# ការត្រួតពិនិត្យមីន

LANDMINE MONITOR

# ២០០៤



# នៅកម្ពុជា

រៀបចំដោយក្រុមយុទ្ធនាការលុបបំបាត់មីនកម្ពុជា

របាយការណ៍ប្រចាំឆ្នាំលើកទី៦ (២០០៣-២០០៤)

**មាតិកា** **ទំព័រ**

គោលនយោបាយលុបបំបាត់មីន (Mine Ban Policy)………………………………………..................…02

ការផលិត ការដឹកជញ្ជូននិងការប្រើប្រាស់មីន (Production, Transfer and Use) .......................05

ការស្តុកទុកនិងការបំផ្លាញឃ្លាំងស្តុកមីន (Stockpiling and Destruction)…….............................06

គ្រាប់មីនរក្សាទុកនៅក្នុងឃ្លាំងសំរាប់បណ្តុះបណ្តាល (Mines Retained for Training)…..…..........08

បញ្ហាដែលកើតមានឡើងដោយសារមីន ( Landmine Problem) ……………………….................09

ការស្រាវជ្រាវនិងការប៉ាន់ប្រមាណ (Survey and Assessment) ……………………….............10

ផែនការការងារនិងការសំរបសំរួលសកម្មភាពមីន (Coordination and Planning of Mine Action)..12

ការបោសសំអាតមីន (Mine Clearance) ……………………………………….............15

ការអប់រំអំពីគ្រោះថ្នាក់មីន (Mine Risk Reduction) …………………………………....……25

មូលនិធិសំរាប់សកម្មភាពមីន ( Mine Action Funding ) ……………………...........................29

អ្នករងគ្រោះថ្នាក់ដោយសាមីន (Mine Casualties)…...................……………………..............32

ការឧបត្ថម្ភអ្នករងគ្រោះដោយសារមីន (Mine Victim Assistance) ………………….............…...35

ការអនុវត្តនិងគោលនយោបាយជនពិការ (Disability policy and Practice)…..............….............48

ក្រុមស្រាវជ្រាវ: បងស្រី **ដេនីស ត្វូតឡិន**
លោក **នី ញ៉ី**

**ដោយ** មានការចូលរួមគាំទ្រពីសមាជិកដែលមានការចាប់អារម្មណ៍ចំពោះយុទ្ធនាការលុបបំបាត់មីនយ៉ាងច្រើន រួមទាំងអ្នកដែលរងគ្រោះដោយសារមីនសំខាន់ៗ និង ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ដែលទទួលរងគ្រោះនិងមានផលប៉ះពាល់ដោយសារមីន ។

ក្រុមយុទ្ធនាការលុបបំបាត់មីនកម្ពុជា: ផ្ទះលេខ៩៦ ផ្លូវ ៥៩២ បឹងកក់២ ទួលគោក ភ្នំពេញ
ទូរស័ព្ទ: ០២៣ ៨៨០ ៩៥៥ / ១៣៩
ទូរសារ: ០២៣ ៨៨០ ១៩០

***ប្រទេសកម្ពុជា***

**០១ តុលា ២០០៤**

*ព្រឹត្តិការណ៍សំខាន់ៗចាប់ពីខែ ឧសភា ឆ្នាំ ២០០៣:* នៅក្នុងឆ្នាំ ២០០៣ ផ្ទៃដីសរុបចំនួន ៤១,៧ លានម៉ែត្រក្រឡា រួមទាំងគ្រាប់មីនប្រឆាំងមនុស្សចំនួន ៦០.៦២០ គ្រាប់, គ្រាប់មីនប្រឆាំងយានយន្ត ចំនួន ១.០៩៦ គ្រាប់ និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ចំនួន ១១៨,៣០៧ គ្រាប់ ត្រូវបានបោសសំអាត។ ចំនួននេះច្រើនជាងឆ្នាំ ២០០២ ចំនួន ២០% និងជាចំនួនច្រើនបំផុតដែលមិនធ្លាប់មានពីមុនមក ។ ការអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីន ត្រូវបានផ្តល់ជូនដល់ប្រជាពលរដ្ឋយ៉ាងហោចណាស់ ៦០០.០០០នាក់ ។ ព្រះរាជាណាចក្រកម្ពុជាបានធ្វើជាសហប្រធានគណៈកម្មការអចិន្ត្រៃយ៍ស្តីអំពីការបោសសំអាតគ្រាប់មីន ការអប់រំគ្រោះថ្នាក់ពីគ្រាប់មីន និងបច្ចេកវិទ្យាសកម្មភាពមីន ចាប់តាំងពីខែ កញ្ញា ឆ្នាំ ២០០៣មកម្លេះ ។ សិក្ខាសាលាជាតិដែលមានចំណងជើងថា "ការកាត់បន្ថយគ្រោះថ្នាក់នៃគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ នៅក្នុងព្រះរាជាណាចក្រកម្ពុជា : ដំណើរឆ្ពោះទៅមុខ" ត្រូវបានរៀបចំធ្វើឡើងនៅខែ មិថុនា ឆ្នាំ ២០០៣ ។ ព្រះរាជាណាចក្រកម្ពុជាបានអនុម័តយកការបោសសំអាតគ្រាប់មីនជាគោលដៅអភិវឌ្ឍន៍ប្រចាំសហស្សវត្សមួយ ។ គេបានរាយការណ៍មកថា : បានរកឃើញគ្រាប់មីនប្រឆាំងមនុស្ស ដែលគេបានរក្សាទុកបន្ថែមចំនួន ៩.២០៧ គ្រាប់ ហើយបានបំផ្លាញគ្រាប់មីនទាំងនេះចោលនៅឆ្នាំ ២០០៣ ។ ព្រះរាជាណាចក្រកម្ពុជាបានរៀបចំផែនការយុទ្ធសាស្រ្ត សំរាប់ជួយជនរងគ្រោះរយៈពេលពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៩។ នៅឆ្នាំ ២០០៣ គេបានរាយការណ៍អំពីករណីកើតមានជាថ្មីនូវគ្រោះថ្នាក់ដោយសារគ្រាប់មីននិងសព្វាវុធមិនទាន់ផ្ទុះចំនួន៧៧២ករណី នៅក្នុងប្រទេសកម្ពុជា ក្នុងនោះស្លាប់១១៥នាក់ និងរបួស ៦៥៧ នាក់។ ក្នុងរយៈពេល ៦ខែដំបូង នៃឆ្នាំ ២០០៤ គេបានកត់ត្រាឃើញថា មានករណីគ្រោះថ្នាក់ដោយសារគ្រាប់មីន និងសព្វាវុធមិនទាន់ផ្ទុះថ្មីចំនួន ៦៧១ ករណី ដោយបង្ហាញអោយឃើញពីទំនោរកើនឡើងដំបូងក្នុង រយៈពេលជាច្រើនឆ្នាំមកនេះ ។

*ព្រឹត្តិការណ៍សំខាន់ៗចាប់ពីឆ្នាំ ១៩៩៩ :* ព្រះរាជណាចក្រកម្ពុជាបានផ្តល់សច្ចានុម័ត សន្ធិសញ្ញាស្តីពីការហាមប្រាមការប្រើប្រាស់គ្រាប់មីនកាលពីថ្ងៃទី២៨ កក្កដា១៩៩៩ ហើយបានចូលជាធរមានកាលពីថ្ងៃទី ១មករា ២០០០។ ច្បាប់អនុវត្តសន្ធិសញ្ញានេះ ចូលជាធរមាននៅថ្ងៃទី ២៨ ឧសភា ១៩៩៩ ច្បាប់ថ្មីនេះបានបង្កើតឡើងនូវអាជ្ញាធរជាតិត្រួតពិនិត្យការបោសសំអាតគ្រាប់មីន ដើម្បីសំរបសំរួលសកម្មភាពនានា ដែលទាក់ទងនឹងបញ្ហាគ្រាប់មីន។ នៅខែ កញ្ញា ២០០០ គេបានបង្កើតឡើងនូវអង្គការសំរបសំរួលថ្មីមួយដែលមានឈ្មោះថា អាជ្ញាធរជំនួយជនរងគ្រោះ និងសកម្មភាពមីនកម្ពុជា ។ ទោះបីជាប្រទេសកម្ពុជាបានប្រកាសនៅឆ្នាំ ១៩៩៩ថា ខ្លួនបានបំផ្លាញគ្រាប់មីនស្តុកទុករបស់ខ្លួនទាំងអស់ចំនួន៧១៩៩១គ្រាប់ក៏ដោយ ក៏គ្រាប់មីនរាប់ពាន់គ្រាប់ត្រូវបានរកឃើញ និងបំផ្លាញចោលជារៀងរាល់ឆ្នាំ ។

ព្រះរាជាណាចក្រកម្ពុជា បានធ្វើជាសហប្រធាន គណៈកម្មាធិការអចិន្ត្រៃយ៍ជំនាញបច្ចេកទេសបោសសំអាតមីន ពីខែឧសភា ១៩៩៩ ដល់ខែកញ្ញា ២០០១ និងជាសហអ្នកទំនាក់ទំនង (Co-Rapporteur) ហើយបន្ទាប់មកធ្វើជាសហប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីអំពីការបោសសំអាតមីន ការអប់រំគ្រោះថ្នាក់នៃគ្រាប់មីន និង បច្ចេកវិទ្យាសកម្មភាពមីនពីខែកញ្ញា ឆ្នាំ២០០២ ដល់ខែធ្នូ ឆ្នាំ ២០០៤ ។ ព្រះរាជាណាចក្រកម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំសិក្ខា

សាលាប្រចាំតំបន់ស្តីអំពី "ការកសាងអនាគតកាលសហប្រតិបត្តិការ សំរាប់សកម្មភាពមីនក្នុងតំបន់អាស៊ីអាគ្នេយ៍ " នៅខែមិនា ឆ្នាំ ២០០៣ ។

ការស្ទាបស្ទង់អំពីឥទ្ធិពលគ្រាប់មីននៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបានបញ្ចប់កាលពីខែមេសាឆ្នាំ២០០២ ហើយបានបង្ហាញអោយឃើញថា ជិតពាក់កណ្តាលនៃភូមិទាំងអស់ត្រូវបានដឹង ឬ សង្ស័យថាបានទទួលរងដោយសារគ្រាប់មីន ឬ យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ។ ផ្ទៃដីជិត ២៥២ លានម៉ែត្រក្រឡា ត្រូវបានបោសសំអាតចាប់ពីឆ្នាំ ១៩៩២ ដល់ឆ្នាំ ២០០៣ និងជាង១៤៦ លានម៉ែត្រក្រឡា ក៏ត្រូវបានបោសសំអាតពីឆ្នាំ ១៩៩៩ ដល់ ២០០៣ ។ ក្រុមរៀបចំគំរោងប្រើប្រាស់ដីធ្លីត្រូវបានបង្កើតឡើងកាលពីខែ ឧសភា ឆ្នាំ ១៩៩៩ ។ មជ្ឈមណ្ឌលសកម្មភាពមីនកម្ពុជាបានប្រឈមមុខនឹងវិបត្តិមូលនិធិ ដែលនាំអោយមជ្ឈមណ្ឌលនេះ សំរេចបញ្ឈប់បុគ្គលិកលែងអោយធ្វើការជាបណ្តោះអាសន្នជាច្រើននាក់ ហើយបានបិទជាបណ្តោះអាសន្ននូវប្រតិបត្តិការបោសសំអាតគ្រាប់មីននានា ក្នុងខែ តុលា ឆ្នាំ ២០០០ ។ រវាងឆ្នាំ ១៩៩៩ និង ឆ្នាំ ២០០២ ប្រជាពលរដ្ឋប្រហែល ២,១ លាននាក់ បានចូលរួមនៅក្នុងសិក្ខាសាលាអប់រំស្តីអំពីគ្រោះថ្នាក់នៃគ្រាប់មីន ។

ចាប់តាំងពីឆ្នាំ ១៩៩៩ មក អវៈយវៈសិប្បនិម្មិតចំនួនជាង ២៨.០០០ សំរាប់ ត្រូវបានផលិត និង តំឡើង ដែលភាគច្រើនផ្តល់អាទិភាពដល់អ្នកនៅមានជីវិតពីគ្រាប់មីន ។ កម្មវិធីថ្មីៗដើម្បីសំរួលសមាហរណកម្មសេដ្ឋកិច្ចសង្គមដល់អ្នកនៅមានជីវិតពីគ្រាប់មីន និង គ្រួសាររបស់គេត្រូវបានអនុវត្តឡើង ។ ទោះជាយ៉ាងណាក៏ដោយ មជ្ឈមណ្ឌលស្តារសម្បទា (Physical Rehabilitation Center) បានធ្លាក់ចុះពីចំនួន ១៥ ក្នុងឆ្នាំ ១៩៩៩ មកនៅត្រឹមចំនួន ១១ ក្នុងឆ្នាំ ២០០៤ ។ រវាងឆ្នាំ ១៩៩៩ និង ខែសីហា ឆ្នាំ ២០០៤ ករណីគ្រោះថ្នាក់ថ្មីៗដោយសារគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះត្រូវបានកត់ត្រាថាកើតមានឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ អត្រាដោយសារគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះបានធ្លាក់ចុះ គិតជាមធ្យម ១២ករណី ក្នុងមួយថ្ងៃ នៅក្នុងឆ្នាំ ១៩៩៦ មកនៅត្រឹម ៣ ករណី ក្នុងមួយថ្ងៃក្នុងឆ្នាំ ១៩៩៩, ២ករណី ក្នុងមួយថ្ងៃ ពីឆ្នាំ ២០០០-២០០៣ ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងរយៈពេល ៨ ខែ ដំបូង នៃឆ្នាំ ២០០៤ អត្រាគ្រោះថ្នាក់នេះបានកើតឡើងជាថ្មីដល់គិតជាមធ្យមជិត ៣ ករណី ក្នុងមួយថ្ងៃ ។

## គោលនយោបាយហាមប្រាមការប្រើប្រាស់គ្រាប់មីន

ព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីន នៅថ្ងៃទី ០៣ ធ្នូ ឆ្នាំ ១៩៩៧ ហើយបានផ្តល់សច្ចានុម័តដល់សន្ធិសញ្ញានេះនៅថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ១៩៩៩ ។ សន្ធិសញ្ញានេះបានចូលជាធរមានសំរាប់ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០០ ។ ច្បាប់អនុវត្តនៅក្នុងប្រទេសគឺច្បាប់ហាមឃាត់ការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស បានចូលជា ធរមាននៅថ្ងៃទី ២៨ ខែឧសភា ឆ្នាំ១៩៩៩ [1] ។

[1] The law bans the production, use, possession, transfer, trade, sale, import and export of antipersonnel mines. It provides for criminal penalties, including fines and imprisonment for offences committed by civilians or members of the police and the armed forces. It also provides for the destruction of mine stockpiles.

ច្បាប់នេះបានផ្តល់អោយមានការបង្កើតអាជ្ញាធរត្រួតពិនិត្យការបោសសំអាតគ្រាប់មីនជាតិ ដើម្បីសំរបសំរួលសកម្មភាពនានាទាក់ទងនឹងបញ្ហាមីន។ ប្រទេសកម្ពុជាគឺជាអ្នកគាំទ្រមួយក្នុងចំណោមអ្នកគាំទ្រដំបូងគេទាំងឡាយចំពោះការហាមប្រាមជាទូទៅនូវការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស ហើយគឺជាអ្នកចូលរួមដ៏សកម្មនៅក្នុងដំណើរការនេះ ក្នុងទីក្រុង Ottawa ចាប់តាំងពីដំបូងមក។ ប្រទេសកម្ពុជាបានបោះឆ្នោតតាមគ្រប់សេចក្តីសំរេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ដែលជំរុញអោយមានការហាមប្រាមការប្រើប្រាស់គ្រាប់មីន ចាប់ពីឆ្នាំ ១៩៩៦មក។

ប្រទេសកម្ពុជា បានចូលរួមក្នុងគ្រប់កិច្ចប្រជុំប្រចាំឆ្នាំនៃភាគីរដ្ឋសមាជិកនៃសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីន និង គ្រប់អន្តរកិច្ចប្រជុំទាំងអស់ ។ នៅក្នុងកិច្ចប្រជុំលើកទី ៥ នៃភាគីរដ្ឋសមាជិកនៅក្នុងខែ កញ្ញា ឆ្នាំ ២០០៣ ព្រះរាជាណាចក្រកម្ពុជា រួមជាមួយនឹងប្រទេសជប៉ុនបានក្លាយជាសហប្រធានគណៈកម្មការអចិន្ត្រៃយ៍ស្តីអំពីការបោសសំអាតមីន ការអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីន និង បច្ចេកវិទ្យាសកម្មភាពមីន ដើរតួជាសហអ្នកទំនាក់ទំនង (co-rapporteur) កាលពីឆ្នាំមុន។ ក្នុងតួនាទីរបស់ខ្លួនជាសហប្រធានប្រទេសកម្ពុជាបានគាំទ្រដល់ការបង្កើតឡើងនូវ "គោលការណ៍ 4P" (Problem : បញ្ហា, Plan : គំរោង, Progress : ដំណើរការ និង Priorities : អាទិភាព) ដែលមានគោលបំណងសំដៅវាស់វែងអំពីដំណើរការសកម្មភាពមីន និង ប៉ាន់ប្រមាណអំពីបញ្ហាដែលនៅសេសសល់សំរាប់ការអនុវត្តន៍ទាំងស្រុងនូវមាត្រា ៥ (ការបោសសំអាតគ្រាប់មីន) នៃសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីន ។ ដោយមានជំនួយពីក្រុមគាំទ្រការអនុវត្តន៍ គេបានចងក្រងឡើងនូវពត៌មានសាវតាស្តីអំពីភាគីប្រទេសដែលរងគ្រោះដោយគ្រាប់មីនចំនួនជាង ៤០ ប្រទេស [2]។ ប្រទេសកម្ពុជាគឺជាសហប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ ស្តីអំពីបច្ចេកវិទ្យាបោសសំអាតមីន ពីខែ ឧសភា ឆ្នាំ ១៩៩៩ ដល់ខែកញ្ញា ឆ្នាំ ២០០០ ។

ប្រទេសកម្ពុជាបានចូលរួមក្នុងក្រុមសកម្មភាពប្រចាំតំបន់នៅទីក្រុងបាងកក (BRAG) ដែលក្រុមនេះត្រូវបានបង្កើតឡើងដោយភាគីរដ្ឋសមាជិកមកពីតំបន់អាស៊ីប៉ាស៊ីហ្វិក ក្នុងខែ កញ្ញា ឆ្នាំ ២០០២ ដោយមានគោលបំណងជំរុញការផ្តួចផ្តើមអោយមានការហាមប្រាម ប្រើប្រាស់គ្រាប់មីនក្នុងតំបន់ និង នាំទៅរកកិច្ចប្រជុំលើកទី៥ នៃភាគីរដ្ឋសមាជិកក្នុងទីក្រុងបាងកក។ ប្រទេសកម្ពុជាបានធ្វើជាម្ចាស់ផ្ទះ រៀបចំសិក្ខាសាលាប្រចាំតំបន់ស្តីអំពី "ការកសាងអនាគតកាលសហប្រតិបត្តិការសំរាប់សកម្មភាពមីនក្នុងតំបន់អាស៊ីអាគ្នេយ៍" នៅក្នុងទីក្រុងភ្នំពេញ ថ្ងៃទី ២៦-២៨ ខែ មិនា ឆ្នាំ ២០០៣ ។ តំណាងនានាមកពីប្រទេសអាស៊ីអាគ្នេយ៍ ប្រទេសចិន ប្រទេសទីម័រ (Timor-Leste) និងប្រទេសស្រីលង្កាព្រមទាំងប្រទេសផ្តល់ជំនួយជាច្រើនទៀតបានចូលរួមនៅក្នុងសិក្ខាសាលានេះ។

ប្រទេសកម្ពុជាបានដាក់ជូននូវរបាយការណ៍តម្លាភាព មាត្រា ៧ ប្រចាំឆ្នាំ របស់ខ្លួន នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៤ សំរាប់ប្រក្រតីទិនឆ្នាំ ២០០៣ ។ របាយការណ៏នោះរាប់បញ្ចូលទាំងទំរង់ស្ម័គ្រចិត្ត អក្សរ J (voluntary Form J) ដោយរាយការណ៍អំពីគ្រោះថ្នាក់នៃគ្រាប់មីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (UXO) និងការស្តារឡើងវិញនូវ

[2] CMAA, ''Mine Action Achievements in the Kingdom of Cambodia 1992-2003,'' 29 April 2004, p. 37.

អ្នកនៅរស់រានមានជីវិតពីគ្រាប់មីន ។ នេះគឺជារបាយការណ៍មាត្រា ៧ ទី ៥ របស់ខ្លួន [3] ។

ប្រទេសកម្ពុជា មិនបានចូលរួមនៅក្នុងកិច្ចពិភាក្សាទូលំទូលាយ ដែលភាគីប្រទេសទាំងនោះបានរៀបចំឡើង ស្តីអំពីបញ្ហានៃការបកស្រាយ និង ការអនុវត្តន៍ទាក់ទងនឹងមាត្រា ១, មាត្រា ២ និង មាត្រា ៣ ។ ដូច្នេះប្រទេសកម្ពុជាមិនត្រូវបានដឹងអំពីទស្សនៈរបស់ខ្លួនចំពោះបញ្ហានានា ដែលទាក់ទងនឹងប្រតិបត្តិការយោធា រួមជាមួយភាគីមិនមែនរដ្ឋសមាជិកទាំងនោះ, គ្រាប់មីនប្រឆាំងយានយន្ត ដែលមានគ្រាប់កិបអាចបង្កគ្រោះថ្នាក់និងឧបករណ៍មិនមែនប្រើប្រាស់ដោយដៃ និង ចំនួនគ្រាប់មីនដែលគេបានអនុញ្ញាតដើម្បីរក្សាទុកធ្វើការហ្វឹកហាត់ ។

ប្រទេសកម្ពុជាគឺជាភាគីរដ្ឋសមាជិកពង្រាងអនុស្សរណៈទីIIដែលបានធ្វើវិសោធនកម្មនៃអនុសញ្ញាយុទ្ធភ័ណ្ឌមិនមែននុយក្លេអ៊ែរ (CCW) ចាប់តាំងពីថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ១៩៩៧ ហើយបានចូលរួមក្នុងសន្និសីទប្រចាំឆ្នាំលើកទី ៥ នៃភាគីរដ្ឋសមាជិកកាលពីថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ។



នៅខែកុម្ភៈ ឆ្នាំ២០០៤ រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តយកការបោសសំអាតគ្រាប់មីន ជាគោលដៅអភិវឌ្ឍន៍សហស្សវត្សបន្ថែម សំរាប់ព្រះរាជាណាចក្រកម្ពុជាគឺជាគោលដៅទី៩ថ្មីបន្ថែមលើគោលដៅទាំង ៨ ដែលអនុម័តដោយអង្គការសហប្រជាជាតិ [4] ។ នៅក្នុងសន្និបាតជាតិ ស្តីអំពីសមិទ្ធិផលសកម្មភាពមីន របស់អាជ្ញាធរជំនួយជនរងគ្រោះ និង សកម្មភាពមីនកម្ពុជា (CMAA) នាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានបញ្ជាក់ថា "គ្រាប់មីនមិនត្រឹមតែក៏រិតនូវសិទ្ធិរបស់យើងចំពោះធនធានធម្មជាតិពិសេសដីធ្លីប៉ុណ្ណោះទេ ប៉ុន្តែគ្រាប់មីនថែមទាំងបណ្តាលអោយប្រជាពលរដ្ឋនៅជនបទបោះបង់ចោលនូវភូមិកំណើតរបស់គេ ហើយមកតាំងពីលំនៅនៅតំបន់ជាយក្រុង។ ចំណាកស្រុកបែបនេះធ្វើអោយកាន់តែអាក្រក់នូវកំណើនប្រជាពលរដ្ឋលើសលប់ ការអន់ថយបរិស្ថានសង្គម ជាពិសេសក្នុងតំបន់ជាយក្រុង។ ប្រជាពលរដ្ឋក្រីក្រនិងងាយរងគ្រោះ តែងតែចាកចេញពីស្រុកដោយគ្មានជំរើស ក្រៅពីប្រថុយរស់នៅដោយធ្វើការនៅក្នុងតំបន់ដែលមានគ្រាប់មីន។ តាមពិតបញ្ហាបោសសំអាតគ្រាប់មីនមិនត្រឹមទាក់ទងតែបញ្ហាសន្តិសុខសង្គមប៉ុណ្ណោះទេ តែថែមទាំងទាក់ទងនឹងកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ជាទូទៅ ព្រោះវាទាក់ទងនឹងការបែងចែកដីធ្លី និងការផ្តល់សំណាញ់សុវត្ថិភាពដល់គ្រួសារកសិករក្រីក្រក្នុងតំបន់ជនបទដាច់ស្រយាល" [5] ។

---

[3] Previous Article 7 reports were submitted on: 15 April 2003 (for calendar year 2002); 19 April 2002 (for calendar year 2001); 30 June 2001 (for calendar year 2000); and 26 June 2000 (for the period from 1993 to 26 June 2000).

[4] Statement by Prime Minister Hun Sen, at the National Conference on Mine Action Achievements 2003 of the CMAA, Phnom Penh, 19 February 2004.

[5] Ibid.

យុទ្ធនាការកម្ពុជាដើម្បីលុបបំបាត់គ្រាប់មីន(CCBL)គឺជាអ្នកគាំទ្រដ៏សកម្មចំពោះគោលដៅសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីន និងតំរូវការរបស់អ្នករស់រានមានជីវិតពីគ្រាប់មីន ។ នៅឆ្នាំ ២០០៣ និង ២០០៤ CCBL បានបន្តជំរុញផ្តួចផ្តើមបង្កើតយុទ្ធនាការនានានៅតាមក៏រិតតំបន់ និង អន្តរជាតិ ។ ក្នុងកំឡុងឆ្នាំនោះ CCBL បានធ្វើជាម្ចាស់ផ្ទះដល់អ្នកកាសែត អ្នកផលិតខ្សែភាពយន្ត អង្គការនានា និង អ្នកបង្កើតយុទ្ធនាការទាំងឡាយមកពីប្រទេសដទៃទៀតរួមទាំងប្រទេសសឹង្ហបុរីដែលមានចំណាប់អារម្មណ៍ក្នុងការជំរុញគោលដៅសន្ធិសញ្ញានេះ ។ ចំពោះកិច្ចប្រជុំលើកទី ៥ នៃភាគីរដ្ឋសមាជិកគណៈប្រតិភូអ្នកបង្កើតយុទ្ធនាការកម្ពុជា រួមទាំងអ្នកនៅមានជីវិតពីគ្រាប់មីនចំនួន ១០ នាក់ បានធ្វើដំណើរទៅទីក្រុងបាងកក ហើយនៅតាមផ្លូវពួកគេបានប្រជុំគ្នាដើម្បីគាំទ្រដល់សន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីនហើយបានបញ្ចេញនូវ *របាយការណ៍របស់អ្នកត្រួតពិនិត្យគ្រាប់មីនឆ្នាំ២០០៣* នៅតាមទីរួមខេត្តនានា ។

ទូតជនពិការនៃអង្គការយុទ្ធនាការលុបបំបាត់មីនអន្តរជាតិ (ICBL) លោក ទន់ ចាន់ណារ៉ែត និងលោក Greg Priyadi បានធ្វើដំណើរទស្សនកិច្ចប្រទេសឥណ្ឌូនេស៊ី ចំនួន ២ លើក ហើយបានរៀបចំកិច្ចប្រជុំជាច្រើនជាមួយមន្ត្រីកំពូលៗរបស់រដ្ឋាភិបាល និង មន្ត្រីយោធា ដែលបានសន្យាផ្តល់សច្ចានុម័តលើសន្ធិ សញ្ញានេះ ។ ទូតយុវជនកញ្ញា សុង កុសល បានជំរុញគំនិតផ្តួចផ្តើមបង្កើតយុទ្ធនាការក្នុងចំណោមយុវវ័យក្នុងប្រទេសជាច្រើន ។

ពីថ្ងៃទី ២៦-២៩ ខែ មេសា ឆ្នាំ ២០០៤ ប្រតិភូកម្ពុជានៃយុទ្ធនការលុបបំបាត់មីនអន្តរជាតិ បានចូលរួមក្នុងសន្និបាតសកម្មភាពមីនក្នុងទីក្រុង Kunming ប្រទេសចិន ដែលរៀបចំឡើងដោយប្រទេសចិននិងបណ្តាញយុទ្ធនាការលុបបំបាត់មីនអន្តរជាតិអូស្ត្រាលី (Australian Network of ICBL) ហើយបានអំពាវនាវដល់ប្រទេសចិនអោយមកចូលរួមក្នុងសន្និបាតត្រួតពិនិត្យសន្ធិសញ្ញាលុបបំបាត់មីនឡើងវិញក្នុងទីក្រុងណៃរ៉ូប៊ី (Nairobi Review Conference) ក្នុងឋានៈជាភាគីរដ្ឋសមាជិកមួយ ។

## ការផលិត, ការដឹកជញ្ជូន និងការប្រើប្រាស់គ្រាប់មីន

ចាប់តាំងពីឆ្នាំ ១៩៩៩ មក មិនមានការអះអាងជាក់លាក់ណាមួយអំពីការប្រើប្រាស់ ការផលិត ឬ ការដឹកជញ្ជូនគ្រាប់មីនប្រឆាំងមនុស្ស ដោយកងកំលាំងរដ្ឋាភិបាល ឬកំលាំងប្រឆាំងណាមួយឡើយ ។ ប្រទេសកម្ពុជាបានរាយការណ៍ថា ខ្លួនមិនមានឧបករណ៍ផលិតគ្រាប់មីនប្រឆាំងមនុស្សណាមួយឡើយ ។[6] រដ្ឋាភិបាលកម្ពុជាបានផលិតមីនប្រឆាំងមនុស្សមួយប្រភេទ ឈ្មោះថា មីនប្រភេទ Claymore KN-10 នៅក្នុងទសវត្សឆ្នាំ ១៩៧០ ហើយកំលាំងនានាបានផលិតមីនធ្វើដោយដៃនៅក្នុងអតីតកាល ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ គ្រាប់មីនជាច្រើនបានធ្វើចរាចរឆ្លងកាត់ព្រំដែនប្រទេសកម្ពុជា ទោះបីជាគេពិបាកដឹងថាគ្រាប់មីនប្រភេទអ្វី ដែលបាននាំចូលដោយរដ្ឋាភិបាលកម្ពុជា ដោយកំលាំងប្រឆាំង និង គ្រាប់មីនប្រភេទមួយណាដែលត្រូវបាននាំចូលមកប្រទេសកម្ពុជាធម្មតាដោយកងកំលាំងបរទេសក៏ដោយ ។ ចាប់តាំងពីខែតុលា ឆ្នាំ ១៩៩៤ មក ប្រទេសកម្ពុជាបានរក្សាទុកនូវជំហរផ្លូវការ

[6] Article 7 Report, Form E, 15 April 2003.

មួយប្រឆាំងនឹងការនាំចូល និង នាំចេញគ្រាប់មីនប្រឆាំងមនុស្ស ។ រដ្ឋាភិបាលកម្ពុជាមិនត្រូវបានដឹងថាបាននាំចេញនូវគ្រាប់មីនប្រឆាំងមនុស្សក្នុងអតីតកាលឡើយ [7] ។

គ្រាប់មីនជាច្រើនត្រូវបានដាក់ពង្រាយជាលើកដំបូងក្នុងប្រទេសកម្ពុជានៅពាក់កណ្តាលទសវត្សឆ្នាំ ១៩៦០ ព្រោះថា ប្រទេស កម្ពុជាត្រូវបានចាប់ផ្តើមអូសទាញចូលទៅក្នុងសង្គ្រាមឥណ្ឌូចិន ។ ក្នុងកំឡុងរបបកម្ពុជាធិបតេយ្យពីឆ្នាំ ១៩៧៥-១៩៧៩ កំលាំងខ្មែរ ក្រហមបានប្រើប្រាស់គ្រាប់មីនយ៉ាងទូលំទូលាយ ទាំងក្នុងគោលបំណងយោធា និង ក្នុងគោលបំណងប្រើប្រាស់ដើម្បីគ្រប់គ្រងប្រជាពលរដ្ឋស៊ីវិល ។ គ្រាប់មីនត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយក្នុងកំឡុងសង្គ្រាមស៊ីវិល ដែលអូសបន្លាយបន្ទាប់ការដួលរលំនៃរបបខ្មែរក្រហម និង បន្តរហូតដល់ទសវត្សឆ្នាំ ១៩៩០ ។ មានរបាយការណ៍ និង អំណះអំណាងជាច្រើនអំពីការប្រើប្រាស់គ្រាប់មីនដោយកងយោធពលខេមរភូមិន្ទ និង កំលាំងខ្មែរក្រហមរហូតដល់ឆ្នាំ ១៩៩៨ ។ ខេត្តនៅភាគពាយ័ព្យប្រទេស បានក្លាយជាសមរភូមិសំខាន់ៗក្នុងប្រទេសកម្ពុជា ។ គ្រាប់មីនជាច្រើនជារឿយៗត្រូវបានដាក់បង្កប់នៅក្នុងតំបន់ដដែលដោយកំលាំងផ្សេងៗគ្នា ដែលការណ៏នេះបង្កើតអោយក្លាយជាតំបន់ដែលពោរពេញដោយគ្រាប់មីនក្រាស់ ដោយគ្មានការបញ្ជា ។ នៅចុងឆ្នាំ ១៩៨៤ ដើម្បីជាការបិទច្រកព្រំដែន គេបានបង្កើតខ្សែក្រវ៉ាត់ **ក.៥** (K5) ដែលបង្កប់ដោយគ្រាប់មីនប្រវែង ៧00 គីឡូម៉ែត្រ ដែលមានគ្រាប់មីនប្រហែលពី ២ ទៅ ៣ លានគ្រាប់ ចាប់ពីដែនសមុទ្រភាគពាយ័ព្យប្រទេសកម្ពុជារហូតដល់ព្រំដែនថៃ និង ឡាវ ។

## ការស្តុកទុក និង ការបំផ្លាញចោលគ្រាប់មីន



កងយោធពលខេមរភូមិន្ទបានបំផ្លាញចោលនូវគ្រាប់មីនប្រឆាំងមនុស្សដែលបានរក្សាទុកចំនួន ៧១.៩៩១ គ្រាប់ ក្នុងរយះពេលពីឆ្នាំ ១៩៩៤ ដល់ឆ្នាំ ១៩៩៨ ។ ក្នុងខែ កុម្ភៈ ឆ្នាំ ១៩៩៩ នាយរងអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ បានបញ្ជាក់ជាផ្លូវការថា កងយោធពលខេមរភូមិន្ទមិនមានរក្សាទុកនូវគ្រាប់មីនប្រឆាំងមនុស្សតទៅទៀតឡើយ [8] ។ នៅឆ្នាំ២០០០ ប្រទេសកម្ពុជាបានធ្វើ របាយការណ៏អំពីគ្រាប់មីនចំនួន ២.០៣៤ គ្រាប់ ដែលរក្សាទុកដោយប៉ូលីសជាតិ ។[9] ប្រទេសកម្ពុជាបានប្រកាសជាបន្តបន្ទាប់ថា មិនមានរក្សាទុកនូវគ្រាប់មីនប្រឆាំងមនុស្សនៅក្នុងប្រទេសឡើយចាប់តាំងពីឆ្នាំ ២០០១ មក [10] ។ យ៉ាងណាក៏ដោយ កំលាំងប៉ូលីស និង យោធា

[7] See *Landmine Monitor Report 2000*, pp. 382–383.
[8] See *Landmine Monitor Report 1999*, p. 391, for annual destruction totals.
[9] Types included DH10, M18A1, PMN, PNM2, OZM4, POMZ2, POMZ2M, K, MH, Type 72, Type 69, 652A, blast mines and improvised mines. Article 7 Report, Form B, 26 June 2000.
[10] Article 7 Report, Form F, 30 April 2004.

តែងតែបានរកឃើញនូវកន្លែងលាក់អាវុធនានា រួមទាំងគ្រាប់មីនប្រឆាំងមនុស្សនៅទូទាំងប្រទេសកម្ពុជា[11] ។ កន្លែងរក្សាទុកគ្រាប់មីនប្រឆាំងមនុស្សដែលបានរកឃើញថ្មីៗនេះ នឹងត្រូវបានរាយការណ៍ទៅ CMAA និង ប្រគល់អោយអង្គការ CMAC ដើម្បីបំផ្លាញចោល ។

ក្នុងរបាយការណ៍មាត្រា៧ ចេញនៅខែមេសា ឆ្នាំ២០០៤ របស់ខ្លួន ប្រទេសកម្ពុជាបានរាយការណ៍ថា: ពីឆ្នាំ ២០០០-២០០៣ ចំនួនគ្រាប់មីនប្រឆាំងមនុស្សសរុបចំនួន ៧៤.៥៤៤ គ្រាប់ ត្រូវបានរកឃើញ និង បំផ្លាញចោល រួមទាំងគ្រាប់មីនចំនួន ៩.២០៧គ្រាប់ នៅឆ្នាំ ២០០៣ [12] ។ នេះគឺជាចំនួនដែលបានកើតឡើងធ្ងន់ធ្ងរបំផុតនៃចំនួនដែលបានរាយការណ៍ពីមុនមកគឺរបាយការណ៍មាត្រា ៧ ខែ មេសា ឆ្នាំ ២០០៣ បានបង្ហាញពីចំនួនគ្រាប់មីនសរុប ១៥.៥៦៧ គ្រាប់ ត្រូវបានបំផ្លាញចោលពីឆ្នាំ ២០០០ ដល់ ២០០២ ។ នៅពេលដែលត្រូវបានសួរអំពីការបង្ហាញដ៏គួរអោយភ្ញាក់ផ្អើលនេះ អាជ្ញាធរមីនបាននិយាយថា តួលេខចំនួន ៧៤.៥៤៤ គ្រាប់នោះ ទំនងជាកំហុស ហើយអាចនឹងរួមបញ្ចូលទាំងការបំផ្លាញគ្រាប់មីនមួយចំនួនមកពីតំបន់ដែលមានមីន[13] ។ ជាបន្តបន្ទាប់ អាជ្ញាធរមីនបានផ្តល់នូវតួលេខកែប្រែដល់អ្នកត្រួតពិនិត្យគ្រាប់មីន គឺចំនួនគ្រាប់មីនប្រឆាំងមនុស្សសរុប ៣៨.៨១២ គ្រាប់ ត្រូវបានរកឃើញ និង បំផ្លាញចោលពីឆ្នាំ ២០០០-២០០៣ ក្នុងនោះមានគ្រាប់មីនចំនួន ៨.៧៣៩ គ្រាប់ នៅឆ្នាំ ២០០០ គ្រាប់មីនចំនួន ៧.៣៥៧ គ្រាប់ នៅឆ្នាំ ២០០១ ចំនួន ១៣.៥០៩ គ្រាប់ នៅឆ្នាំ ២០០២ និង ៩.២០៧ គ្រាប់ នៅឆ្នាំ ២០០៣[14] ។

ការរកឃើញ និង ការបំផ្លាញចោលគ្រាប់មីនប្រឆាំងមនុស្ស មិនត្រូវបានរាយការណ៍ទាំងស្រុង ឬ ជាហូរហែរឡើយនៅក្នុងរបាយការណ៍មាត្រា ៧ ពីមុនមក ។ របាយការណ៍មាត្រា ៧ ខែ មិថុនា ឆ្នាំ ២០០០ បានបញ្ជាក់អំពីការបំផ្លាញចោលនូវគ្រាប់មីនចំនួន ១៣.៤០៧ គ្រាប់ របស់ CMAC ពីឆ្នាំ ១៩៩៧ ដល់ ២០០០ ប៉ុន្តែមិនបានបែងចែករវាងគ្រាប់មីនប្រឆាំងរថក្រោះ និង គ្រាប់មីនប្រឆាំង មនុស្សឡើយ[15] ។ របាយការណ៍ខែមិថុនា ឆ្នាំ២០០១ បាននិយាយថា CMAC បានបំផ្លាញចោលនូវគ្រាប់មីនដែលបានរកឃើញថ្មីៗ ចំនួន ១១.៤១៧ គ្រាប់ នៅឆ្នាំ ២០០០[16] ។ របាយការណ៍ខែ មេសា ឆ្នាំ ២០០២ បាននិយាយថា គ្រាប់មីនដែលបានរកឃើញថ្មីៗចំនួន ៥៣៣ គ្រាប់ ត្រូវបានបំផ្លាញចោលនៅឆ្នាំ ២០០១ និង ចំនួន ៣.១៦៥ គ្រាប់ទៀត ត្រូវបានបំផ្លាញចោលនៅខែមករា ឆ្នាំ ២០០២[17] ។ ក្នុងរបាយការណ៍ខែ មេសា ឆ្នាំ ២០០០ របស់ខ្លួនប្រទេសកម្ពុជាបានបញ្ជាក់ថា : ចាប់តាំងពីការបញ្ចប់ជាផ្លូវការនូវការបំផ្លាញគ្រាប់មីន ដែលរក្សាទុកក្នុងឆ្នាំ ១៩៩៨មក ប្រទេសកម្ពុជាបានរកឃើញគ្រាប់មីនប្រឆាំងមនុស្សបន្ថែមចំនួន ១៧.១០០ គ្រាប់ ដែលចំនួន ១៥.៥៦៧ គ្រាប់ ក្នុងចំណោមគ្រាប់មីនទាំងនោះត្រូវបាន

[11] See, for example, CMAA, "2002 Activities Report of CMAA," 31 December 2002, p. 21; Article 7 Report, Forms D and F, 15 April 2003.
[12] Article 7 Report, Form G, 30 April 2004.
[13] Email from Cambodia Campaign to Ban Landmines, 5 October 2004.
[14] Ibid, with revised Article 7 Report, Form G, provided by Prum Sophak Mongkul, CMAA.
[15] Article 7 Report, Form F, 26 June 2000.
[16] Article 7 Report, Forms B and F, 30 June 2001. The report indicated that 8,739 stockpiled antipersonnel mines were found and destroyed by CMAC, another 1,078 by the Royal Cambodian Armed Forces, and about 1,600 by the National Police in 2000.
[17] Article 7 Report, Form F, 19 April 2002.

បំផ្លាញចោល ហើយចំនួន ១.៥៣៣ គ្រាប់ ត្រូវបានប្រើប្រាស់ក្នុងការហ្វឹកហាត់ [18] ។

ការដោះមីននៅតាមភូមិជាបច្ច័យចំពោះចំនួនដ៏ច្រើននៃគ្រាប់មីនដែលបានរកឃើញថ្មីៗ ក្នុងគោលបំណងយកដែកលក់ ។ អាជីវករលក់ដែកម្នាក់នៅខេត្តកំពង់ធំបានប្រាប់អ្នកត្រួតពិនិត្យគ្រាប់មីនថា ៖ នៅឆ្នាំ ២០០៣ គាត់បានទិញយុទ្ធភ័ណ្ឌចាស់ៗចំនួន ២០០តោន រួមទាំងគ្រាប់មីនចាស់ៗហួសសម័យផងដែរ ។ គាត់បានធ្វើអាជីវកម្មជាមួយអ្នកជំនួញនៅប៉ោយប៉ែត ដែលលក់ដែកអោយទៅប្រទេសថៃ ។ ក្នុងករណីខ្លះ អ្នកប្រមូលទិញ និង អ្នកលក់ដែកត្រូវទទួលរងរបួស និង ស្លាប់ផងដែរ ។

ជាការឆ្លើយតបទៅនឹងការអះអាងថា គ្រាប់មីនប្រឆាំងមនុស្សដែលមានគុណភាពល្អនៅតែត្រូវបានរក្សាទុកនៅក្នុងឃ្លាំងតំបន់យោធា[19] អាជ្ញាធរមីនបានឆែកឆេរជាមួយមេបញ្ជាការកងយោធពលខេមរភូមិន្ទប្រចាំតំបន់ភូមិភាគ ៥ (ខេត្តបាត់ដំបង) ហើយបានទទួលការអះអាងបញ្ជាក់ថា មិនមានគ្រាប់មីនប្រឆាំងមនុស្សណាមួយត្រូវបានរក្សាទុកនៅឃ្លាំងភូមិភាគ ៥ ឡើយ[20] ។ អ្នកត្រួតពិនិត្យគ្រាប់មីនបានស្នើអោយអាជ្ញាធរមីន ទៅពិនិត្យគ្រប់ឃ្លាំងរបស់យោធាភូមិភាគទាំងអស់ នាមុនពេលសន្និបាតត្រួតពិនិត្យសន្ធិសញ្ញាលុបបំបាត់មីនឡើងវិញ ក្នុងទីក្រុង Nairobi (Nairobi Review Conference) ដើម្បីផ្ទៀងផ្ទាត់នូវការខកខានមិនបានរាប់បញ្ចូលគ្រាប់មីនប្រឆាំងមនុស្សដែលបានរក្សាទុកណាមួយ ។ នៅខែកុម្ភៈ ឆ្នាំ ២០០២ លោកនាយករដ្ឋមន្ត្រីបាននិយាយថា ៖ " យើងត្រូវតែប្រមូលយកគ្រាប់មីនទាំងនោះ មិនត្រឹមតែគ្រាប់មីនដែលមិនបានរកឃើញកប់នៅក្នុងវាលប៉ុណ្ណោះទេ ប៉ុន្តែប្រមូលយកទាំងគ្រាប់មីនដែលបានរក្សាទុកនៅក្នុងឃ្លាំងរួមទាំងឃ្លាំងរបស់ប៉ូលីសនិងយោធា ដើម្បីអោយអង្គការ CMAC កំទេចចោល" [21] ។

## គ្រាប់មីនរក្សាទុកសំរាប់ការហ្វឹកហាត់

នៅក្នុងរបាយការណ៍មាត្រា ៧ ទាំង ៥ របស់ខ្លួន ដូចបានអនុញ្ញាតតាមមាត្រា ៣ ប្រទេសកម្ពុជាបានបង្ហាញថា ខ្លួនមិនមានគ្រាប់មីនរក្សាទុកសំរាប់ការហ្វឹកហ្វឺន ឬ អភិវឌ្ឍន៍អ្វីឡើយ ។ យ៉ាងណាក៏ដោយ ខ្លួនក៏បានរាយការណ៍អំពីការផ្ទេរគ្រាប់មីនសំរាប់ការ ហ្វឹកហាត់ និង ការអភិវឌ្ឍន៍ទៅមជ្ឈមណ្ឌលហ្វឹកហ្វឺនរបស់ CMAC នៅឆ្នាំ ១៩៩៨ (២៣៦ គ្រាប់), ឆ្នាំ ១៩៩៩ (៨១៨ គ្រាប់), ឆ្នាំ ២០០០ (៥២ គ្រាប់), ឆ្នាំ ២០០១ (៤២៣ គ្រាប់), ឆ្នាំ ២០០២ (២៤០ គ្រាប់) និង ឆ្នាំ ២០០៣ (៣៦៦ គ្រាប់) [22] ។ វាទំនងជាថា ជារៀងរាល់ឆ្នាំ គ្រាប់មីនមួយចំនួនត្រូវបានបញ្ជូនទៅមជ្ឈមណ្ឌលហ្វឹកហ្វឺនរបស់ CMAC គឺគ្រាប់មីន ដែលបានដោះចេញពីដីដោយអ្នកដោះមីន ឬ គ្រាប់មីនដែលបានរកឃើញពីកន្លែងលាក់ទុកថ្មីៗ ហើយប្រើប្រាស់ភ្លាមៗបន្ទាប់ពីពេលនោះ ។

---

[18] Article 7 Report, Form D, 15 April 2003.

[19] For details see *Landmine Monitor Report 2001*, p. 439.

[20] Interview with Sam Sotha, Director General, Cambodian Mine Action and Victim Assistance Authority, Kumning,30 April 2004.

[21] Address by Prime Minister Samdech Hun Sen, Rottank Mundul, 24 February 2002.

[22] Article 7 Report, Form D, 30 April 2004; Article 7 Report, Form D, 19 April 2002. In 2001, 423 mines were transferred from CMAC DU 6 (Siem Reap) to the CMAC Training Center and "used for the training of Mine Detection Dog teams." In 2002, the Ministry of Interior handed over 240 mines for training. In 2003, the CMAC Training Center received 366 antipersonnel mines from various demining units.

## បញ្ហាដែលកើតមានដោយសារគ្រាប់មីន

ប្រទេសកម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេស ដែលទទួលរងគ្រោះធ្ងន់ធ្ងរបំផុតដោយសារគ្រាប់មីន និង យុទ្ធភ័ណ្ឌមិនទាន់ ផ្ទុះនៅក្នុងពិភពលោក ដោយសារតែជំលោះជិត ៣ ទសវត្ស ។ នៅឆ្នាំ ២០០៣ ចំនួន ៩០% នៃជនរងគ្រោះ គឺជាជនស៊ីវិល ។ ឧប្បត្តិហេតុ ដោយគ្រាប់មីនភាគច្រើនកើតឡើងដោយសារសកម្មភាពបង្កបង្កើនផលដើម្បីជីវភាពរស់នៅនៅក្នុងព្រៃ និង វាលស្រែចំការ[23] ។ ការគំរាមកំហែងនៃយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និង គ្រាប់មីន គឺជាឧបសគ្គចំពោះការធ្វើចលនាសន្តិសុខ សកម្មភាពសេដ្ឋកិច្ច និង ការអភិវឌ្ឍន៍ក្នុងខេត្តមួយចំនួន ជាពិសេសខេត្តក្នុងតំបន់ភាគខាងជើង និងភាគពាយ័ព្យនៃប្រទេស ។ នៅក្នុងព្រៃនៃខេត្តបន្ទាយមានជ័យ,បាត់ដំបង, ឧត្តរមានជ័យ និងប៉ៃលិន ដែលជាខេត្តទទួលរងខ្លាំងបំផុតប្រជាពលរដ្ឋនៅតែទទួលរងគ្រោះដាច់អវៈយវៈដោយសារតែពួកគេបានស្វែងរកមធ្យោបាយដើម្បីចិញ្ចឹមគ្រួសារ ។ គ្រាប់មីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ បានរឹតបន្តឹងដល់សិទ្ធិចេញ-ចូលផ្ទះ សំបែងសិទ្ធិប្រើប្រាស់ ដីធ្លីកសិកម្ម ដីធ្លីវាលស្មៅ ប្រភពទឹក ព្រៃឈើ សាលារៀន ទំនប់ទឹក ប្រឡាយទឹក សកម្មភាពពាណិជ្ជកម្ម មណ្ឌលសុខភាព ស្ពាន ថ្នល់ និង ភូមិជិតខាង ។

រហូតដល់ឆ្នាំ២០០០ អង្គការ CMAC បានរាយការណ៍ថាផ្ទៃដីចំនួន៦៦៤គីឡូម៉ែត្រក្រឡាគឺជាដីបង្កប់ដោយគ្រាប់មីន និង ចំនួន ១.៤០០ ម៉ែត្រក្រឡាទៀត គឺជាដីសង្ស័យថាមានគ្រាប់មីន ។ នៅឆ្នាំ ២០០១ អង្គការ CMAC បានរកឃើញផ្ទៃដីមានគ្រាប់មីនចំនួន ២.៩០០ គីឡូម៉ែត្រក្រឡា ។

ប្រតិបត្តិការបោសសំអាតគ្រាប់មីនដែលបានរៀបចំឡើងក្នុងប្រទេសកម្ពុជា ចាប់ផ្តើមនៅឆ្នាំ ១៩៩២ ហើយតាំងពីនោះមកផ្ទៃដីប្រហែល ២៥២ គីឡូម៉ែត្រក្រឡា ត្រូវបានបោសសំអាតគ្រាប់មីនរួច[24] ។ ការបោសសំអាតគ្រាប់មីនដោយជនស៊ីវិល ដែលគេស្គាល់ថាជាការដោះមីននៅតាមភូមិត្រូវបានធ្វើឡើងសំរាប់រយៈពេលវែងឆ្ងាយណាស់ ។ ក្នុងប្រទេសកម្ពុជា គ្រាប់មីនប្រឆាំងមនុស្សដែលបានរកឃើញជាទូទៅភាគច្រើន គឺមានគ្រាប់មីនប្រភេទ PMN, PMN2, PMD-6, MN79, ប្រភេទ 69, DH10, MON 66/50, POMZ-2M, ប្រភេទ 72A និង ប្រភេទ 72B[25] ។

តំបន់ដែលបង្កប់គ្រាប់មីនជាច្រើននៅតែមិនត្រូវបានដាក់សញ្ញាសំគាល់ ឬ ព័ទ្ធរបងនៅឡើយ ។ នៅឆ្នាំ ២០០៣ CMAC បានដាក់សញ្ញាសំគាល់នៅទីវាលមានគ្រាប់មីនចំនួន៦៧៥កន្លែង ក្នុងផ្ទៃដីចំនួន១៣៦.៩៤៧.២២២ ម៉ែត្រក្រឡា[26] ។ ប៉ុន្តែ នៅខែមករា ឆ្នាំ ២០០៤ ចំនួន ៩៨% នៃករណីគ្រោះថ្នាក់ដែលបានរាយការណ៍ប្រចាំខែ (៨៦ ក្នុងចំណោម ៨៨ ករណី) បាននិយាយថា មិនមានសញ្ញា សំគាល់នៅក្នុងទីកន្លែងគ្រោះថ្នាក់នោះឡើយ[27] ។

---

[23] Cambodia Mine/UXO Victim Information System (CMVIS), "Monthly Mine/UXO Report," January 2004.
[24] See details in Mine Clearance section below.
[25] Article 7 Report, Form F, 30 April 2004. Other types found in Cambodia include KN-10, M-62, M14, M16A1, M18A1, MBV-78-A1, MBV-78-A2, MD-82-B, MDH-10, MDH-2, MDH-3, MDH-5, MDH-7, MIN, MN, MODEL, MON, NOMZ2B, OMZ-3, OMZ-4, OMZ-72, P-40 BALL, PMA-2, PMA-3, POMZ-2, PPMI-SR, PPM-2, PSM-1, Type 66; US Department of Defense, Mine Facts CD Rom, version 1.2.
[26] Article 7 Report, Form I, 30 April 2004.
[27] CMVIS, "Monthly Mine/UXO Victim Report: January 2004."

## ការស្រាវជ្រាវនិងការប៉ាន់ប្រមាណ

ការកំណត់អំពីទំហំនៃបញ្ហាគ្រាប់មីននៅក្នុងប្រទេសកម្ពុជានៅតែមានលក្ខណៈពិបាកនៅឡើយ ។ មុនពេលការស្ទាបស្ទង់អំពីឥទ្ធិពលនៃគ្រាប់មីន (LIS) (ដែលគេស្គាល់ផងដែរថាជាការស្ទាបស្ទង់កំរិតទី ១) បានចាប់ផ្តើមនៅឆ្នាំ ២000 មិនមានការស្ទាបស្ទង់តាមប្រព័ន្ធអំពីបញ្ហាគ្រាប់មីននៅក្នុងប្រទេសកម្ពុជាឡើយ ទោះបីជាការស្ទាបស្ទង់តាមលក្ខណៈបច្ចេកទេសតូចតាចមួយចំនួន ត្រូវបានធ្វើឡើងក្នុងសហគមន៏នានាតាមសំណើពីប្រជាពលរដ្ឋក្នុងតំបន់ដែលកំពុងរស់នៅក្នុងតំបន់ដែលសង្ស័យថាមានគ្រាប់មីន និង ទិន្នន័យអំពីដំណោះស្រាយល្អមួយត្រូវបានប្រមូលក្នុងទិន្នន័យរបស់ CMAC ក៏ដោយ ។

ការស្ទាបស្ទង់អំពីឥទ្ធិពលនៃគ្រាប់មីន (LIS) ដែលបានចេញនៅខែ ឧសភា ឆ្នាំ ២00២ បានបង្ហាញអោយឃើញថា តំបន់ចំនួន ៣0៣៧ ត្រូវបានសង្ស័យថាទទួលរងគ្រោះដោយគ្រាប់មីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងគ្រាប់រំសេវ ។ ការស្ទាបស្ទង់នេះបានប៉ាន់ប្រមាណថា ប្រជាពលរដ្ឋចំនួន ៥,១៨ លាននាក់ ក្នុងភូមិចំនួន ៦.៤២២ ស្ថិតក្នុងភាពគ្រោះថ្នាក់ ។ ការស្ទាបស្ទង់បានរកឃើញថា ប្រហែល ១៦៤0ភូមិ ប្រមាណ ១២% នៃភូមិទាំងអស់មានកំរិតគ្រោះថ្នាក់ដោយសារគ្រាប់មីន និង សព្វាវុធមិនទាន់ផ្ទុះខ្ពស់[28] ។ ការស្ទាបស្ទង់នេះ ត្រូវបានធ្វើឡើងដោយ Geospatial International Inc. (GeoSpatial/GST) និងផ្តល់មូលនិធិដោយរដ្ឋាភិបាលកាណាដាចំនួន១,១លានដុល្លាអាមេរិក ។

ការវិភាគអំពីស្ថានភាពបច្ចុប្បន្ននៃការស្ទាបស្ទង់ និង ការគូសផែនទីត្រូវបានបង្ហាញជូនដល់វេទិកាសកម្មភាពមីន (Mine Action Forum) ក្នុងទីក្រុងភ្នំពេញ កាលពីថ្ងៃទី 0៩ ខែ មិនា ឆ្នាំ ២00៤ ។ យោងតាមការវិភាគនេះការស្ទាបស្ទង់អំពីឥទ្ធិពលនៃគ្រាប់មីន មិនបានប្រើប្រាស់របាយការណ៍ស្ទាបស្ទង់តាមបច្ចេកទេស ដែលបានប្រមូលជាបន្តបន្ទាប់ក្នុងរយៈពេលមួយទសវត្សដោយប្រតិបត្តិករសកម្មភាពមីន (Mine Action Operator) ឡើយ ហើយមិនបានបញ្ចូលតំបន់មួយចំនួនដែលការីទាំងនោះបានបង្ហាញត្រឹមត្រូវថាបានទទួលរងគ្រោះនោះដែរ[29] ។

អាជ្ញាធរសកម្មភាពមីនកម្ពុជាបានរាយការណ៍ថា ផែនការជាតិនៃសកម្មភាពមីនសំរាប់ឆ្នាំ ២00៣ ដែលចងក្រងនូវគ្រប់ការបោសសំអាតមីន ដែលរៀបគំរោងដោយភ្នាក់ងារបោសសំអាតមីនចំនួន៤ ដែលកំពុងប្រតិបត្តិការក្នុងប្រទេសកម្ពុជា បានបង្ហាញអោយឃើញថា : ជាង ១៥% នៃផ្ទៃដីដែលត្រូវបោសសំអាតនៅឆ្នាំ ២00៣ មិនត្រូវបានកត់ត្រាទុកក្នុងការស្ទាបស្ទង់ឥទ្ធិពលនៃគ្រាប់មីនឡើយ[30] ។ តំបន់ទាំងនេះស្ថិតនៅទាំងក្នុងភូមិដោយគ្មានឯកសារសំអាងក្នុង LIS (៦,៣ ភាគរយ) និងនៅក្នុងភូមិដែលបានដកស្រង់ថាមិនត្រូវបានរងគ្រោះដោយ LIS (៩,២ ភាគរយ) ។ ការពិនិត្យសង្កេតដូចគ្នានេះ ត្រូវបានធ្វើឡើងសំរាប់គំរោងការងារជាតិឆ្នាំ ២00៤ ដែល ២0% នៃផ្ទៃដីដែលត្រូវបោសសំអាតមិនត្រូវបានកត់ត្រានៅក្នុង LIS ឡើយ គឺ ១១% គ្មានឯកសារសំអាង ក្នុង LIS និង ៩%

[28] Article 7 Report, Form C, 30 April 2004.
[29] Ian Thomas, GIS & Database Specialist, CIDA, "Presentation on CMAA database," at Mine Action Forum meeting, Phnom Penh, 9 March 2004. Thomas is a Technical Advisor for CMAA.
[30] CMAA, "Mine Action: 1992-2003," 29 April 2004, p.8.

មិនបានទទួលរងគ្រោះយោងតាម LIS ។ អាជ្ញាធរសកម្មភាពមីនកម្ពុជា បានបង្កើតឡើងនូវទិន្នន័យសកម្មភាពមីនជាតិ (NMAD) ក្នុងឆ្នាំ ២០០២ ជាការបន្តនូវការស្ទាបស្ទង់អំពីឥទ្ធិពលនៃគ្រាប់មីន។ ទិន្នន័យនោះរួមមានពត៌មានដែលបានទទួល LIS ប្រព័ន្ធពត៌មានអំពីជនរងគ្រោះដោយគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះកម្ពុជា (CIMVIS) កំណត់ត្រាការទំលាក់គ្រាប់បែករបស់កងទ័ពអាកាសអាមេរិក ពីឆ្នាំ ១៩៦៥-១៩៧៣ ការស្ទាបស្ទង់បច្ចេកទេស ផែនទីភូមិសាស្ត្រ និង រូបភាពពីលំហអាកាស និង ផ្កាយរណប ។ នៅខែ កញ្ញា ឆ្នាំ ២០០៣ រដ្ឋាភិបាលកាណាដា បានពង្រីកការឧបត្ថម្ភរយៈពេលវែងរបស់ខ្លួនដល់កម្មវិធីទិន្នន័យសកម្មភាពមីនជាតិ និងបានផ្តល់មូលនិធិជាថ្មី ដល់ឧបករណ៍បុគ្គលិកទិន្នន័យ ៤ រូប និង ជំនាញការ ១ រូប [31] ។

នៅខែ មករា ២០០៤ ក្រុមទិន្នន័យសកម្មភាពមីនជាតិបានបង្កើតឡើងនូវការវាយតំលៃថ្នាក់ជាតិអំពីការទទួលរងគ្រោះរបស់ប្រទេសកម្ពុជា ដែលស្របទៅតាមគំរូទិន្នន័យសកម្មភាពមីនចំបង៧ទាំងអស់ ដែលទទួលបានពីគ្រប់ប្រតិបត្តិករនិងបង្ហាញទិន្នន័យទាំងនោះនៅលើផែនទី ។ កម្មវិធីទិន្នន័យសកម្មភាពមីនជាតិបានបង្កើតការវិភាគអំពីឧប្បត្តិហេតុរងគ្រោះដោយសារគ្រាប់មីនក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយ ហើយបានប្រៀបធៀបការវិភាគនេះជាមួយនឹងគំរោងការងាររបស់ការីបោសសំអាតគ្រាប់មីន ។

ប្រព័ន្ធគ្រប់គ្រងពត៌មានសំរាប់សកម្មភាពមីន (IMSMA) ត្រូវបានតំឡើងនៅជាមួយអាជ្ញាធរមីនក្នុងខែមករា ឆ្នាំ ២០០៣ ។ ការព្រួយបារម្ភអំពីប្រសិទ្ធិភាពនៃប្រព័ន្ធគ្រប់គ្រងពត៌មានសំរាប់សកម្មភាពមីនត្រូវបានលើកឡើងនៅក្នុងវេទិកាសកម្មភាពមីននៅខែ មិនា ឆ្នាំ ២០០៤ ។ អ្នកចូលរួមក្នុងវេទិកានេះម្នាក់ បានរៀបរាប់ថាប្រព័ន្ធគ្រប់គ្រងពត៌មានសំរាប់សកម្មភាពមីន ជាឧបករណ៍ "មិនអាចបត់បែន, ថាមិនបើកចំហរ និង ស្មុគស្មាញខ្លាំងណាស់" ។ គាត់បាននិយាយថា វាបានផ្ទេរភាពជាម្ចាស់ទិន្នន័យចេញពីសារការី ហើយមិនអាចផ្តល់អាទិភាពដោយការបោសសំអាតមីននៅតាមទីវាលបានត្រឹមត្រូវឡើយ។ គាត់បានបញ្ជាក់ថាអង្គការ CMAC និង អង្គការHALO Trust មានទិន្នន័យស្រាប់មួយចំនួនដែលកំពុងក្លាយជាមានលក្ខណៈជឿនលឿនឡើង ហើយថាអង្គការ MAG ដែលមានលក្ខណៈធម្មតាជាងនោះមិនសូវមានលក្ខណៈជឿនលឿនប៉ុន្មានទេប៉ុន្តែមានសុវត្ថិភាពផ្ទុកទិន្នន័យបានត្រឹមត្រូវ [32] ។

អង្គការ CMAC បានប្រមូលពត៌មាននិងរបាយការណ៍អំពីតំបន់ដែលសង្ស័យថាមានគ្រាប់មីនហើយកត់ត្រាតំបន់ទាំងនោះក្នុងទិន្នន័យតាំងពីឆ្នាំ១៩៩២មក ។ ទិន្នន័យរបស់អង្គការ CMAC គ្រប់គ្រងពត៌មានស្តីអំពីការបោសសំអាតមីន ការស្ទាបស្ទង់ ការបោះចោលនូវយុទ្ធភ័ណ្ឌផ្ទុះ ការអប់រំអំពីគ្រោះថ្នាក់គ្រាប់មីន ការត្រួតពិនិត្យអំពីការបោសសំអាតគ្រាប់មីន និង កត្តាសេដ្ឋកិច្ចសង្គមទាំងមុន និងក្រោយការបោសសំអាតគ្រាប់មីន។ ទិន្នន័យនេះបំរើអោយប្រតិបត្តិការរបស់អង្គការ CMAC និងផ្តល់ពត៌មានបន្ថែមផ្តល់ទិន្នន័យជាតិរបស់អាជ្ញាធរមីន [33] ។

---

[31] Ibid, p.18.

[32] Ian Thomas, CIDA, "Presentation on CMAA database," 9 March 2004. This view was echoed to Landmine Monitor by HALO which described IMSMA as being of little use to the established operators who have developed their own more user friendly systems. Email from Richard Boulter, Programme Manager, HALO Cambodia, 2 October 2004.

[33] CMAC, "Six Month Progress Report," November 2003, p. 7.

ត្រឹមខែ កុម្ភៈ ២០០៤ អង្គការ HALO Trust បានបង្កើតទិន្នន័យកុំព្យូទ័រមួយអំពីការងារបោសសំអាតមីនទាំងអស់ដែលបានធ្វើឡើង និង ជិតបញ្ចប់នូវរូបភាពតាមអាកាស ដែលផ្តល់អោយទិន្នន័យនេះនូវសមត្ថភាពទទួលពត៌មានអំពីការបោសសំអាតមីនទៅលើរូបភាពដើម្បីទទួលបាននូវការបង្ហាញជាក់លាក់អំពីការងារដែលបានអនុវត្ត [34] ។

ការស្ទាបស្ទង់វិភាគអំពីគ្រោះថ្នាក់ (CAS) ដែលបង្កើតឡើងដោយប្រព័ន្ធពត៌មានជនរងគ្រោះដោយសារគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ កម្ពុជាត្រូវបានប្រើប្រាស់ដោយភាគីទាំងអស់ដើម្បីជួយផ្តល់អាទិភាពភារកិច្ចដោះមីន ។ CMVIS ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៤ ដោយកាកបាទក្រហមកម្ពុជា និង អង្គការជនពិការអន្តរជាតិ ដើម្បីផ្តល់ការប្រមូលពត៌មានតាមប្រព័ន្ធ និងជាបន្តបន្ទាប់ និង ដើម្បីផ្សព្វផ្សាយពត៌មានស្តីអំពីករណីគ្រោះថ្នាក់ដោយសារគ្រាប់មីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ។ វាចាប់ផ្តើមប្រមូលទិន្នន័យនៅក្នុងខេត្ត ចំនួន ៦ ហើយនៅឆ្នាំ ២០០១ បានពង្រីកទៅដល់ខេត្ត-ក្រុងទាំង ២៤ [35] ។ នៅឆ្នាំ ២០០៣ វាត្រូវបានផ្តល់មូលនិធិដោយប្រទេស Finland និង អង្គការ UNICEF ។

## ផែនការការងារនិងការសំរបសំរួលសកម្មភាពមីន

ប្រទេសកម្ពុជាបានកំណត់គោលដៅឆ្ពោះទៅរកឥទ្ធិពលសូន្យពីគ្រាប់មីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះត្រឹមឆ្នាំ ២០១២ ហើយមាន គំរោងសំរេចផែនការនេះដោយការបោសសំអាតតំបន់ដែលមានគ្រាប់មីនមានឥទ្ធិពលខ្ពស់ និង បង្កើតកម្មវិធីអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីនអោយបានទូលំទូលាយបន្ថែមទៀត ។ ទស្សនៈរយៈពេលយូរនេះគឺដើម្បីជួយប្រទេសកម្ពុជាអោយរួចផុតពីឥទ្ធិពលសេដ្ឋកិច្ចសង្គម និង មនុស្សធម៌ទាំងអស់ដែលរងគ្រោះដោយសារគ្រាប់មីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ [36] ។

យ៉ាងណាក៏ដោយ មាត្រា៥នៃសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីន បានជំរុញអោយប្រទេសកម្ពុជាត្រូវសំរេចអោយបាននូវការបោសសំអាតតំបន់ ដែលមានគ្រាប់មីនទាំងអស់ក្រោមការគ្រប់គ្រងនិងយុត្តាធិការរបស់ខ្លួនត្រឹមខែ មករា ឆ្នាំ ២០១០ គឺ រយៈពេល ១០ ឆ្នាំ បន្ទាប់ពីសន្ធិសញ្ញានេះចូលជាធរមាន ។ ជាងនេះទៀត ប្រទេសកម្ពុជាមិនបានកំណត់ច្បាស់លាស់នូវអ្វីដែលបង្កើតអោយមាន " ឥទ្ធិពលក៏វិតសូន្យ " ឬ អ្វីដែលខ្លួនបញ្ជាក់ទាក់ទងនឹងឧបសគ្គសេដ្ឋកិច្ចសង្គមនាពេលអនាគត និង គ្រោះថ្នាក់ពីគ្រាប់មីនឡើយ ។

រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតអាជ្ញាធរជំនួយជនរងគ្រោះ និង សកម្មភាពមីនកម្ពុជា នៅខែ កញ្ញា ឆ្នាំ ២០០០ អាជ្ញាធរនេះ ទទួលខុសត្រូវលើការសំរបសំរួលគ្រប់សកម្មភាពបោសសំអាតមីនទាំងអស់នៅក្នុងប្រទេសកម្ពុជា។ អាជ្ញាធរបានជួយរាជរដ្ឋាភិបាលក្នុងការបង្កើតគោលនយោបាយនិងគោលការណ៍ត្រួតពិនិត្យសំរាប់គ្រប់គ្រងសកម្មភាពមីន និង ធានាប្រាកដថាកម្មវិធីសកម្មភាពមីនទាំងឡាយ ជាបច្ច័យក្នុងការចូលរួមផ្តល់អាទិភាព និង

---

[34] HALO Trust, “Annual Report 2003, for submission to the CMAA,” February 2004.
[35] CMVIS “Mine and UXO Casualties in Cambodia 2000,” Cambodia 2002.
[36] Implementation Support Unit, “Progress in implementing Article 5: An overview of the mine-affected States Parties’ problems, plans, progress, and priorities for assistance,” Geneva, 21 June 2004.

គោលនយោបាយកាត់បន្ថយភាពក្រីក្រ [37] ។ អាជ្ញាធរនេះត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងតំរូវការចាំបាច់ក្នុងការបែងចែកមុខងារអាជ្ញាធរត្រួតពិនិត្យ និង គ្រប់គ្រងសកម្មភាពមីនពីទីភ្នាក់ងារអនុវត្តសកម្មភាពមីនរបស់រដ្ឋាភិបាល [38] ។

ក្នុងកំឡុងពេល ៦ ខែ ដំបូងនៃឆ្នាំ ២០០៣ អាជ្ញាធរមីនបានរៀបចំយុទ្ធសាស្ត្រជាតិសកម្មភាពមីន និង ផែនការសកម្មភាពមីន រយៈពេល ៥ ឆ្នាំ ២០០៣-២០០៧ (FYMAP) ។ គោលដៅរបស់ FYMAP រាប់បញ្ចូលទាំងការពង្រឹង ការសំរបសំរួលសកម្មភាពមីនជាតិ កំណែរប្រែការគ្រប់គ្រងសេដ្ឋកិច្ចសង្គមអំពីការបោសសំអាតគ្រាប់មីន ការពង្រីកសមិទ្ធផលសកម្មភាពមីន និង ការបង្កើតមធ្យោបាយការពារ និង ថែរក្សាទាក់ទងនឹងការអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីន និងការផ្តល់ជំនួយដល់អ្នកនៅមានជីវិតពីគ្រាប់មីន។ នៅខែ ឧសភា ឆ្នាំ ២០០៣ អាជ្ញាធរមីនបានចេញនូវផែនការការងារជាតិ ដោយបានចងក្រងអំពីផែនការការងារនានារបស់ទីភ្នាក់ងារបោសសំអាតមីន ។

នៅខែតុលា/វិច្ឆិកា ឆ្នាំ ២០០៣ ដោយមានការឧបត្ថម្ភពីកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) និង ការផ្តល់មូលនិធិពីចក្រភពអង់គ្លេស អាជ្ញាធរមីនបានបង្កើតនូវក្រុមគ្រប់គ្រងគុណភាពដើម្បីត្រួតពិនិត្យ និង វាយតំលៃ [39] ។ ដោយផ្អែកលើបទដ្ឋានសកម្មភាពមីនអន្តរជាតិ (IMAS) អាជ្ញាធរមីន បានបញ្ចប់នូវសេចក្តីពង្រាងបទដ្ឋានសកម្មភាពមីនជាតិកម្ពុជា（CMAS）។ បទដ្ឋានសកម្មភាពមីនជាតិកម្ពុជា ត្រូវបានរៀបគំរោងអនុវត្តនូវពាក់កណ្តាលឆ្នាំ ២០០៤ ប៉ុន្តែត្រូវបានរាយការណ៍ថា ត្រូវស្ថិតក្នុងដំណាក់កាលចុងក្រោយនៃការអនុម័តរបស់រដ្ឋាភិបាលនៅចុងខែ កញ្ញា ឆ្នាំ ២០០៤ ។ យោងតាមអង្គការ HALO Trust ប្រតិបត្តិករដឹកនាំនានាបានសំដែងនូវផែនការរៀបគំរោងទុកជាមុនមួយចំនួន ដោយអនុវត្តតាមភាពសមស្របនៃស្តង់ដារដែលបានស្នើឡើងមួយចំនួនដែលមិនឆ្លុះបញ្ចាំងអោយឃើញនូវអ្វីដែលបានបង្ហាញជាភស្តុតាងអំពីប្រតិបត្តិការមួយចំនួនដែលអាចទទួលយកបានក្នុង រយៈពេល ១០ ឆ្នាំចុងក្រោយ[40] ។

ក្នុងកិច្ចប្រជុំថ្មីៗនេះ ទាំងអង្គការ HALO និងអង្គការ MAG បានអំពាវនាវអោយមានការត្រួតពិនិត្យឡើងវិញអំពីបទដ្ឋានបោសសំអាតគ្រាប់មីន ដែលត្រូវអនុម័តសំរាប់តំបន់ដែលទទួលការគំរាមកំហែងតិចតួច និង សំណូមពរអោយមានការសាកល្បងជាមួយឈើបុកស្រូវ និង ឧបករណ៍ដទៃទៀត ដើម្បីស្វែងរកមធ្យោបាយកាត់បន្ថយគ្រោះថ្នាក់អោយមកនៅត្រឹមកំរិតមួយដែលអាចទទួលយកបានដោយគ្មានភាពទ័លច្រក ប្រកបដោយភាពប្រុងប្រយ័ត្ន ហ្មត់ចត់ ដែលនៅតែចាំបាច់សំរាប់តំបន់ដែលមានគ្រាប់មីនច្រើន [41] ។

ផ្អែកនៃដំណើរការរៀបចំគំរោង និង សំរបសំរួល ត្រូវបានរៀបចំធ្វើឡើងតាមរយៈការបង្កើតក្រុមរៀបចំ

---

[37] Response to Landmine Monitor by Dominique Pierre Guéret, CMAA, Phnom Penh, 13 January 2004.

[38] The National Demining Regulatory Authority was established after the 1999 landmines legislation was adopted. It served a coordinating role until CMAA was created. Previously CMAC coordinated mine action activities.

[39] CMAA, “Mine Action: 1992-2003,” 29 April 2004, p. 19.

[40] Email from Richard Boulter, HALO, 2 October 2004.

[41] Ibid.

គំរោងប្រើប្រាស់ដីធ្លី (LUPUs) ។ នៅខែ ឧសភា ឆ្នាំ ១៩៩៩ LUPU និងអនុគណៈកម្មការខេត្តសំរាប់ការប្រើប្រាស់ដីធ្លីក្នុងតំបន់មានគ្រាប់មីន ត្រូវបានបង្កើតឡើងក្នុងខេត្តបាត់ដំបង ដើម្បីសំរួលដល់ការព្រួយបារម្ភអំពីការលៃលកស្មើៗគ្នា និង ភាពជាម្ចាស់នៃដីធ្លីដែលបានបោសសំអាតគ្រាប់មីនរួច ។ ចាប់ពីខែ មិថុនា ឆ្នាំ ២០០១ មក អង្គការជនពិការអន្តរជាតិ (Handicap International) បាននឹងកំពុងផ្តល់ជំនួយហិរញ្ញវត្ថុ និង បច្ចេកទេសដល់ LUPU ក្នុងខេត្តចំនួនពីរ គឺបន្ទាយមានជ័យ និង ឧត្តរមានជ័យ ដោយមានជំនួយហិរញ្ញវត្ថុពីសហគមន៍អឺរ៉ុប និង ផ្តល់ដល់ LUPU ទី ៣ នៅខេត្តព្រះវិហារ ចាប់តាំងពីខែ មេសា ឆ្នាំ ២០០២ ដោយមានការផ្តល់មូលនិធិពីប្រទេសបារាំង។ គោលបំណងនៃក្រុមរៀបចំគំរោងប្រើប្រាស់ដីធ្លីនេះគឺត្រូវកំណត់ (ជាមួយម្ចាស់ភាគហ៊ុនពាក់ព័ន្ធទាំងអស់) នូវតំបន់ដីធ្លីនៅក្នុងខេត្តដែលគួរតែមានអាទិភាពសំរាប់ការបោសសំអាតគ្រាប់មីន នឹងត្រូវដោះស្រាយបញ្ហានៃការបែងចែកដីធ្លី និង ភាពជាម្ចាស់ដីធ្លីជាមុនសិន ។

ការវាយតំលៃអំពីសមិទ្ធិផលទាំងឡាយរបស់ LUPU ដែលបានធ្វើឡើងនៅក្នុងខែ កញ្ញា ឆ្នាំ ២០០៣ បានបង្ហាញអោយឃើញទាំងបញ្ហានិងឱកាសទាំងឡាយ[42] ។ យោងតាមការវាយតំលៃនេះ ដំណើរការធ្វើអត្តសញ្ញាណកម្ម និង ការជ្រើសរើសចំការមីនជារឿយៗនៅតែកំពុងត្រូវបានដឹកនាំដោយការិបោសសំអាតមីន និង អង្គការក្រៅរដ្ឋាភិបាលនានានៅឡើយ ទោះបីជាការទទួលខុសត្រូវសំខាន់ត្រូវបានផ្តល់អោយទៅប្រធានភូមិសំរាប់អត្តសញ្ញាណកម្មភារកិច្ច និង ជ្រើសរើសអ្នកទទួលដីធ្លីក៏ដោយ ។ យ៉ាងណាក៏ដោយ អ្នកភូមិទាំងឡាយមិនសូវត្រូវបានជូនពតិមានអំពីអ្វីដែលកំពុងត្រូវបានធ្វើការសំរេចចិត្តក្នុងនាមពួកគេឡើយ។ ប្រតិបត្តិករដោះមីនមួយចំនួនមានអារម្មណ៏ថា ការងាររបស់ពួកគេកំពុងត្រូវបានធ្វើអោយយឺតយ៉ាវ ដោយសារតែភាពគ្មានបទពិសោធន៍ និង ការប្រតិបត្តិការងាររបស់ LUPU។ ស្ទើរតែគ្រប់ភាគីដែលមានការព្រួយបារម្ភទាំងអស់បានយល់ស្របថា : ជំលោះដីធ្លីត្រូវបានកាត់បន្ថយគួរអោយកត់សំគាល់ ដោយសារតែមានការស៊ើបអង្កេតនៅតាមភូមិជាលំអិត ដែលធ្វើឡើងមុនពេលបោសសំអាតគ្រាប់មីន ។ LUPU ក៏ដើរតួដ៏មានប្រសិទ្ធភាពផងដែរ ក្នុងការនាំយកទីភ្នាក់ងារបោសសំអាតមីនក្នុងការធ្វើការជាមួយគ្នាអោយបានជិតស្និទ្ធ ដើម្បីអោយការបោសសំអាតមីនជាន់គ្នា នៅក្នុងតំបន់តែមួយត្រូវបានកាត់បន្ថយ ឬ លប់បំបាត់ចោល ។ យ៉ាងណាក៏ដោយ ប្រសិនបើជំលោះដីធ្លីដែលបានស្នើឡើងសំរាប់ការបោសសំអាតមីនត្រូវបានរកឃើញមុនការបោសសំអាត ភារកិច្ចនេះជាធម្មតាមិនត្រូវបានបញ្ចូលនៅក្នុងគំរោងផែនការឡើយ ដើម្បីកុំអោយមានជំលោះកើតឡើង ។

អាជ្ញាធរមីនបានរាយការណ៏ថា រហូតដល់ពេលឥឡូវនេះ ដំណើរការ LUPU គឺជាឧបករណ៏សំខាន់ក្នុងការផ្តល់អាទិភាពដល់តំបន់ ដែលមានគ្រាប់មីន ដើម្បីធ្វើការបោសសំអាត ដោយអនុលោមតាមតំរូវការសេដ្ឋកិច្ចសង្គមនៅក្នុងតំបន់ ប៉ុន្តែវាក៏ជាឧបសគ្គមួយផងដែរដូចជា: “គ្មានបទបញ្ញត្តិ/សមាសភាពទូទៅមិនមានជំនួយឧបត្ថម្ភដូចគ្នា ឬ មិនមានមូលនិធិប្រកបដោយនិរន្តរភាព” ។ ជាងនេះទៀត ដំណើរការ LUPU មិនត្រូវបានគិតពិចារណាអំពីការ

[42] Michael F. Bolton, Praivan Limpanboon and Chhim Vanak, “LUPU Project Evaluation,” October 2003.

ទទួលខុសត្រូវរបស់អាជ្ញាធរមីន ឬ របស់ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ដែលបានបង្កើតឡើងនូវយន្តការសំរាប់ដោះស្រាយជំលោះដីធ្លីឡើយ ។ ចាប់ពីខែ វិច្ឆិកា ឆ្នាំ ២០០៣ មក LUPU ចំនួន ៣ បានបាត់បង់ជំនួយមូលនិធិរបស់គេ [43] ។

រវាងខែ សីហា និង ខែ ធ្នូ ឆ្នាំ ២០០៣ អាជ្ញាធរមីន បានពង្រាងអនុក្រិត្យមួយមានចំណងជើងថា៖ "ការគ្រប់គ្រងសេដ្ឋកិច្ចសង្គមនៃប្រតិបត្តិការបោសសំអាតគ្រាប់មីន" ដែលបង្កើតអោយមានគោលការណ៍ថ្មីសំរាប់យន្តការ LUPU/អាជ្ញាធរខេត្ត[44] ។ ក្រោយពីបានពិគ្រោះយោបល់ជាមួយម្ចាស់ភាគហ៊ុនទាំងអស់មកអនុក្រិត្យនេះត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីនៅ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ ។

រៀងរាល់ ៣ ខែម្តង អង្គការក្រៅរដ្ឋាភិបាលនានាដែលពាក់ព័ន្ធនឹងសកម្មភាពមីននៅក្នុងប្រទេសកម្ពុជាបានចូលរួមជាមួយគ្នាក្នុងវេទិកាសកម្មភាពមីន ។ វេទិកាសកម្មភាពមីនមួយត្រូវបានរៀបចំធ្វើឡើងកាលពីថ្ងៃទី ៩ ខែ មិនា ឆ្នាំ ២០០៤ ។

## ការបោសសំអាតគ្រាប់មីន

កំឡុងឆ្នាំ២០០៣ ប្រតិបត្តិករបោសសំអាតគ្រាប់មីនចំនួន ៤ មាន : CMAC, HALO Trust, MAG និង កងយោធពលខេមរភូមិន្ទ/កងវិស្វកម្ម បានបោសសំអាតគ្រាប់មីនលើផ្ទៃដីសរុបចំនួន ៤១,៧៤៦,៥៤១ ម៉ែត្រក្រឡា ដោយបំផ្លាញចោលនូវគ្រាប់មីនប្រឆាំងមនុស្ស ចំនួន ៦០,៦២៦ គ្រាប់, គ្រាប់មីនប្រឆាំងរថក្រោះ ចំនួន ១,០៩៦ គ្រាប់ និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ១១៨,៣០៧ គ្រាប់ ។ នេះគឺជាចំនួនខ្ពស់បំផុតដែលមិនធ្លាប់មាន និង គឺជាចំនួនដែលកើនឡើងគួរអោយកត់សំគាល់ ៧លានម៉ែត្រក្រឡា ឬ ២០% ក្នុងឆ្នាំ២០០២។ ផ្ទៃដីជិត ២៥២ លានម៉ែត្រក្រឡា ត្រូវបានបោសសំអាតចាប់ពីប្រតិបត្តិការនានាបានចាប់ផ្តើមនៅឆ្នាំ ១៩៩២ ហើយជាង ១៤៦ លានម៉ែត្រក្រឡា ក្នុងកំឡុងពេល ៥ ឆ្នាំ ចាប់ពីឆ្នាំ ១៩៩៩ ។

**ការបោសសំអាតគ្រាប់មីនសរុបនៅឆ្នាំ ២០០៣** [45]

| ទីភ្នាក់ងារ | ផ្ទៃដី (ម៉ែត្រក្រឡា) | គ្រាប់មីនប្រឆាំងមនុស្ស | គ្រាប់មីនប្រឆាំងរថក្រោះ | យុទ្ធភណ្ឌមិនទាន់ផ្ទុះ |
|---|---|---|---|---|
| CMAC | 9.708.686 | 22.160 | 503 | 76.642 |
| MAG | 2.682.172 | 4.170 | 62 | 1.873 |
| HALO Trust | 5.007.019 | 8.455 | 224 | 18.698 |
| RCAF | 24.348.664 | 25.841 | 307 | 21.094 |
| សរុប | **41.746.541** | **60.626** | **1.096** | **118.307** |

ចំនួនសរុបនៅក្នុងតារាងនេះ បានមកដោយផ្អែកលើរបាយការណ៍ផ្ទាល់ពីការីបោសសំអាតមីនទាំង៤ ។ របាយការណ៍មាត្រា ៧ ខែ មេសា ឆ្នាំ ២០០៤ របស់ប្រទេសកម្ពុជា មានការខុសប្លែកបន្តិចបន្តួចពីចំនួនរបស់

[43] CMAA, "Mine Action: 1992-2003," 29 April 2004, p. 20.
[44] Ibid, p. 21.
[45] Response to LM Questionnaire by Khun Ratana, Chief Secretariat CMAC, 27 February 2004; MAG, "2003 Report submitted to CMAA," February 2004; HALO Trust, "Annual report 2003 for submission to the CMAA," February 2004; RCAF, "Demining Assignment Task and Development of Nation Society," February 2004.

អង្គការHALO Trust និងអង្គការ MAG ។ របាយការណ៍នេះបានបញ្ជាក់ថា: អង្គការ HALO Trust បានបោសសំអាតផ្ទៃដីចំនួន ៤.៨២ គីឡូម៉ែត្រក្រឡា ហើយអង្គការ MAG បានចំនួន ២.៨០៨ គីឡូម៉ែត្រក្រឡាដោយបំផ្លាញចោលនូវគ្រាប់មីនប្រឆាំងមនុស្សចំនួន ៥.៣៨៧ គ្រាប់ ។ យោងតាមអង្គការ HALO បញ្ជាក់ថា : អាជ្ញាធរមីនខកខានមិនបានបញ្ចូលផ្ទៃដី ដែលបានបោសសំអាតដោយអង្គការ HALO Trust ជាមួយក្រុមបោសសំអាតមេកានិចឡើយ [46] ។

ការបោសសំអាតគ្រាប់មីនមនុស្សធម៌សមស្រប និង ចាប់ផ្តើមនៅឆ្នាំ ១៩៩២ ដែលផ្តួចផ្តើមគំនិតដោយអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិក្នុងប្រទេសកម្ពុជា (UNTAC) ។ ចាប់តាំងពីនោះមកអង្គការ CMAC, អង្គការ HALO Trust, អង្គការ MAG និង ប្រតិបត្តិករបោសសំអាតគ្រាប់មីនដទៃទៀត ដែលមិនពាក់ព័ន្ធក្នុងការបោសសំអាតគ្រាប់មីនតទៅទៀតនៅប្រទេសកម្ពុជា បានបោសសំអាតលើផ្ទៃដីសរុបជិត ២៥២ គីឡូម៉ែត្រក្រឡា [47] ។

**ការបោសសំអាតគ្រាប់មីនសរុបពីឆ្នាំ ១៩៩២ ដល់ ២០០៣** [48]

| ទីភ្នាក់ងារ | ផ្ទៃដី (ម៉ែត្រក្រឡា) | គ្រាប់មីនប្រឆាំងមនុស្ស | គ្រាប់មីនប្រឆាំងរថក្រោះ | យុទ្ធភណ្ឌមិនទាន់ផ្ទុះ |
|---|---|---|---|---|
| CMAC | 112.032.442 | 193.190 | 3.785 | 792.622 |
| MAG | 10.386.135 | 20.864 | 255 | 38.265 |
| HALO Trust | 25.565.563 | 42.307 | 575 | 57.113 |
| RCAF | 84.323.793 | 156.643 | 7.946 | 46.853 |
| ប្រតិបត្តិការពីមុន | 19.290.000 | 5.480 | មិនដឹង | មិនដឹង |
| សរុប | **251.597.933** | **418.484** | **12.561** | **934.853** |

ចំនួនសរុបក្នុងតារាងនេះ បានមកពីអាជ្ញាធរមីន។ យ៉ាងណាក៏ដោយ របាយការណ៍មាត្រា ៧ ខែ មេសា ឆ្នាំ ២០០៤ របស់កម្ពុជាមានការខុសប្លែកគ្នាម្តងទៀតជាមួយនឹងចំនួនរបស់អង្គការ HALO Trust និងអង្គការ MAG។ របាយការណ៍នេះបានបញ្ជាក់ថា: អង្គការ HALO បានបោសសំអាតលើផ្ទៃដីចំនួន ២៥.៤៩ លាន ម៉ែត្រក្រឡា និង បំផ្លាញចោលគ្រាប់មីនចំនួន ៤២.៣៣២ គ្រាប់ រីឯអង្គការ MAG បានចំនួន ១០.៥៩ លាន ម៉ែត្រក្រឡា ហើយបំផ្លាញចោលនូវគ្រាប់មីនចំនួន ១៨.៩៤៩ គ្រាប់ ។

[46] Email from Richard Boulter, HALO, 2 October 2004.
[47] CMAA, "Mine Action: 1992-2003," 29 April 2004, p. 22. Among past operators, Compagnie Française d'Assistance Spécialisée/Compagnie International de Dévelopment cleared 11.88 million square meters, UNTAC cleared 3.47 million square meters, and Norwegian People's Aid cleared 3.94 million square meters before transferring its capacities to CMAC.
[48] Questionnaire Response by CMAC, 27 February 2004; MAG, "2003 Report," February 2004; HALO, "Annual Report 2003," February 2004; RCAF, "Demining Assignment," February 2004.

**ការបោសសំអាតគ្រាប់មីនសរុបពីឆ្នាំ ១៩៩៩ ដល់ ២០០៣** [49]

| ឆ្នាំ | អង្គការ CMAC | អង្គការ MAG | អង្គការ HALO | កងវិស្វ័កម្មខេមរភូមិន្ទ | សរុប |
|---|---|---|---|---|---|
| 1999 | 10.797.705 | 353.242 | 1.990.857 | 2.420.000 ស្មាន | 15.561.804 |
| 2000 | 8.369.635 | 850.252 | 3.000.453 | 20.011.000 | 32.231.340 |
| 2001 | 9.637.455 | 1.400.149 | 4.336.014 | 6.482.357 | 21.855.975 |
| 2002 | 11.582.239 | 1.766.740 | 4.246.011 | 17.118.994 | 34.713.984 |
| 2003 | 9.708.686 | 2.682.172 | 5.007.019 | 24.348.664 | 41.746.541 |
| សរុប | **50.095.720** | **7.052.555** | **18.580.354** | **67.961.015** | **146.109.644** |

បន្ទាប់ពីទទួលបានប្រតិបត្តិការបោសសំអាតគ្រាប់មីន និង ចាប់ដំណើរការនៅឆ្នាំ ១៩៩២ និង ១៩៩៣ មក អត្រាការបោស សំអាតគ្រាប់មីនប្រចាំឆ្នាំស្ថិតនៅចំនួនថេរពីឆ្នាំ ១៩៩៤ ដល់ ១៩៩៩ ជាមធ្យម ១៨,១ លាន ម៉ែត្រក្រឡា ក្នុងមួយឆ្នាំ ។ ចាប់ពីនោះមក ចំនួនសរុបកើនឡើងយ៉ាងខ្លាំងលើកលែងឆ្នាំ ២០០១ ដោយសារ អង្គការ CMAC មានវិបត្តិមូលនិធិ និង ចាត់ចែងខុស ។ ពីឆ្នាំ ២០០០-២០០៣ ផ្ទៃដីជាមធ្យម ៣២,៧ លានម៉ែត្រ ក្រឡា ត្រូវបានបោសសំអាតក្នុងឆ្នាំនិមួយៗ ។

គំរោងផែនការការងារជាតិសំរាប់ឆ្នាំ ២០០៤ ដែលចងក្រងគំរោងការងារពីកាវិសំខាន់ទាំង ៤ កំណត់គោល ដៅត្រូវបោសសំអាត លើផ្ទៃដីចំនួន ២៩.៦៤០.០០០ ម៉ែត្រក្រឡា[50] ។ វត្ថុបំណងសេដ្ឋកិច្ចសង្គមរបស់អង្គការ CMAC, អង្គការ HALO Trust និងអង្គការ MAG គឺត្រូវបោសសំអាតលើផ្ទៃដីចំនួន ១៣.៦៧០.០០០ ម៉ែត្រក្រឡា សំរាប់ការតាំងទីលំនៅជាថ្មី និង វិស័យកសិកម្ម និង ដើម្បីផ្តល់ផលប្រយោជន៍ដល់គ្រួសារប្រមាណ ១៥.០០០ គ្រួសារ ដើម្បីប្រើប្រាស់ដីដែលបានបោសសំអាតមីនដោយផ្ទាល់ និង ជិត ៨៦.០០០ គ្រួសារ សំរាប់ការ ប្រើប្រាស់ដីនេះដោយប្រយោល ។ ការបោសសំអាតគ្រាប់មីន នឹងពាក់ព័ន្ធក្នុងឃុំចំនួន ១១៩ និង ២៣៩ ភូមិ ក្នុងនោះមាន ៨០ ភូមិ នៃចំនួន ១៤៩ ភូមិ ជាឃុំដែលទទួលរងគ្រោះ នេះបើយោងតាមការស្ទាបស្ទង់អំពីឥទ្ធិពល នៃគ្រាប់មីន [51] ។

យោងតាមអាជ្ញាធរមីនចាប់ពីឆ្នាំ ២០០១ មក "ចំនួនផ្ទៃដីសរុបដែលបានបោសសំអាតសំរាប់តាំងលំនៅដ្ឋាន ជាថ្មី កសិកម្ម សង់ផ្ទះសំបែង ឬសំរាប់កន្លែងផ្សេងៗទៀតនោះ សំរាប់កាត់បន្ថយគ្រោះថ្នាក់ មានចំនួនប្រហែល ១.០០០ ហិកតា [១០.០០០.០០០ ម៉ែត្រក្រឡា]" សំរាប់ប្រតិបត្តិករសកម្មភាពមីន ។ មិនអាចផ្តល់តួលេខអំពី ឥទ្ធិពលសេដ្ឋកិច្ចសង្គមបានត្រឹមត្រូវក្នុងឆ្នាំមុនៗ មុនការស្ទាបស្ទង់ឥទ្ធិពលគ្រាប់មីនបានឡើយ[52] ។

---

[49] The 2001 clearance figure for MAG does not match Cambodia's 2002 Article 7 report total of 1,418,813.
[50] CMAA, "Mine Action: 1992-2003," 29 April 2004.
[51] CMAA, "Mine Action: 1992-2003," 29 April 2004, p. 31.
[52] CMAA, "Mine Action: 1992-2003," 29 April 2004, p. 29.

*មជ្ឈមណ្ឌលសកម្មភាពមីនកម្ពុជា (CMAC)*[53]

មជ្ឈមណ្ឌលសកម្មភាពមីនកម្ពុជា ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩២ ហើយទទួលរ៉ាប់រងសកម្មភាពបោសសំអាតមីនពី UNTAC នៅខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។ អង្គការ CMAC គឺជាស្ថាប័នជាតិមួយ ដែលមានតួនាទី និង អណត្តិរបស់ខ្លួន គឺត្រូវអនុវត្តសកម្មភាពបោសសំអាតគ្រាប់មីនមនុស្សធម៌ ។ នៅខែ កុម្ភៈ ឆ្នាំ១៩៩៥ រាជក្រឹត្យមួយបានផ្តល់អំណាចដល់អង្គការ CMAC ដើម្បីសំរបសំរួល និង ប្រតិបត្តិគ្រប់កម្មវិធីសកម្មភាពមីនទាំងអស់ ។ នៅឆ្នាំ ១៩៩៩ អង្គការ CMAC បានប្រឈមមុខនឹងពាក្យចោទប្រកាន់ទាំងឡាយអំពីភាពមិនត្រឹមត្រូវ លើបញ្ហាហិរញ្ញវត្ថុ បក្ខពួកនិយម មានអំពើពុករលួយ និង ការចាត់ចែងខុសគោលការណ៍ ហើយជាលទ្ធផលនៅឆ្នាំ ២000 ការផ្តល់មូលនិធិរបស់ម្ចាស់ជំនួយត្រូវបានផ្អាក ដោយបង្ខំអោយមានការចុះត្រួតពិនិត្យប្រតិបត្តិការនៅតាមទីកន្លែង [54] ។ យុទ្ធសាស្ត្រសំរាប់ការកែទំរង់ និងារស្ថាបនាឡើងវិញ ត្រូវបានបង្កើតឡើង ហើយនៅត្រឹមពាក់កណ្តាលឆ្នាំ ២00១ ស្ថានភាពរបស់អង្គការ CMAC ត្រូវបានធ្វើអោយមានស្ថេរភាពឡើងវិញ ដោយផ្តល់ឱកាសអោយកសាងឡើងវិញនូវសមត្ថភាពដែលមានស្រាប់ ។

នៅឆ្នាំ ២00៣ CMAC បានបោសសំអាត និង ផ្តល់អោយសហគមន៏នូវផ្ទៃដីចំនួនសរុប ៩.៧0៨.៦៨៦ ម៉ែត្រក្រឡា។ អង្គការ CMAC បានបំផ្លាញចោលនូវគ្រាប់មីនប្រឆាំងមនុស្សចំនួន ២២.១៦0គ្រាប់, គ្រាប់មីនប្រឆាំងមនុស្សចំនួន ៥0៣ គ្រាប់ និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ចំនួន ៧៦.៦៤២ គ្រាប់។ ផ្ទៃដីដែលបានបោសសំអាតដោយអង្គការ CMAC ត្រូវបានប្រើប្រាស់សំរាប់ការតាំងទីលំនៅជាថ្មី វិស័យកសិកម្ម ផ្លូវថ្នល់ វត្តអារាម មណ្ឌលសុខភាព អណ្តូងទឹក ស្រះទឹក ការិយាល័យឃុំ ប្រឡាយធារាសាស្ត្រ ដែលមានបណ្តាញផ្លូវថ្នល់ និង សាលារៀន ។ គ្រួសារសរុបចំនួន ២.0១៨ គ្រួសារ បានទទួលផលប្រយោជន៏ដោយផ្ទាល់ ហើយចំនួន ៥៣.២៦៧ គ្រួសារ ត្រូវបានទទួលផលប្រយោជន៏ដោយប្រយោលពីសកម្មភាពអង្គការ CMAC នៅឆ្នាំ ២00៣[55] ។ បន្ថែមលើការបោសសំអាតមីននៅឆ្នាំ២00៣ ក្រុមដាក់ផ្លាកសញ្ញាសំគាល់គ្រាប់មីនរបស់អង្គការ CMAC បានដាក់សញ្ញាសំគាល់ចំការមីនចំនួន ៦៧៥កន្លែង ដែលមានផ្ទៃដីចំនួន ១៣៦.៩៤៧.២២២ ម៉ែត្រក្រឡា ដែលត្រូវបានបោសសំអាត[56] ។

អង្គការ CMAC ប្រើប្រាស់បុគ្គលិកប្រហែល ២៤00 នាក់ ។ ត្រឹមចុងឆ្នាំ ២00៣ ក្រុមសកម្មភាពមីនរបស់អង្គការ CMAC មានកងអនុសេនាតូចធម្មតាចំនួន ២៣ ( ៣0 នាក់ ក្នុងមួយកងអនុសេនាតូច) ,កងអនុសេនាតូចចល័ត ចំនួន ២៤ ( ៣៣ នាក់ ក្នុងមួយកងអនុសេនាតូច), ក្រុម EOD ចំនួន ១៨ ( ៣ នាក់ក្នុងមួយក្រុម), ក្រុមដាក់សញ្ញាសំគាល់គ្រាប់មីន ចំនួន ១៩ ( ៥ នាក់ ក្នុងមួយក្រុម), ក្រុមដាក់សញ្ញាសំគាល់គ្រាប់មីននៅតាមសហគមន៏

[53] Unless otherwise noted, CMAC data is from: Questionnaire Response by CMAC, 27 February 2004.

[54] Other problems identified by the Director General of CMAA included too many technical advisors who did not take responsibilities, the lack of a demining plan at the national level, the fact that CMAC was at the same time an operator and regulator and coordinator, and the limited involvement of the government in mine action. Presentation by Sam Sotha, CMAA, to the Standing Committee of Mine Clearance, Mine Risk Education and Mine Action Technologies, Geneva, 5 February 2003.

[55] Ibid.

[56] Article 7 Report, Form I, 30 April 2004.

ចំនួន ១៤ (៥ នាក់ក្នុងមួយក្រុម), ក្រុមអប់រំចំណេះដឹងអំពីគ្រាប់មីន ចំនួន ៦ ក្រុម (៤ នាក់ ក្នុងមួយក្រុម), ក្រុមទំនាក់ទំនងនៅតាមស្រុក ដើម្បីកាត់បន្ថយគ្រោះថ្នាក់ ដែលមានមូលដ្ឋាននៅសហគមន៍ចំនួន ១៣ ក្រុម (១ នាក់ ក្នុងមួយស្រុក), ក្រុមឆ្កែហិតគ្រាប់មីន ចំនួន ៥ ក្រុម (១៨ នាក់ ក្នុងមួយក្រុម), ក្រុមកាត់ស្មៅ និង គម្លោចព្រៃ ចំនួន ១២ក្រុម (២ នាក់ ក្នុងមួយក្រុម), ក្រុមស្ទាបស្ទង់បច្ចេកទេស ចំនួន ២ ក្រុម (១០ នាក់ ក្នុងមួយក្រុម), ក្រុមកាត់បន្ថយគ្រោះថ្នាក់នៃគ្រាប់មីន ចំនួន ៤ ក្រុម (១៧ នាក់ ក្នុងមួយក្រុម)[57] ។ បុគ្គលិកអង្គការ CMAC ចំនួន ៣៩៥ នាក់ ទទួលរ៉ាប់រងបើកវគ្គបណ្តុះបណ្តាល ស្តីពីលំដាប់សកម្មភាពកំចាត់គ្រាប់មីននៅមជ្ឈមណ្ឌលបណ្តុះបណ្តាលរបស់អង្គការ CMAC ។ មជ្ឈមណ្ឌលនេះក៏មានការសាកល្បង និង វាយតំលៃឧបករណ៍ និង បច្ចេកទេសបោសសំអាតមីនថ្មីៗផងដែរ ។

គំនិតផ្តួចផ្តើមនានា ដើម្បីពង្រីកពេលវេលាឆ្លើយតបទៅនឹងសំណើរបស់សហគមន៍ សំរាប់ការបោសសំអាតគ្រាប់មីន រួមមានការបង្កើតក្រុមកាត់បន្ថយគ្រោះថ្នាក់នៃគ្រាប់មីន (នៅឆ្នាំ២០០២) និង ក្រុមស្ទាបស្ទង់បច្ចេកទេស (នៅឆ្នាំ ២០០៣) និង ការបំលែងកងអនុសេនាតូច រចនាសម្ព័ន្ធតាមការដ្ឋាន ទៅជាកងអនុសេនាតូចចល័ត (នៅឆ្នាំ ២០០៣) ព្រមទាំងការប្រើប្រាស់ម៉ាស៊ីនកាត់ស្មៅ និង គម្លោចព្រៃថ្មីៗ ចំនួន ០៨ គ្រឿង ដែលជាអំណោយរបស់ប្រទេសជប៉ុន[58] ។

អង្គការមូលនិធិជំនួយរបស់ប្រជាជនន័រវេស (NPA) បានបន្តការឧបត្ថម្ភដល់ CMAC ។ នៅឆ្នាំ ២០០៣ NPA បានផ្តល់ទីប្រឹក្សាបច្ចេកទេសម្នាក់ ក្នុងការរៀបចំគំរោង ការធ្វើប្រតិបត្តិការនិងការគ្រប់គ្រងគុណភាព។ មូលនិធិបានផ្តល់ការឧបត្ថម្ភ និង ត្រួតពិនិត្យអង្គការ CMAC កងឯកភាពទី១ (DU1): ហើយក៏បានសំរួលដល់តំរូវការជាក់លាក់នៃសហគមន៍ដែលទទួលរងគ្រោះដោយគ្រាប់មីនក្នុងតំបន់ភាគពាយ័ព្យប្រទេស ដែលទាក់ទងនឹងការកំណត់អាទិភាព និង សិទ្ធិប្រើប្រាស់ដីធ្លី[59] ។

***អង្គការ HALO Trust***[60]

HALO Trust បានចូលមកប្រទេសកម្ពុជានៅឆ្នាំ ១៩៩១ ហើយបានចូលរួមនៅក្នុងការស្ទាបស្ទង់ជាតិដំបូងដែលធ្វើឡើងដោយ UNTAC ។ បន្ទាប់ពីនោះ អង្គការនេះបានចាប់ផ្តើមប្រតិបត្តិការបោសសំអាតគ្រាប់មីននៅខែ មិនា ឆ្នាំ ១៩៩២ ។ ត្រឹមដំណាច់ឆ្នាំ ២០០៣ HALO Trust បានបោសសំអាតផ្ទៃដី ចំនួន ២៩.៥៦៩.៥៦៣ ម៉ែត្រក្រឡា ដែលមាន ៧២% នៃផ្ទៃដីសរុបដែលបានបោស សំអាតរួច រវាងឆ្នាំ ១៩៩៩ ដល់ ២០០៣ ។

នៅឆ្នាំ ២០០៣ HALO Trust បានអនុវត្តសកម្មភាពក្នុងខេត្តចំនួន ៥ និង ផ្អែកបោសសំអាតគ្រាប់មីន

---

[57] These mine action resources were deployed within six Demining Units (DU) namely: DU1 at Bantey Meanchey Province, DU2 at Battambang Province, DU3 at Pailin and Samlot district of Battambang province, DU4 at Kampong Thom, Kampong Cham and Preah Vihear provinces, DU5 at Pursat Province, and DU6 at Siem Reap and Odor Meanchey Provinces. Questionnaire Response by CMAC, 27 February 2004.
[58] CMAC, "Six month progress report," November 2003, pp. 46-47.
[59] Email from Harald Smedsrud, Advisor, NPA, Oslo, 14 June 2004.
[60] Information in this section, unless otherwise noted, is from HALO, "Annual Report 2003," February 2004.

ដោយដៃ ចំនួន ១០១ ដែលប្រតិបត្តិការនៅតាមចំការមីន ក្រុមបោសសំអាតគ្រាប់មីនមេកានិច ចំនួន ១៤, ក្រុមបំផ្លាញចោលយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ចំនួន ២ និង ក្រុមអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីន ចំនួន ១ ។ ជាសរុប ការីបោសសំអាតគ្រាប់មីន បានបោសសំអាតលើផ្ទៃដី ដែលសង្ស័យថាមានគ្រាប់ មីន ចំនួន ៥.០០៧.០១៩ ម៉ែត្រក្រឡា ក្នុងនោះមានគ្រាប់មីនប្រឆាំងមនុស្ស ចំនួន ៨.៤៥៥ គ្រាប់, គ្រាប់មីនប្រឆាំងរថក្រោះ ចំនួន ២២៤ គ្រាប់ និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ចំនួន ១៨.៦៩៨ គ្រាប់ ។ ផ្ទៃដីដែលបានបោសសំអាតដោយ HALO Trust នៅឆ្នាំ ២០០៣ ត្រូវបានប្រើប្រាស់សំរាប់ការតាំងទីលំនៅជាថ្មី (៤៤ ភាគរយ), ផ្លូវថ្នល់ និង គមនាគមន៏ (៣៥ ភាគរយ), វិស័យកសិកម្ម (១២ភាគរយ), សាលារៀន (៦ភាគរយ) និង ប្រើប្រាស់សំរាប់គោលបំណងផ្សេងៗទៀត (៣ភាគរយ) ។

គ្រាប់មីនប្រឆាំងមនុស្សចំនួន ៨.៤៥៥ គ្រាប់ ដែលរកឃើញដោយអ្នកបោសសំអាតមីនដោយដៃនៅឆ្នាំ ២០០៣ គឺជាចំនួនដែល កើនឡើងគួរអោយកត់សំគាល់ ពីចំនួន ៤.៤៨៥ គ្រាប់ នៅឆ្នាំ ២០០២ ។ HALO Trust បានរាយការណ៏ថា ចំនួននេះបានកើតឡើង ដោយសារតែគោលនយោបាយបោសសំអាតមីននៅតាមតំបន់ព្រំដែន ដែលការពារការទន្ទ្រានយកដីពីសកម្មភាពរបស់មនុស្សនៅតំបន់ ខ្សែក្រវ៉ាត់ ក.៥ (K5) ។ ដើម្បីកាត់បន្ថយការិត គ្រោះថ្នាក់នេះ អង្គការ HALO Trust ជឿជាក់ថា ការបោសសំអាតគ្រាប់មីននៅតាមតំបន់ព្រំដែន ដែលមានជនស៊ីវិលធ្វើដំណើរឆ្លងកាត់ គួរធ្វើឡើងជាអាទិភាពដោយយោងតាមអង្គការ HALO Trust ជាងពាក់កណ្តាលនៃគ្រោះថ្នាក់ដោយសារគ្រាប់មីនទាំងអស់នៅក្នុងប្រទេសកម្ពុជា ឥឡូវនេះកើតឡើងនៅតាមតំបន់ព្រំដែនភាគច្រើននៅតំបន់ ក.៥ (K5)[61] ។

នៅដើមឆ្នាំ ២០០៣, HALO បានជួលបុគ្គលិកខ្មែរ ចំនួន ៩៤៣ នាក់ (៨៤៦នាក់ កំពុងប្រតិបត្តិការ ហើយ ៩៧នាក់ ជាបុគ្គលិកជំនួយសកម្មភាព) និង សមាជិកបុគ្គលិកបរទេសចំនួន ៣នាក់ ។ នៅត្រឹមដំណាច់ឆ្នាំនេះ ដោយមានការបង្កើតនូវមូលដ្ឋានប្រតិបត្តិការថ្មីមួយក្នុងស្រុកកំរៀង ខេត្តបាត់ដំបង អង្គការ HALO Trust បានពង្រីកបុគ្គលិកបន្ថែមរហូតដល់ ១.០៧៤ នាក់ (៩៦៩ នាក់ កំពុង ប្រតិបត្តិការ និង ១០៨ នាក់ ជាបុគ្គលិកជំនួយសកម្មភាព) ។

នៅឆ្នាំ ២០០៣ HALO បានដាក់ពង្រាយរថយន្តបោសសំអាតមីន កង់ទំហំមធ្យម (medium wheeled loaders) ចំនួន ០៣ គ្រឿង (ម៉ាក Volvo ០២គ្រឿង, និងម៉ាក Muir Hill ០១ គ្រឿង) ត្រាក់ទ័រ Light Crawler (Fiat Allis) និងត្រាក់ទ័រឈូស Bulldozer D6 ០១គ្រឿង ។ គ្រឿងចក្រទាំងនេះបានបន្តផ្តល់ការគាំទ្រផ្នែកមេកានិចនៅក្នុងតំបន់ទាំងនោះនៅតាមតំបន់ដែលមានគ្រាប់មីន និង សំណល់ដែកខ្ពស់។ ពេញមួយឆ្នាំនេះ HALO Trust បានដាក់ពង្រាយត្រាក់ទ័រកាត់រុក្ខជាតិកាំបិតខាងក្រោយ (rear-mounted) ចំនួន ០៨ គ្រឿង និង ត្រាក់ទ័រកាត់រុក្ខជាតិកាំបិតខាងមុខ (front-mounted) ចំនួន ០២ គ្រឿង ។

[61] Email from Richard Boulter, HALO, 2 October 2004.

HALO បានដាក់ពង្រាយប្រព័ន្ធសំគាល់សញ្ញាគ្រាប់មីនពាក់កណ្តាលអចិន្ត្រៃយ៍ (semi-permanent marking system) ដើម្បីជាការព្រមានអំពីគ្រោះថ្នាក់ដែលចេះតែបន្តនៅតំបន់ក្រៅពីតំបន់ដែលបានបោសសំអាតគ្រាប់មីនរួច។ បង្គោលសំគាល់គ្រាប់មីនធ្វើពីស៊ីម៉ងត៍បេតុង ឥឡូវនេះកំពុងត្រូវបានដាក់នៅចម្ងាយ៥០ម៉ែត្រ ១ដើមតាមបណ្តោយព្រំប្រទល់ផ្ទៃដីដែលបានបោសសំអាតរួច។ ទាំងនេះគឺជាសុច្ចនករ (indicator) នៃការកំណត់ដីធ្លីដែលបានបោសសំអាតរួច ។

*អង្គការ MAG* [62]

អង្គការ MAG ដែលជាអង្គការក្រៅរដ្ឋាភិបាលមានមូលដ្ឋាននៅចក្រភពអង់គ្លេស បានចាប់ផ្តើមប្រតិបត្តិការនៅប្រទេសកម្ពុជាក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៩២ ។ ពីឆ្នាំ ១៩៩២ ដល់ឆ្នាំ ២០០៣ អង្គការ MAG បានបោសសំអាតផ្ទៃដីចំនួន ១០,៣៦ លានម៉ែត្រក្រឡា ។ នៅឆ្នាំ ២០០៣ អង្គការ MAG បានបោសសំអាតផ្ទៃដីចំនួន ២.៦៨២.១៧២ ម៉ែត្រក្រឡា រួមមានគ្រាប់មីនប្រឆាំងមនុស្ស ៤.១៧០ គ្រាប់, គ្រាប់មីនប្រឆាំង រថក្រោះចំនួន ៦២ គ្រាប់ និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ចំនួន ១.៨៧៣ គ្រាប់ ។ បន្ថែមលើនេះអង្គការ MAG បានអនុវត្តភារកិច្ចបំផ្លាញចោលនូវយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (EOD) ចំនួន ៩០៥លើក ដោយបំផ្លាញចោលនូវគ្រាប់មីនចំនួន ៦៣០ គ្រាប់ និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ចំនួន ៣.១៩៥ គ្រាប់ ហើយក្រុមជំនួយបន្ទាន់ (Rapid Response Team) របស់ខ្លួនបានបោសសំអាតលើផ្ទៃដីចំនួន ៣.០៤៧ ម៉ែត្រក្រឡា ក្នុងភារកិច្ចរបស់ខ្លួន ចំនួន ៣៥០ លើក ដោយបំផ្លាញចោលនូវគ្រាប់ចំនួន ៤៨០ គ្រាប់ និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ៣.០៥០ គ្រាប់ ។

ផ្ទៃដីដែលបានបោសសំអាតរួចនៅឆ្នាំ ២០០៣ ត្រូវបានប្រើប្រាស់សំរាប់ការតាំងទីលំនៅជាថ្មីរបស់ប្រជាពលរដ្ឋ ដែលបានផ្លាស់ប្តូរទីលំនៅ កសាងផ្លូវ ប្រឡាយ/បណ្តាញធារាសាស្ត្រ វិស័យកសិកម្ម សាលារៀន មណ្ឌលសុខភាព អណ្តូងទឹក វត្តអារាម ទ្វារទឹក ស្រះទឹក និងស្ពាន។ ការបោសសំអាតនេះបានផ្តល់ផលប្រយោជន៏ដល់ប្រជាពលរដ្ឋចំនួន ១១.៩៩២ គ្រួសារ សរុបប្រជាពលរដ្ឋចំនួន ៣០.៣០៧ នាក់ ។

អង្គការ MAG បានរាយការណ៏ថានៅឆ្នាំ ២០០៣ ផលិតភាពរបស់ខ្លួនក្នុងប្រទេសកម្ពុជាបានកើនឡើងចំនួន ៥២ ភាគរយ បើប្រៀបធៀបនឹងឆ្នាំ ២០០២ ។ អង្គការនេះបានវាយតំលៃអំពីកំណើនផលិតភាពនេះ ជាលទ្ធផលចំពោះបច្ចេកទេសបោសសំអាតមីន ដែលបាននាំមកនូវឧបករណ៏ស្វែងរកគ្រាប់មីនថ្មីៗ និង សកម្មភាពប្រតិបត្តិការងារដែលបានពង្រីក។

នៅឆ្នាំ ២០០៣ អង្គការ MAG បានប្រើប្រាស់បុគ្គលិកជាតិ ចំនួន ៥០០ នាក់ និង បុគ្គលិកអន្តរជាតិ ចំនួន ៣ នាក់ សំរាប់ កម្មវិធីរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ។ បុគ្គលិកទាំងនោះរួមមានបុគ្គលិកដោះមីនស្រី ចំនួន ១០០ នាក់ រាប់ទាំងក្រុមសកម្មភាពមីនស្ត្រី ដំបូងគេ និង បុគ្គលិកដោះមីនជាជនពិការ ប្រហែល ៧០ នាក់ ។ អង្គការនេះបានដាក់ពង្រាយនូវក្រុមសកម្មភាពមីនជំនាញចំរុះ (MATs) ចំនួន ២៣ ក្រុម, ក្រុមបំផ្លាញយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

[62] Unless otherwise noted, MAG data is from: MAG, “2003 Report submitted to CMAA,” February 2004; Email from Tim Carstairs, Director for Policy, Mines Advisory Group, 5 October 2004.

(EOD) ចំនួន ៣ ក្រុម និងក្រុមទំនាក់ទំនងសហគមន៍ (CL) ចំនួន ៧ ក្រុម និង ម៉ាស៊ីន Tempest miniflail ចំនួន ៥ គ្រឿង ។ ក្រុមសកម្មភាពមីនទាំងនោះ ត្រូវបានដាក់ពង្រាយជាអចិន្ត្រៃយ៍ក្នុងខេត្តចំនួន ៤ គឺ: បាត់ដំបង ពោធិសាត់ កំពង់ធំ និង ព្រះវិហារ ។ ក្រុម EOD ត្រូវបានដាក់ពង្រាយដើម្បីធ្វើសកម្មភាពក្នុងខេត្តចំនួន ០៩ ។

អង្គការ MAG បានបង្កើតនូវក្រុមជំនួយបន្ទាន់ (RRT) ក្នុងខេត្តព្រះវិហារ នៅខែធ្នូ ឆ្នាំ ២០០២ ដោយសារតែអត្រាគ្រោះថ្នាក់កើនឡើងខ្ពស់ក្នុងស្រុកជាំក្សាន្ត។ ក្រុមនេះបានធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមទំនាក់ទំនងសហគមន៍ ដើម្បីផ្តល់អាទិភាពដល់តំរូវការរបស់សហគមន៍ ។ អង្គការ MAG បានរាយការណ៍ថា អត្រាគ្រោះថ្នាក់បានធ្លាក់ចុះនៅខេត្តព្រះវិហារ ចំនួន ៤៥% ចាប់តាំងពីការចាប់ផ្តើមរបស់ក្រុម RRT មក ។

អង្គការ MAG បានចាត់ចែងនូវទំនាក់ទំនងសហគមន៍ទូលំទូលាយ និង បណ្តាញប្រមូលទិន្នន័យ ។ ក្រុមទំនាក់ទំនងសហគមន៍បានផ្តល់អោយនូវភាពប្រទាក់ក្រឡារវាងសហគមន៍ដែលរងគ្រោះ និង ចំលើយតបនានាដែលពួកគេមាន ។ ក្រុមទាំងនេះមានទំនាក់ទំនងជាមួយសហគមន៍ពីចាប់ផ្តើមដំបូងរហូតដល់ដំណើរការដោះមីន និង ឈានចូលដល់ការវាស់វែងអំពីផ្នាំដែលទទួលផលប្រយោជន៍បន្ទាប់ពីដំណើរការដោះមីនត្រូវបានបញ្ចប់ ។ ក្រុមទំនាក់ទំនងសហគមន៍ក៏បានផ្តល់អោយអ្នកភូមិផងដែរនូវសេវាកម្មបង្អែក ដែលនៅទីនោះបុគ្គលិកអង្គការ MAG ធ្វើការទំនាក់ទំនងជាមួយអង្គការសកម្មភាពមីនមនុស្សធម៌ខាងក្រៅផ្សេងទៀត ដែលអាចមានលទ្ធភាពជួយដោះស្រាយបញ្ហាជាក់លាក់នានា ។ ទាក់ទងនឹងបញ្ហានេះអង្គការ MAG បានអនុវត្តគោលនយោបាយដៃគូក្នុងការអនុវត្តន៍ និង សកម្មភាពមីន ការសហការណ៍ រួមគ្នាជាមួយនឹងទីភ្នាក់ងារផ្សេងទៀតដូចជា: អង្គការវឌ្ឍនភាព ដែលជាអង្គការអភិវឌ្ឍន៍ក្រៅរដ្ឋាភិបាលក្នុងស្រុក, អង្គការ Church World Service, Lutheran World Service និង World Vision ។

### *កងយោធពលខេមរភូមិន្ទ (RCAF)* [63]

កងយោធពលខេមរភូមិន្ទ បានចាប់ផ្តើមពាក់ព័ន្ធក្នុងសកម្មភាពបោសសំអាតគ្រាប់មីន សំរាប់គោលបំណងមិនមែនយោធា បន្ទាប់ពីការដួលរលំនូវកំលាំងសេសល់របស់ខ្មែរក្រហមចុងក្រោយនៅឆ្នាំ ១៩៩៨ ។ RCAF បានរាយការណ៍ថា នៅឆ្នាំ ២០០៣ ខ្លួនបានបោសសំអាតលើផ្ទៃដីចំនួន ២៤.៣៤៨.៦៦៤ ម៉ែត្រក្រឡា ហើយបានបំផ្លាញចោលនូវគ្រាប់មីនប្រឆាំងមនុស្ស ចំនួន ២៥.៨៤១ គ្រាប់, និងគ្រាប់មីនប្រឆាំងរថក្រោះ ចំនួន ៣០៧ គ្រាប់។ ផ្ទៃដីដែលបានបោសសំអាតរួចត្រូវបានត្រួតពិនិត្យ និង សំអាត ដើម្បីធានាអំពីសុវត្ថិភាពរបស់អ្នកដឹកនាំជាតិ និង អន្តរជាតិ ដើម្បីធ្វើដំណើរទៅទស្សនាទីកន្លែងនោះ (២.២៤០.០០០ម៉ែត្រក្រឡា) ដើម្បីសំរួលការស្ថាបនាយោធភូមិ និង ប៉ុស្តិ៍យាមរបស់កងទ័ព (៣.៦០០០.០០០ ម៉ែត្រក្រឡា) សំរាប់ស្ថាបនាស្ពានថ្នល់ (៧.៦១៦.០៨២ ម៉ែត្រក្រឡា) សំរាប់ការអភិវឌ្ឍន៍ ប្រព័ន្ធជលវិទ្យា (៦.៧៤២.៥៨២ ម៉ែត្រក្រឡា) និង សំរាប់ជាផ្ទៃដីអភិវឌ្ឍន៍ថ្មី

[63] Unless otherwise noted, RCAF data is from RCAF, “Demining Assignment Task and Development of Nation Society,” February 2004, p. 8.

(៤.១៥០.០០០ម៉ែត្រក្រឡា) ។ ពីឆ្នាំ ១៩៩៩ ដល់ ២០០៣ កងយោធពលខេមរភូមិន្ទ បានបោសសំអាតនូវផ្ទៃដី ដែលមានគ្រាប់មីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ចំនួនប្រហែល ៦៨ លានម៉ែត្រក្រឡា ។

កងយោធពលខេមរភូមិន្ទ មានបុគ្គលិកដោះមីនចំនួន ៨៣០ នាក់ ក្នុងនោះ ៦៩១ នាក់ បំរើការក្នុង កងកំលាំងបោសសំអាតមីន និង យុទ្ធភ័ណ្ឌមិន ទាន់ផ្ទុះ, ១២១ នាក់ ជាគ្រូណែនាំ និងជាមន្ត្រីគ្រប់គ្រង និង ១៨ នាក់ ជាបុគ្គលិកបំផ្លាញចោលនូវយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ។

សំរាប់ឆ្នាំ ២០០៤ កងយោធពលខេមរភូមិន្ទ មានគោលបំណងបង្កើតក្រុមជំនាញការ ប្រតិបត្តិការដោះមីន ប្រចាំកងពលរងក្នុងខេត្ត-ក្រុងនិមួយៗ ហើយបានកំណត់នូវគោលដៅបោសសំអាតលើផ្ទៃដីចំនួន ១០ លានម៉ែត្រ ក្រឡា ។ សំរាប់កិច្ចការនេះ ខ្លួនបានដាក់ជូននូវសំណើថវិកាចំនួន ៣ លានដុល្លា ដល់រាជរដ្ឋាភិបាល ។

ការសិក្សាមួយដែលចេញដោយមជ្ឈមណ្ឌលអន្តរជាតិសំរាប់ការដោះមីនមនុស្សធម៌ក្នុងទីក្រុងហ្សឺណែវ នៅ ខែ មិថុនា ឆ្នាំ ២០០៣ បានរាយការណ៍អំពីការព្រួយបារម្ភចំពោះការបោសសំអាតគ្រាប់មីនរបស់កងយោធពល ខេមរភូមិន្ទ ដោយម្ចាស់ជំនួយនានា និង សហគមន៍សកម្មភាពមីនស៊ីវិលនៅក្នុងប្រទេសកម្ពុជា [64] ។ ក្នុងចំណោម ការព្រួយបារម្ភទាំងនោះរួមមាន:(១) កងយោធពលខេមរភូមិន្ទបានរាយការណ៍អំពីអត្រាបោសសំអាតគ្រាប់មីនខ្ពស់ និង អះអាងអំពីកំរិតគ្រោះថ្នាក់សូន្យ ក្នុងកំឡុងពេលបោសសំអាតគ្រាប់មីននោះ ត្រូវបានចាត់ទុកថាមិនអាច គួរអោយជឿជាក់បាន (២) កងយោធពលខេមរភូមិន្ទ បានរៀបរាប់អំពីសកម្មភាពការងាររបស់ខ្លួនថា ជាការងារ មនុស្សធម៌ ប៉ុន្តែពាក់ព័ន្ធទៅនឹងសកម្មភាពបោសសំអាតសំរាប់ផ្លូវថ្នល់និងការស្ថាបនានានាដើម្បីឆ្លើយតបដល់សេចក្តី ណែនាំរបស់រដ្ឋាភិបាលនិងក្នុងគោលបំណងពាណិជ្ជកម្ម និង (៣) កង្វះខាតតម្លាភាពនិងការទទួលខុសត្រូវ [65] ។ ការសិក្សានេះក៏បានបញ្ជាក់ផងដែរថា រដ្ឋាភិបាលបានរាយការណ៍ថា កងកំលាំងប្រដាប់អាវុធនឹងដើរតួសំខាន់បន្ថែម ទៀតក្នុងសកម្មភាពបោសសំអាតគ្រាប់មីននាពេលអនាគត ហើយថាសមត្ថភាពរបស់កងយោធពលខេមរភូមិន្ទ ចាំបាច់ត្រូវតែពង្រីក ។

### *ការបោសសំអាតគ្រាប់មីនរបស់អ្នកភូមិ*

ការបោសសំអាតមីនដោយអ្នកភូមិ ក្រៅពីកម្មវិធីបោសសំអាតមីនមនុស្សធម៌ ដែលត្រូវបានអនុម័តឡើង នៅតែបន្តទោះបីជាសកម្មភាពនេះមិនត្រូវបានអនុញ្ញាតជាផ្លូវការក៏ដោយ ។ អ្នកភូមិមួយចំនួនបោសសំអាតដីធ្លី សំរាប់ធ្វើកសិកម្ម និង ដើម្បីធានាអំពីសន្តិសុខ សេដ្ឋកិច្ច និង រាងកាយរបស់គ្រួសារគេ [66] ។ អ្នកដទៃទៀតជួលអ្នក ដោះមីននៅតាមភូមិដើម្បីបោសសំអាតដីអោយពួកគេ [67] ។ អ្នកស្រាវជ្រាវត្រួតពិនិត្យគ្រាប់មីនបានជួបអតីតសមាជិក ទីភ្នាក់ងារបោសសំអាតមីនជាច្រើននាក់ ដែលឥឡូវនេះពាក់ព័ន្ធនឹងសកម្មភាពបោសសំអាតគ្រាប់មីននៅតាមភូមិ ។

---

[64] GICHD, “The Role of the Military in Mine Action,” 2003.

[65] Donors also cited allegations that senior military figures have taken cleared land and that some roads have been built or exploited by RCAF engineers for lucrative and illegal logging.

[66] For a more detailed description see *Landmine Monitor Report 2001*, p. 446.

[67] The price for clearance in Battambang district is $250 per hectare (10,000 square meters) in 2003, an increase from $100 per hectare in previous years. Interview with a villager in Battambang, April 2004.

សកម្មភាពបោសសំអាតមីននៅតាមភូមិ បានកើតឡើងក្នុងកំរិតមួយខ្ពស់ទូទាំងប្រទេសកម្ពុជាក្រោយពីការមកដល់នៃអង្គការសកម្មភាពមីននានា ។ អង្គការ CMAC បានរាយការណ៍ថា ពីឆ្នាំ ១៩៩៣ ដល់ ១៩៩៩ អ្នកភូមិបានបោសសំអាតលើផ្ទៃដីចំនួន ៦៩.៧៨០.០០០ម៉ែត្រក្រឡា ច្រើនជាងការីដោះមីនអាជីពនៅពេលនោះ [68] ។

ការជជែកវែកញែកអំពីរបៀបដើម្បីសំរួលសកម្មភាពដោះមីនដោយអ្នកភូមិ បានបន្តចាប់តាំងពីដើមទសវត្សឆ្នាំ១៩៩០ ហើយនៅតែមិនអាចដោះស្រាយបាន។ យោងតាមការសិក្សាមួយដែលផ្សព្វផ្សាយដោយវិទ្យាស្ថាន International Peace Research (PRIO), អង្គការ Handicap International និង អង្គការ UNICEF [69] នៅខែ កញ្ញា ឆ្នាំ ២០០៣ ហេតុផលមួយក្នុងចំណោមហេតុផលចម្បង៧ទាំងឡាយ តើហេតុអ្វីបានជាការដោះមីននៅតាមភូមិនៅតែមានក្នុងប្រទេសកម្ពុជាគឺៈ "ផ្នែកសកម្មភាពមីនជាធម្មតាមិនបានបំពេញតំរូវការចេញ-ចូលលើដីធ្លីរបស់ប្រជាពលរដ្ឋ ហើយនិងប្រភពធនធាននានាក្នុងតំបន់ដែលរងគ្រោះដោយគ្រាប់មីនឡើយ។ សំរាប់អ្នកភូមិជាច្រើនការប្រថុយប្រថានមិនអាចផ្តល់អោយគ្រួសាររបស់គេធំជាងការប្រថុយប្រថានដោះមីនដោយខ្លួនគេ និង កាត់បន្ថយផ្ទៃដី ដែលរងគ្រោះដោយសារមីនមកនៅត្រឹមកំរិតមួយដែលអាចលើកលែងបាន" ។ ផ្នែកសកម្មភាពមីនត្រូវបានមើលឃើញថាកំពុងផ្តល់សេវាកម្មដែលមានគុណភាពខ្ពស់មួយ ប៉ុន្តែសំរាប់ចំនួនកំណត់នៃអ្នកទទួលបានផលប្រយោជន៏ខណៈពេលដែលភាគច្រើននៃសហគមន៏ ដែលទទួលរងគ្រោះបន្តដោះស្រាយតែម្នាក់ឯងចំពោះបញ្ហាបរិស្ថានដែលរងគ្រោះដោយគ្រាប់មីនរបស់គេ ។ ការសិក្សានោះ សំណូមពរអោយសហគមន៏សកម្មភាពមីន គួរតែ ថ្លឹងថ្លែងផ្តោតអារម្មណ៏លើការបំបាត់ចោលនូវគ្រោះថ្នាក់ដោយគ្រាប់មីនជាដាច់ខាតដោយមានយុទ្ធសាស្រ្ត ដែលសំរួលអោយមានដីធ្លី និង ប្រភពធនធានច្រើនថែមទៀតត្រូវបានបោសសំអាត និង ផ្តល់អោយអ្នកភូមិដើម្បីកាត់បន្ថយនូវភាពចាំបាច់របស់គេដែលត្រូវចូលទៅតំបន់ដែលមានគ្រោះថ្នាក់ខ្ពស់ ។

ការសិក្សានោះបានបញ្ជាក់ថា "អ្នកដោះមីននៅតាមភូមិក្នុងប្រទេសកម្ពុជាបានបង្ហាញអោយឃើញថាៈ មានលទ្ធភាពកំរិតតំបន់ដែលកំពុងត្រូវបានប្រើប្រាស់ដោយប្រជាពលរដ្ឋនៅត្រឹមកំរិតភូមិ ដើម្បីដោះស្រាយនឹងបញ្ហាបរិស្ថានដែលពួកគេរស់នៅ។ លទ្ធភាពទាំង នេះមិនគួរត្រូវបានធ្វើមិនដឹងមិនឮឡើយ ព្រោះពួកគេនិយាយជំទាស់ចំពោះការនិយាយដោះសារដ៏លើសលប់អំពីសកម្មភាពមីន" ។ ជំនួសមកវិញ ពួកគេគួរដើរតួជាអ្នកផ្តល់ពតិមានដល់ការីសកម្មភាពមីន អំពីចំណុចខ្លាំង និង ចំណុចខ្សោយរបស់សហគមន៏ ដែលជាអ្នកទទួលផល និង អំពីចំណុចខ្លាំង និង ចំណុចខ្សោយនៃអន្តរាគមន៏ដោយខ្លួនឯងនេះ" ។

នៅខែ តុលា ឆ្នាំ ២០០៣ អង្គការ MAG និង អាជ្ញាធរក្នុងតំបន់ បានចាប់ផ្តើមគំរោងនាំមុខមួយ ក្នុងស្រុកកំរៀង និង ស្រុកភ្នំព្រឹក្ស ខេត្តបាត់ដំបង ដែលមានគោលដៅបណ្តុះបណ្តាលប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៏ដែលរងគ្រោះដោយគ្រាប់មីនអោយក្លាយជាអ្នកបោសសំអាតមីន ។ ប្រជាពលរដ្ឋចំនួន ៤០នាក់ ត្រូវបានបណ្តុះ

[68] See *Landmine Monitor Report 2000*, p. 389.
[69] Ruth Botomley, *Crossing the Divide, Landmines, Villagers and Organisation*, (Oslo: International Peace Research Institute, 2003), p.130.

បណ្តាលពីខែ មករា ដល់ខែ សីហា ឆ្នាំ ២០០៤ ក្នុងគំរោងមួយដែលអនុវត្ត ដោយមានកិច្ចសហប្រតិបត្តិការជាមួយអង្គការ Lutheran World Federation[70] ។ អង្គការ MAG បានបញ្ចប់ការសាកល្បងគោលការណ៍ថ្មីនេះ ដោយដាក់ឈ្មោះថា "ក្រុមបោសសំអាតគ្រាប់មីនក្នុងតំបន់" ។ លទ្ធផលនៃការសាកល្បងទាំងនេះ នឹងត្រូវបានចេញនៅចុងឆ្នាំ ២០០៤[71] ។

នៅពេលដែលការបោសសំអាតគ្រាប់មីននៅតាមភូមិត្រូវបានពិភាក្សាដោយវេទិកាសកម្មភាពមីន នៅថ្ងៃទី ០៩ មិនា ២០០៤ អង្គការ HALO Trust បានបញ្ជាក់ថា ខ្លួនបានរកឃើញនូវភស្តុតាងតិចតួចណាស់អំពីការបោសសំអាតមីននៅតាមភូមិក្នុងតំបន់ដែល HALO Trust ស្នើសុំបោសសំអាត ប៉ុន្តែវាទំនងជាមានការរីករាលដាលបន្ថែមទៀតក្នុងតំបន់ដែលទំនងជាមិនដែលបានត្រូវបោសសំអាតដោយប្រតិបត្តិករដោះមីន ជាតំបន់ដែលមានការគំរាមកំហែងទាបបំផុតរបស់គេ [72] ។

## ការអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីន

អង្គការនានាដែលកំពុងធ្វើការក្នុងវិស័យអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីន (MRE) ក្នុងប្រទេសកម្ពុជា រួមមានអង្គការ CMAC, កាកបាទក្រហមកម្ពុជា, អង្គការ HALO Trust, អង្គការ Handicap International, ក្រសួងអប់រំ យុវជន និង កីឡា, អង្គការ MAG, អង្គការ UNICEF, អង្គការ World Education និង អង្គការ World Vision ។ យោងតាមអង្គការ UNICEF នៅឆ្នាំ ២០០៣ អង្គការទាំងនេះបានផ្តល់ការអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីនដល់ប្រជាពលរដ្ឋយ៉ាងហោចណាស់ ៦០០.០០០ នាក់[73] ។ ស្ថិតិដែលបានផ្តល់ដល់អ្នកត្រួតពិនិត្យគ្រាប់មីន បានបង្ហាញអោយឃើញនូវប្រជាពលរដ្ឋចំនួនប្រហែល ៣៥០.០០០នាក់ ដែលជាអ្នកទទួលបានការអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីន ។ រវាងឆ្នាំ ១៩៩៩ និង ឆ្នាំ ២០០២ ប្រជាពលរដ្ឋចំនួនប្រហែល ២.១ លាននាក់ បានចូលរួមក្នុងការអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីន ។

ក្នុងកំឡុងពេលពីឆ្នាំ ១៩៩៤ ដល់ឆ្នាំ ១៩៩៨ អង្គការ CMAC ដែលទទួលខុសត្រូវលើការសំរបសំរួលការអប់រំអំពីគ្រោះថ្នាក់គ្រាប់មីន បានរាយការណ៍ថា ប្រជាពលរដ្ឋចំនួន ១.១លាននាក់ បានទទួលការអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីនពីអង្គការសំខាន់បី គឺ CMAC, MAG និង World Vision[74] ។ នៅឆ្នាំ ១៩៩៩ CMAC, MAG និង World Vision បានផ្តល់ការអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីន ដល់ប្រជាពលរដ្ឋចំនួន ៤៩៧.១៩៨ នាក់ ។ នៅឆ្នាំ២០០០,CMACបានផ្តល់ការអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីនដល់ប្រជាពលរដ្ឋចំនួន៦២៧.២៤៤នាក់ ។ នៅឆ្នាំ២០០១ អង្គការ World Vision បានផ្តល់ការអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីនដល់ប្រជាពលរដ្ឋចំនួន៦.៣៦៧ នាក់ ហើយអង្គការ World Education បានបណ្តុះបណ្តាលគ្រូជាង២.០០០នាក់ អោយប្រើប្រាស់ការអប់រំអំពី

[70] MAG, "2003 Report," February 2004, p. 8.
[71] Email from Tim Carstairs, MAG, 5 October 2004.
[72] Email from Richard Boulter, HALO, 2 October 2004.
[73] Email from Plong Chhaya, Assistant Project Officer, UNICEF Phnom Penh, 28 July 2004.
[74] CMAC, "Socio Economic Unit Report," December 1998.

គ្រោះថ្នាក់នៃគ្រាប់មីននេះក្នុងកម្មវិធីសិក្សាតាមសាលារៀន បន្ទាប់មកបានផ្តល់ការអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីននេះដល់ក្មេងៗ សិស្សានុសិស្សនៅសាលាបឋមសិក្សាជាង ៩០.០០០ នាក់ និងក្មេងៗនៅក្រៅសាលារៀន ចំនួន ២០.០០០នាក់ ។ អង្គការ CMAC មិនបានអនុវត្តសកម្មភាពអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីននេះនៅឆ្នាំ ២០០១ ទេ ដោយសារបញ្ហាហិរញ្ញវត្ថុ[75] ។ នៅឆ្នាំ២០០២ ការអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីនត្រូវបានផ្តល់អោយដល់ប្រជាពលរដ្ឋចំនួនជាង ២២៤.៩៥៧ នាក់ ដោយអង្គការ CMAC, កាកបាទក្រហមកម្ពុជា, HALO Trust, World Education និងអង្គការ World Vision ។ ជាងនេះទៀត ពួកគេបានបណ្តុះបណ្តាលគ្រូអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីន ចំនួន ២.៤៤០ នាក់ រាប់ទាំងគ្រូបង្រៀនតំណាងសហគមន៍ និង អ្នកស្ម័គ្រចិត្ត[76] ។

អាជ្ញាធរមីនបានរៀបចំសិក្ខាសាលាជាតិមួយស្តីអំពី "ការអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ក្នុងប្រទេសកម្ពុជា : ដំណើរឆ្ពោះទៅមុខ" នៅក្នុងខេត្តបាត់ដំបង កាលពីថ្ងៃទី ១២ មិថុនា ២០០៣ ។ អនុសាសន៍សំរាប់ការការពារគ្រោះថ្នាក់ដោយគ្រាប់មីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះក្នុងប្រទេសកម្ពុជារួមមាន : ការយកចិត្តទុកដាក់បន្ថែមទៀតចំពោះចំណេះដឹងនៃគ្រោះថ្នាក់ ដែលបង្កដោយយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ការហាមប្រាមដ៏មុឹងម៉ាត់អំពីការរកស៊ីជួញដូរយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ការពង្រឹងអនុវត្តច្បាប់ហាមប្រាមការប្រើប្រាស់គ្រាប់មីន និងច្បាប់ពាក់ព័ន្ធដទៃទៀត ការពង្រីកការបោសសំអាតគ្រាប់មីនដោយក្រុមចល័តតូចៗ ដើម្បីឆ្លើយតបដល់តំរូវការជាបន្ទាន់ ការពាក់ព័ន្ធបន្ថែមទៀតរបស់អ្នកដឹកនាំសហគមន៍ក្នុងគំរោងចំណេះដឹងអំពីគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងឱកាសផ្តល់ការងារបន្ថែមទៀតដល់ក្រុមដែលងាយទទួលរងគ្រោះដែលកំពុងរស់នៅតំបន់គ្រោះថ្នាក់ ដើម្បីអោយពួកគេមិនប្រថុយចូលទៅតំបន់ ដែលមានមីន ឬ យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ[77] ។

បន្ទាប់ពីសិក្ខាសាលានេះ អង្គការ UNICEF បានយល់ព្រមផ្តល់មូលនិធិដល់អ្នកសំរបសំរួលការអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីន ដែលធ្វើការពេញម៉ោងក្នុងអាជ្ញាធរមីន ដើម្បីពង្រឹងទំនាក់ទំនងរវាងអង្គការសកម្មភាពមីន និង រដ្ឋាភិបាល[78] ។

នៅឆ្នាំ ២០០៣ គ្រូបង្រៀន ចំនួន ៤.២០៤ នាក់ មកពីក្រសួងអប់រំ យុវជន និង កីឡា បានផ្តល់ការអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីនដល់ក្មេងៗសិស្សសាលាបឋមសិក្សា ចំនួន ២៦៥.៣០០ នាក់ ។ បន្ថែមលើនេះ សិស្សដែលទទួលបានការអប់រំនេះចំនួន ៤.២០២ នាក់ បានផ្តល់ការអប់រំបន្តដល់ក្មេងៗក្រៅសាលារៀន ចំនួន ៤១.៩២៣នាក់ ។ សកម្មភាពទាំងនេះត្រូវបានអនុវត្តក្នុងស្រុក ចំនួន ៣០ ដែលរងគ្រោះខ្លាំងបំផុត ។ នាយកសាលាចំនួន ២០៦ នាក់ បានទទួលការបណ្តុះបណ្តាល និង ធ្វើដំណើរទស្សនកិច្ចត្រួតពិនិត្យ ចំនួន ១៦៧ លើក[79] ។

---

75 See *Landmine Monitor Report 2002*, pp. 145-146.

76 See *Landmine Monitor Report 2003*, pp. 143-144. Statistics for HALO Trust and World Vision in 2002 are not available.

77 CMAA, "Mine Action: 1992-2003," 29 April 2004, p. 32.

78 Ibid; email from Sam Sotha, CMAA, 15 January 2004.

79 Email from Plong Chhaya, UNICEF, 28 July 2004.

នៅឆ្នាំ ២០០៣ អង្គការ CMAC បានអនុវត្តសកម្មភាពអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីន តាមរយៈយុទ្ធនាការឃោសនាទូលំទូលាយ (Mass Media Campaign), ក្រុមចំណេះដឹងគ្រាប់មីនចល័ត, ក្រុមអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីន (MRT) និង ក្រុមកាត់បន្ថយគ្រោះថ្នាក់នៃគ្រាប់មីនដែលមានមូលដ្ឋាននៅតាមសហគមន៍ក្នុងស្រុកដែលពាក់ព័ន្ធ[80] ។ យុទ្ធនាការឃោសនាទូលំទូលាយនេះ រួមមាន ការផ្សព្វផ្សាយឃុតឆាកតាមទូរទស្សន៍ជាតិ ចំនួន ៤៤៩ លើក និង តាមវិទ្យុជាតិ ចំនួន ១.២០០ លើក ការលើកតំឡើងប៉ាណូផ្សព្វផ្សាយថ្មីៗចំនួន ២៥ ក្នុងតំបន់ដែលមានអត្រាគ្រោះថ្នាក់ខ្ពស់ ដូចជាក្រុងប៉ៃលិន ការផលិតកាសែតវីដេអូ និង Audio និងការស្ទាបស្ទង់នៅតាមតំបន់អំពីឥទ្ធិពលនៃប៉ាណូផ្សព្វផ្សាយ និង ឃុតឆាកដែលបានផ្សាយតាមទូរទស្សន៍ និង វិទ្យុ [81] ។ ក្រៅពីផ្តល់ការបណ្តុះបណ្តាលអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីនដល់សហគមន៍ដែលរងគ្រោះ ក្រុមអប់រំពីគ្រោះថ្នាក់មីនចល័តបានធ្វើការវាយតំលៃជាមូលដ្ឋាន អំពីតំរូវការរបស់ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងតំបន់រងគ្រោះក្នុងគោលបំណងសំរួលដល់ការបង្កើនយុទ្ធសាស្ត្រប្រសើរជាងមុននៅពេលអនាគត ។

នៅឆ្នាំ២០០៣ ក្រុមអប់រំគ្រោះថ្នាក់មីនចល័ត បានធ្វើទស្សនកិច្ចនៅតាមភូមិចំនួន ៧៦២ភូមិ (៩៥ ភាគរយនៃគំរោងផែនការសកម្មភាពទាំងអស់) ហើយបានជួបសមាជិកគ្រួសារចំនួន ៩៥.៣៦៤នាក់ ដោយផ្តល់នូវវគ្គសិក្សា ចំនួន ៧០៦ នាក់ មានចំនួនអ្នកទទួលផលប្រយោជន៍សរុបពីបទបង្ហាញចំណេះដឹងអំពីគ្រាប់មីននេះចំនួន ១៣៧.៦០៣ នាក់ ប្រុស ៣២.៣៥៣ នាក់, ស្រី ៣៥.២៦០ នាក់ និង ក្មេងៗចំនួន ៧៥.១២២ នាក់ [82] ។

អង្គការ CMAC បានរាយការណ៍ថាក្នុងកំឡុងពីឆ្នាំ ១៩៩៤ ដល់ខែ កុម្ភៈ ២០០៤ ក្រុមចំណេះដឹងគ្រាប់មីនចល័តបានធ្វើទស្សនកិច្ចនៅតាមភូមិចំនួន ៨.១១៩ ភូមិ ហើយបានជួបប្រជាពលរដ្ឋ ចំនួន ១.៨០១.៦១៨ នាក់ ។ ជាលទ្ធផលគ្រាប់មីនប្រឆាំងមនុស្សចំនួន ៨.៩៩០ គ្រាប់ និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ចំនួន ៣០.៩៧១ គ្រាប់ ត្រូវបានរាយការណ៍អោយ អង្គការ CMAC ដើម្បីបោសសំអាត [83] ។

ដោយបានចាប់ផ្តើមនៅខែ វិច្ឆិកា ២០០២ ដោយ HI និង CMAC ក្រុមកាត់បន្ថយគ្រោះថ្នាក់នៃគ្រាប់មីនមានគោលដៅការពារឧប្បត្តិហេតុដោយគ្រាប់មីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ តាមរយៈការបណ្តុះបណ្តាលអំពីជំនាញចំរុះរាប់បញ្ចូលទាំងការបោសសំអាត កំណត់ការដាក់សញ្ញាសំគាល់រយៈពេលវែង ការបំផ្លាញចោលយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ការអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីន និង ទំនាក់ទំនង សហគមន៍ ។ ក្រុមនិមួយៗមានគ្នា ១៧ នាក់ [84] ។ នៅឆ្នាំ ២០០៣ ការអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីនតាមប្រព័ន្ធ ត្រូវបានធ្វើឡើងនៅក្នុងការវាយតំលៃតាមភូមិរបស់ក្រុមកាត់បន្ថយគ្រោះថ្នាក់គ្រាប់មីន ហើយជាមធ្យមប្រជាពលរដ្ឋ ២ នាក់ ក្នុងគ្រួសារនិមួយៗ ត្រូវបានផ្តល់

[80] Questionnaire Response by CMAC, 27 February 2004.

[81] Information provided by CMAC to the CCBL and emailed to Landmine Monitor by Ny Nhar, CCBL, 26 August 2004; email from Plong Chhaya, UNICEF, 28 July 2004; CMAC, ‘‘Six month progress report,’’ November 2003. p. 4.

[82] Information provided by CMAC, 26 August 2004; CMAC, “Annual Report 2003,” p. 13.

[83] Presentation by CMAC, “Mine/UXO Risk Education Components,” at Humanitarian Mine/UXO Clearance Technologies and Cooperation Workshop, Kunming, China, 26 – 28 April 2004.

[84] Presentation by Tang Sun Hao, MRT Field Project Manager, HI, January 2004.

អោយនូវការអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីន[85] ។ រវាងខែ មករា និង វិច្ឆិកា ២០០៣ ក្រុមកាត់បន្ថយគ្រោះថ្នាក់បានផ្តល់ការអប់រំ អំពីគ្រោះថ្នាក់នៃគ្រាប់មីនដល់ប្រជាពលរដ្ឋសរុប ចំនួន ១២.៩៨២ នាក់ ។

កម្មវិធីអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីន ដែលមានមូលដ្ឋាននៅតាមសហគមន៍បានចាប់ផ្តើមជាគំរោងសាកល្បងមួយក្នុងខែ តុលា ២០០១ ហើយទទួលបានជំនួយពី HI និង UNICEF ។ នៅឆ្នាំ ២០០៣ កម្មវិធីកាត់បន្ថយគ្រោះថ្នាក់នៃគ្រាប់មីនដែលមានមូលដ្ឋាននៅតាមសហគមន៍ (CBMRR) ត្រូវបានពង្រីកទៅក្នុងស្រុកគោលដៅដែលទទួលរងគ្រោះខ្ពស់ថ្មីៗ ចំនួន ៧ ក្នុងខេត្តបាត់ដំបង និង ក្នុងស្រុកចំនួន ៤ ក្នុងខេត្តបន្ទាយមានជ័យ [86] ។ នៅឆ្នាំ ២០០៣ គណៈកម្មាធិការគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះក្នុងតំបន់ចំនួន ៣០៤ បានទទួលការបណ្តុះបណ្តាលក្នុងការអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីន ការកំណត់ផែនទីនៅក្នុងភូមិ និងការផ្តល់អាទិភាព ភារកិច្ចសកម្មភាពមីនជាចំបង ។ ជាលទ្ធផលភារកិច្ចបោសសំអាតទំហំតូចៗចំនួន ៤៣ ត្រូវបានស្នើឡើង ផ្ទៃដីចំនួន ២៨៣.៩៩៦ ម៉ែត្រក្រឡា ត្រូវបានបោសសំអាត ហើយគ្រាប់មីនចំនួន ៣.៦១១ គ្រាប់ និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ចំនួន ៦.៥៨៧ គ្រាប់ ត្រូវបានបំផ្លាញចោល [87] ។ នៅខែ ឧសភា ឆ្នាំ ២០០៣ គណៈកម្មាធិការត្រួតពិនិត្យមួយត្រូវបានបង្កើតឡើង ដើម្បីត្រួតពិនិត្យ និង វាយតំលៃការអនុវត្តន៍ និង ប្រសិទ្ធភាពនៃគំរោង CBMRR ក្នុងខេត្តបាត់ដំបង និង ក្រុងប៉ៃលិន និងជាពិសេសដើម្បីរកអោយឃើញនូវតំបន់ដែលចាំបាច់ត្រូវពង្រីក ។ ការវាយតំលៃកម្មវិធីនេះត្រូវបានធ្វើឡើងនៅឆ្នាំ ២០០២ [88] ។

កាកបាទក្រហមកម្ពុជាបានបង្កើតគំរោងចំណេះដឹងអំពីគ្រាប់មីន ដែលមានមូលដ្ឋាននៅតាមសហគមន៍មួយក្នុងឆ្នាំ ២០០២ ។ ក្នុងកំឡុងឆ្នាំ ២០០៣ បុគ្គលិកស្ម័គ្រចិត្តរបស់កាកបាទក្រហមចំនួន ១៨៣ នាក់ បានផ្តល់ការអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីនដល់ប្រជាពលរដ្ឋចំនួន ៩០.១៤៨ នាក់ ក្នុងខេត្ត ៦ (បន្ទាយមានជ័យ, បាត់ដំបង, ឧត្តរមានជ័យ, ប៉ៃលិន, ព្រះវិហារ និង ពោធិសាត់) ។ បន្ថែម លើនេះ យុវជនកាកបាទក្រហមចំនួន ៨៩ នាក់បានទទួលការបណ្តុះបណ្តាល ការអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីន ហើយបន្ទាប់មកបានផ្តល់ការអប់រំនេះបន្តដល់សិស្សានុសិស្សចំនួន ៣.១១៥ នាក់ [89] ។ គំរោងនេះត្រូវបានឧបត្ថម្ភថវិកាដោយកាកបាទក្រហម Finland [90] ។

នៅខែ កុម្ភៈ ២០០៣ HALO Trust បានបង្កើតក្រុមអប់រំគ្រោះថ្នាក់នៃគ្រាប់មីនមួយ មានគ្នា ៣ នាក់ ។ ក្រុមនេះបានផ្តល់បទបង្ហាញអំពីគ្រោះថ្នាក់នៃគ្រាប់មីនដល់សិស្សសាលា និង មនុស្សពេញវ័យនៅតាមភូមិ ដែល HALO Trust កំពុងប្រតិបត្តិការបោសសំអាត ។ នៅឆ្នាំ ២០០៣ បទបង្ហាញរបស់ HALO Trust ត្រូវបានចូលរួមដោយអ្នកភូមិសរុប ២៧.៣១១ នាក់ [91] ។

---

[85] HI, "Emergency Mine /UXO Risk Reduction in North-West Cambodia," Phnom Penh, February 2004, p.7.
[86] Information provided by CMAC to the CCBL, 26 August 2004.
[87] Email from Plong Chhaya, UNICEF, 28 July 2004.
[88] Project Development Group, "External Evaluation of the Pilot Project of Community-Based Mine Risk Reduction (CBMRR)," undated. See *Landmine Monitor Report 2003*, p.144.
[89] Email from Plong Chhaya, UNICEF, 28 July 2004.
[90] ICRC, "Special Report Mine Action," sent to Landmine Monitor on 23 July 2004, p.41.
[91] HALO, "Annual Report 2003," February 2004, p. 4.

នៅឆ្នាំ ២០០៣ MAG មានក្រុមទំនាក់ទំនងសហគមន៍ចំនួន ៧ ក្រុម និង ក្រុមជំនួយបន្ទាន់ ១ ក្រុម ធ្វើការជាមួយក្រុមដទៃទៀតរបស់ខ្លួន។ បទបង្ហាញអំពីការអប់រំគ្រោះថ្នាក់នៃគ្រាប់មីនរបស់ក្រុមជំនួយបន្ទាន់ត្រូវបានចូលរួមដោយប្រជាពលរដ្ឋ ចំនួន ១.៩៩៤ នាក់ (ក្មេង ៩៣០ នាក់ និង មនុស្សពេញវ័យ ១.០៦៤ នាក់) នៅឆ្នាំ ២០០៣[92] ។ រួមជាមួយនឹងអង្គការជនពិការអន្តរជាតិ (Handicap International) និងអង្គការផ្តល់ជំនួយរបស់ប្រជាជនន័រវេស (Norwegian People Aid) MAG បាននឹងកំពុងអនុវត្តការសិក្សាអំពីការប្រើប្រាស់ដោយចេតនានិងការប្រើប្រាស់យុទ្ធភ័ណ្ឌដែលនៅអាចប្រើការបាន។ ការសិក្សានេះមានគោលបំណងបង្កើតការយល់ដឹងអោយបានប្រសើរដល់អ្នកដែលពាក់ព័ន្ធក្នុងការប្រើប្រាស់ដោយចេតនា និង ការប្រើប្រាស់យុទ្ធភ័ណ្ឌដែលនៅអាចប្រើការបាន និង កត្តាអ្វីដែលជាបច្ច័យដល់ការបន្តចរិកបែបនេះ ។ គេសង្ឃឹមថា លទ្ធផលដែលបានពីការសិក្សានេះនឹងជួយបង្ហាញអោយឃើញអំពីភាពប្រសើរដែលអាចត្រូវបានធ្វើឡើង ដោយការកាត់បន្ថយគ្រោះថ្នាក់នៃគ្រាប់មីនបច្ចុប្បន្ន និង អន្តរាគមន៍សំរាលគ្រោះថ្នាក់[93] ។

ក្រុមសកម្មភាព/ចំណេះដឹងគ្រាប់មីនរបស់អង្គការ World Vision បានអនុវត្តសកម្មភាពអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីន ដែលមានគោលបំណងបញ្ចូលសកម្មភាពមីន និង រចនាសម្ព័ន្ធអភិវឌ្ឍន៍នៅតាមសហគមន៍ ។ នៅឆ្នាំ ២០០៣ ក្រុមទាំងនេះធ្វើសកម្មភាពយ៉ាងសកម្មក្នុងស្រុកចំនួន ៤ នៃខេត្តបាត់ដំបង និង ខេត្តព្រះវិហារ ។ សមាជិកបុគ្គលិក ៤រូប បានផ្តល់ការអប់រំគ្រោះថ្នាក់នៃគ្រាប់មីនដល់អ្នកភូមិចំនួន៤.៤៨៤ នាក់ រួមមាន ១.០៤៧នាក់ នៅស្រុករតនះមណ្ឌល, ៤៤ នាក់ នៅស្រុកសំឡូត, ២.១៩៣ នាក់ នៅស្រុករវៀង និង ១.២០០ នាក់ នៅស្រុកត្បែងមានជ័យ[94] ។

ទិវាចំណេះដឹងអំពីគ្រាប់មីនត្រូវបានប្រារព្ធធ្វើឡើងនៅថ្ងៃទី ២៤ កុម្ភៈ ឆ្នាំ ២០០៤ នៅខេត្តឧត្តរមានជ័យ, បន្ទាយមានជ័យ, បាត់ដំបង, សៀមរាប ភាគឧត្តរ និង នៅតាមព្រំដែនខេត្តបន្ទាយមានជ័យ និង ពញាព្ញ ។ ក្មេងៗដែលរងរបួសនៅឆ្នាំ ២០០៣ បាននិយាយទៅកាន់ក្រុមក្មេងៗដែលមានអាយុស្របាលគ្នា ។ ទិវានោះត្រូវបានជំរុញធ្វើឡើងដោយអង្គការ Care មជ្ឈមណ្ឌលអរូបីយ៏ (Arrupe Center), CMAC, អង្គការ Jesuit Refugee Service និង អង្គការដទៃទៀត ។

## មូលនិធិសំរាប់សកម្មភាពមីន

នៅខែ មិថុនា ឆ្នាំ ២០០៤ ប្រទេសកម្ពុជាបានរាយការណ៍អោយភាគីប្រទេសដទៃទៀតថាៈ តំលៃបច្ចុប្បន្ននៃការបោសសំអាតគ្រាប់មីនមានចំនួនប្រហែល ២០ លានដុល្លារ ក្នុងមួយឆ្នាំ [95] ។ នៅខែ មេសា ឆ្នាំ ២០០៤ អាជ្ញាធរមីនកម្ពុជា បានប៉ាន់ប្រមាណថាតំលៃសរុបសំរាប់ប្រតិបត្តិការបោសសំអាតមីន រួមទាំងជំនួយបច្ចេកទេសនិង

---

92 MAG, “2003 Report,” February 2004, p. 5.

93 “Terms of reference, Study on the deliberate handling and usage of live ordnance,” Commissioned by HI, MAG, and NPA, 30 November 2003, Phnom Penh, Cambodia, p. 5.

94 Chham Sokha, World Vision Cambodia, report to Landmine Monitor, 28 July 2004.

95 GICHD Implementation Support Unit, “Progress in implementing Article 5: An overview of the mine-affected States Parties’ problems, plans, progress, and priorities for assistance,” Geneva, 21 June 2004.

ការចូល រួមវិភាគទានតាមប្រភេទមានចំនួនប្រហែល ២០ ទៅ ៣០ លានដុល្លារ ក្នុងមួយឆ្នាំ [96] ។

យោងតាមពតិមានដែលបានដាក់ជូនទៅ ឬ ដែលបានប្រមូលដោយអ្នកត្រួតពិនិត្យគ្រាប់មីនរដ្ឋាភិបាលប្រទេសម្ចាស់ជំនួយ ចំនួន១៥ និង សហគមន៍អឺរ៉ុបបានផ្តល់ថវិកាប្រហែល ១៧លានដុល្លារ ក្នុងការឧបត្ថម្ភដល់សកម្មភាពមីនសំរាប់ប្រទេសកម្ពុជាក្នុងឆ្នាំ២០០៣[97] ។ នេះបើប្រៀបធៀបទៅនឹងចំនួនប្រហែល ២៧,៣ លានដុល្លារនៅឆ្នាំ ២០០២ និង ២១ លានដុល្លារនៅឆ្នាំ ២០០១ ។ ការ ផ្តល់ជំនួយសំរាប់សកម្មភាពមីនក្នុងប្រទេស កម្ពុជាត្រូវបានប៉ាន់ប្រមាណថាមានចំនួនលើស ១៩០ លានដុល្លារពីឆ្នាំ ១៩៩៤ ដល់ឆ្នាំ ២០០៣ រាប់ទាំងចំនួន ១១៤ លានដុល្លារសំរាប់ឆ្នាំ ១៩៩៩ ដល់ឆ្នាំ ២០០៣ ។

ការចូលរួមផ្តល់វិភាគទានក្នុងឆ្នាំ ២០០៣ រួមមាន: ប្រទេសអូស្ត្រាលីចំនួន ១,៦ លានដុល្លារអូស្ត្រាលី (១.០៤៣.២០០ ដុល្លារ អាមេរិក) ប្រទេសបិលហ្ស៊ិកចំនួន ៩៦០.៤៧១អឺរ៉ូ (១.០៨៦.៧៧៣ដុល្លារ) ប្រទេសកាណាដាចំនួន ១.៦៣២.៦៥៣ដុល្លារកាណាដា (១.១៨៨.៤៨៥ ដុល្លារ) សហគមន៍អឺរ៉ុបចំនួន ៤៤៩.៥៣៩អឺរ៉ូ (៥០៨.៦៥៣ដុល្លារ) ប្រទេសហ្វាំងឡង់ដ៏ចំនួន ១.៦៨៦.០៦១អឺរ៉ូ (១.៩០៧.៧៧៨ដុល្លារ) ប្រទេសបារាំងចំនួន ៤៦៥.០០០អឺរ៉ូ (៥២៦.១៤៨ដុល្លារ) ប្រទេសអាល្លឺម៉ង់ចំនួន ៥៥៥.២៦៦អឺរ៉ូ (៦២៨.២៨៣ ដុល្លារ) ប្រទេសអៀរឡង់ដ៏ចំនួន ៣៨៥.០០០អឺរ៉ូ (៤៣៥.៦២៨ដុល្លារ) ប្រទេសជប៉ុនចំនួន ៣៨៩.០០០.០០០ យេន (៣.១៨៨.០០០ ដុល្លារ) ប្រទេសហូឡង់ដ៏ចំនួន ៦៧៥.៤៨៩ដុល្លារ ប្រទេសណូវែលហ្សេឡង់ដ៏ចំនួន ២០៩.០០០ ដុល្លារ ប្រទេសន័រវេស ចំនួន ១.៦០០.០០០ NOK (២២៥.៩២៨ ដុល្លារ), ប្រទេសអេស្បាញ ចំនួន ៧៥.៣៩២ អឺរ៉ូ (៨៥.៣១៣ ដុល្លារ), ប្រទេសស៊ុយអែត ចំនួន ១៦.០០០.០០០ SEK (១.៩៨០.០០០ ដុល្លារ), ចក្រភពអង់គ្លេស ចំនួន ២៧១.២៥០ ផោន (៤៤៣.២៥០ ដុល្លារ) និង សហរដ្ឋ អាមេរិក ចំនួន ២.៩២២.៨០៨ ដុល្លារ ។

បន្ថែមចំពោះរដ្ឋាភិបាលម្ចាស់ជំនួយ ការីសកម្មភាពមីនបានទទួលមូលនិធិពីប្រភពសប្បុរសធម៌ និង ឯកជនព្រមទាំងរាជរដ្ឋាភិបាលកម្ពុជា ។ រាជរដ្ឋាភិបាលកម្ពុជាបានរាយការណ៍ក្នុងខែ មេសា ឆ្នាំ ២០០៤ ថា ខ្លួនបានឧបត្ថម្ភដល់ CMAA, CMAC និង RCAF ចំនួន ៨០០.០០០ ដុល្លារ ក្នុងមួយឆ្នាំ [98] ។ នៅឆ្នាំ ២០០៣ CMAC បានរាយការណ៍ថា ខ្លួនបានទទួលថវិកាចំនួន ៥០០.០០០ ដុល្លារ ហើយ HALO រាយការណ៍ថាបានទទួល ៧៣.០០០ ដុល្លារ ។ ពីឆ្នាំ ១៩៩៣ ដល់ ១៩៩៨ រាជរដ្ឋាភិបាលបានផ្តល់ជំនួយប្រហែល ១ លានដុល្លារ ដល់ CMAC ហើយក៏បានផ្តល់អោយ CMAC នូវស្ថានភាពរួចពន្ធ ដែលមានទឹកប្រាក់ប្រហែលយ៉ាងហោច ២លានដុល្លារ ផងដែរ [99] ។

ប្រតិបត្តិករសកម្មភាពមីន៣ ក្នុងចំណោម៤: អង្គការ CMAC,អង្គការHALO Trust និងអង្គការ MAG បានរាយការណ៍អំពីចំណាយប្រហែល ១៧.៥ លានដុល្លារ ក្នុងឆ្នាំ ២០០៣ ។ តំលៃសកម្មភាពបោសសំអាតមីនរបស់

[96] CMAA, "Mine Action: 1992-2003," 29 April 2004.
[97] See individual country reports in this edition of *Landmine Monitor Report*. In some cases, the funding was for the country's fiscal year, not calendar year 2002. Landmine Monitor has converted the currencies and rounded off numbers.
[98] CMAA, "Mine Action: 1992-2003," 29 April 2004, p. 16.
[99] See *Landmine Monitor Report 1999*, p. 397.

កងយោធពលខេមរភូមិន្ទក្នុងឆ្នាំ២០០៣ មិនត្រូវបានផ្តល់អោយដល់អ្នកត្រួតពិនិត្យគ្រាប់មីនឡើយ ។ កងយោធពលខេមរភូមិន្ទ បានគំរោងទទួលថវិកាបោសសំអាតមីន និង ប្រតិបត្តិការយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ចំនួន ៣ លានដុល្លារ នៅឆ្នាំ ២០០៤ ។ សំរាប់ប្រតិបត្តិការសកម្មភាពមីនដែលអនុវត្តនៅឆ្នាំ ២០០៣ អង្គការ CMAC បានរាយការណ៍ថា ខ្លួនបានទទួលមូលនិធិសរុបចំនួន ១០.៧៣៣.៥៥៥ ដុល្លារ ពីម្ចាស់ជំនួយចំនួន ៩ គឺ : UNDP Trust Fund (៤.៨៩៧.៥៩៩ ដុល្លារ), សហរដ្ឋអាមេរិក (១.៩៧២.១៨៥ ដុល្លារ), ប្រទេសជប៉ុន (១.៧៨៤.៩៩៩ ដុល្លារ), ប្រទេសអាល្លឺម៉ង់ (៨២៩.៤៣០ ដុល្លារ), ជំនួយប្រជាជនន័រវេស (៨៥០.៦៧២ ដុល្លារ), រាជរដ្ឋាភិបាលកម្ពុជា (៥០០.០០០ ដុល្លារ), អង្គការ Handicap International (១៨៩.៧៣៩ ដុល្លារ), សេវាកម្មសកម្មភាពមីនជប៉ុន (៦១.៦០០ ដុល្លារ) និង អង្គការ Care International (៤៧.៧៧១ ដុល្លារ)[100] ។ អង្គការ CMAC បានទទួលមូលនិធិប្រហែល ៨,៦ លានដុល្លារ នៅឆ្នាំ ១៩៩៩, ចំនួន ៧,៦ លានដុល្លារ នៅឆ្នាំ ២០០០, ចំនួន ៧,៥ លានដុល្លារ នៅឆ្នាំ ២០០១ និង ១០,៨ លានដុល្លារ នៅឆ្នាំ ២០០២[101] ។

HALO Trust បានរាយការណ៍អំពីប្រាក់ចំណូលគំរោងសរុបសំរាប់ឆ្នាំ ២០០៣ ចំនួន ៣.៧៤៦.០៨៧ ដុល្លារ ។ ម្ចាស់ជំនួយរបស់ HALO រួមមានក្រសួងការបរទេសនៃប្រទេសហ្វាំងឡង់ដ៏ (៦៧០.០០០ អឺរ៉ូ ឬ ៨០០.០០០ដុល្លារ)[102] ក្រសួងការបរទេសសហរដ្ឋអាមេរិក (៧៦២.៥០០ ដុល្លារ), ក្រសួងការបរទេសហូឡង់ (៦៧៥.៨៨៩ ដុល្លារ), ស្ថានទូតជប៉ុន (៥៤៦.២៣៤ ដុល្លារ), ប្រព័ន្ធ ផ្សព្វផ្សាយទីក្រុងតូក្យូ (៣៦២.៥០០ ដុល្លារ), ជំនួយអូស្ត្រាលី (២៣៨.៤៤៨ ដុល្លារ), ECHO (១៧៧.៩១៧ ដុល្លារ), Rotary International District 2580 (៨០.០០០ ដុល្លារ), រាជរដ្ឋាភិបាលកម្ពុជា (៧៣.០០០ ដុល្លារ), Freedom Field USA (១៦.៦៦៧ ដុល្លារ), និង Rotary International District 5030 (១៣.៣៣៣ ដុល្លារ)[103] ។ ប្រតិបត្តិការរបស់អង្គការ HALO Trust នៅក្នុងប្រទេសកម្ពុជា មានតំលៃប្រហែល ៤ លានដុល្លារ នៅឆ្នាំ ១៩៩៩, ចំនួន ២,៥ លានដុល្លារ នៅឆ្នាំ ២០០០, ចំនួន ៤,៥ លានដុល្លារ នៅឆ្នាំ ២០០១ និង ចំនួន ៣,៦ លានដុល្លារ នៅឆ្នាំ ២០០២ ។

នៅឆ្នាំ ២០០៣ MAG បានទទួលថវិកាប្រហែល ៣ លានដុល្លារ សំរាប់ ១៦ គំរោង ក្នុងប្រទេសកម្ពុជា ពី ១២ ម្ចាស់ជំនួយ រួមមានក្រសួងការបរទេសសហរដ្ឋអាមេរិក, ប្រទេសជប៉ុន, ECHO, Church World Service, World Vision, Julia Burk Foundation, Co-op Bank-UK, Roots of Peace, Lutheran World Serivce, Guernsey Overseas Aid និង ព្រះវិហារ Mann ។ សំរាប់ឆ្នាំ ២០០៤ អង្គការ MAG ស្វែងរកការការពារថវិការបស់ខ្លួនប្រហែល ៣ លានដុល្លារ[104] ។ អង្គការ MAG បានទទួលថវិកាចំនួន ៣,៩ លានដុល្លារ

[100] Questionnaire Response by CMAC, 27 February 2004.
[101] From December 1993 to April 2000, CMAC received a total of $53 million through the UNDP Trust Fund; this does not include other contributions to CMAC such as in-kind donations, equipment and bilateral funding.
[102] Exchange rate calculated by HALO Trust.
[103] HALO, “Annual Report 2003,” February 2004, p. 7.
[104] MAG, “2003 Report,” February 2004, p.10.

នៅឆ្នាំ ១៩៩៩, ចំនួន ៤ លានដុល្លារ នៅឆ្នាំ ២០០០, ចំនួន ៣,៥ លានដុល្លារ នៅឆ្នាំ ២០០១ និង ប្រហែល ៣ លានដុល្លារ នៅឆ្នាំ ២០០២ ។

អាជ្ញាធរមីនកម្ពុជា បានទទួលជំនួយហិរញ្ញវត្ថុ និងជំនួយតាមប្រភេទពីម្ចាស់ជំនួយផ្សេងៗគ្នា ចាប់តាំងពីការបង្កើតរបស់ខ្លួននៅចុងឆ្នាំ ២០០០មក រួមទាំងមូលនិធិពីរាជរដ្ឋាភិបាលចាប់តាំងពីពាក់កណ្តាលឆ្នាំ២០០២។ ប្រទេសអូស្ត្រាលី កាណាដា ន័រវេស UNDP សហគមន៍អឺរ៉ុប UNICEF និង ប្រទេសជប៉ុន បានជួយអាជ្ញាធរមីនកម្ពុជា រៀបចំសិក្ខាសាលាជាតិ និង សិក្ខាសាលាអន្តរជាតិ ។ នៅខែ កញ្ញា ឆ្នាំ ២០០៣ ប្រទេសកាណាដាបានបន្តផ្តល់មូលនិធិជាថ្មីសំរាប់ទិន្នន័យសកម្មភាពមីនជាតិ ។ ចក្រភពអង់គ្លេស តាមរយៈ UNDP បានផ្តល់ជំនួយដល់ការរៀបចំ និង ត្រួតពិនិត្យគំរោងសេដ្ឋកិច្ចសង្គមចាប់ផ្តើមនៅចុងឆ្នាំ ២០០៣ ។ សហគមន៍អឺរ៉ុបបានផ្តល់ជំនួយសំរាប់តុបតែង សាងសង់លេខាធិការដ្ឋាន រហូតដល់ខែ សីហា ឆ្នាំ ២០០២ ។ ចាប់តាំងពីឆ្នាំ ២០០២ មក UNDP និង ប្រទេសបារាំង បានផ្តល់ជំនួយតាមប្រភេទសំរាប់ការរៀបចំគំរោងផែនការ និង បញ្ហាសេដ្ឋកិច្ចសង្គម ។ ពីខែ កញ្ញា ២០០១ ដល់ខែ មិនា ២០០២ ក្រសួងការបរទេស អាល្លឺម៉ង់បានផ្តល់ជំនួយបច្ចេកទេស ដើម្បីបង្កើតមជ្ឈមណ្ឌលទិន្នន័យ។ អង្គការ MAG បានផ្តល់ឧបករណ៍ និង អ្នកជំនាញបច្ចេកទេសព្រមទាំង អ្នកបកប្រែសំរាប់រយៈពេល១ឆ្នាំ (២០០១-២០០២) ។ មជ្ឈមណ្ឌលដោះមីនអន្តរជាតិក្រុងហ្សឺណែវ (GICHD), សកម្មភាពមីនអង្គការសហប្រជាជាតិ (UNMAS) និងអង្គការ UNICEF បានផ្តល់ជំនួយបច្ចេកទេសតាមប្រភេទ ដើម្បីពង្រឹងប្រព័ន្ធ IMSMA និង ជំនួយបច្ចេកទេសក្នុងវិស័យផ្សេងទៀតរាប់ទាំងការអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីន[105] ។

## អ្នករងគ្រោះថ្នាក់ដោយសារគ្រាប់មីន

នៅឆ្នាំ ២០០៣ ករណីគ្រោះថ្នាក់នៃគ្រាប់មីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះថ្មីៗ មានចំនួន ៧៧២ ករណីត្រូវបានរាយការណ៍ថាកើតមាននៅក្នុងប្រទេសកម្ពុជា គឺ : មនុស្សចំនួន ១១៥ នាក់ត្រូវបានស្លាប់ និង ៦៥៧ នាក់រងរបួស ក្នុងនោះ ៤៤២ នាក់ ជាបុរស, ៤៦ នាក់ជាស្ត្រី និង ២៨៤ នាក់ ជាកូនក្មេង, ៧៥១ នាក់ ជាជនស៊ីវិល[106] ។ ក្នុងចំនួនគ្រោះថ្នាក់សរុបនេះ មនុស្សចំនួន ១៥២ នាក់ (២០ ភាគរយ) ត្រូវ ការអវៈយវៈសិប្បនិម្មិត ។ គ្រាប់មីនបានបណ្តាលអោយគ្រោះថ្នាក់ ៣៦២ ករណី (៤៧ ភាគរយ) រីឯគ្រោះថ្នាក់ចំនួន ៤១០ ករណី (៥៣ ភាគរយ) បណ្តាលមកពីយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ យ៉ាងណាក៏ដោយ ចំនួន ៨០ ភាគរយ នៃកូនក្មេងត្រូវបានស្លាប់ និង រងរបួសដោយយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ។ នៅឆ្នាំ ១៩៩៩ ចំនួន ៦៣ ភាគរយនៃគ្រោះថ្នាក់ត្រូវបានបង្កឡើងដោយគ្រាប់មីន[107] ។ គ្រោះថ្នាក់នៅតែត្រូវបានរាយការណ៍ជាបន្តនៅឆ្នាំ២០០៤អត្រាគ្រោះថ្នាក់ដោយគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះថ្មីៗ ចំនួន ៦៧១ ករណី ត្រូវបានកត់ត្រាទុវ ដំណាច់ខែ សីហា[108] ។

---

105 CMAA, “Mine Action: 1992-2003,” 29 April 2004, p. 16.
106 Unless otherwise stated, information in this section was provided in email to Landmine Monitor (HI) from Chhiv Lim, Project Manager, CMVIS, 25 September 2004; and Cambodia Mine/UXO Victim Information System, special report prepared for Landmine Monitor, 6 October 2004.
107 CMAA, “Mine Action: 1992-2003,” 29 April 2004, pp. 12-13.
108 CMVIS, “Monthly Mine/UXO Victim Report: June 2004.”

ចាប់តាំងពីឆ្នាំ១៩៩៩ មក ករណីគ្រោះថ្នាក់ដោយគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះថ្មីៗ ចំនួន ៥.១២៨ ករណី ត្រូវបានកត់ត្រាថាបានកើតមាននៅក្នុងប្រទេសកម្ពុជា ។ អត្រាគ្រោះថ្នាក់ដោយគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ធ្លាក់ចុះពី ១២ ករណីថ្មីៗក្នុងមួយថ្ងៃនៅឆ្នាំ ១៩៩៦ មកនៅត្រឹម ៣ ករណី ក្នុងមួយថ្ងៃ នៅឆ្នាំ ១៩៩៩ ហើយជាមធ្យមត្រឹម ២ករណី ក្នុងមួយថ្ងៃ នៅឆ្នាំ ២០០៣ ដែលនេះជាអត្រាថេរ ចាប់ពីឆ្នាំ ២០០០ មក ។ យ៉ាងណាក៏ដោយ ក្នុងរយៈពេល ៨ ខែ ដំបូងនៃឆ្នាំ ២០០៤ អត្រាគ្រោះថ្នាក់នេះបានកើតឡើងជាថ្មីទៅកំរិតមធ្យម ស្មើរតែ ៣ ករណី ក្នុងមួយថ្ងៃ ។

ពត៌មានស្តីអំពីគ្រោះថ្នាក់នៃគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ត្រូវបានប្រមូលមកពីគ្រប់ខេត្ត ដោយបណ្តាញបុគ្គលិកនៅតាមតំបន់របស់កាកបាទក្រហមកម្ពុជា ទិន្នន័យនេះបន្ទាប់មកត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធពត៌មានជនរងគ្រោះដោយសារគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះកម្ពុជា (CMVIS)ធ្វើឡើងដោយកាកបាទក្រហមកម្ពុជា(CRC) និង អង្គការជនពិការអន្តរជាតិ (HI) ។

ចំនួនអ្នករងគ្រោះថ្នាក់មីននិងគ្រាប់មិនទាន់ផ្ទុះនៅកម្ពុជា ពីឆ្នាំ ១៩៩៦-ខែ សីហា ២០០៤:

| ឆ្នាំ | ចំនួនអ្នករងគ្រោះ | ជាមធ្យមក្នុង១ខែ | ជាមធ្យមក្នុង១ថ្ងៃ | ជាទាហាន | ជាស៊ីវិល | មិនដឹងសញ្ញាណ |
|---|---|---|---|---|---|---|
| 1996 | 4,320 | 360 | 12 | 2,577 | 1,743 | |
| 1997 | 2,299 | 191 | 6 | 998 | 1,300 | 1 |
| 1998 | 2,153 | 179 | 6 | 834 | 1,310 | 9 |
| 1999 | 1,154 | 96 | 3 | 163 | 987 | 4 |
| 2000 | 858 | 72 | 2+ | 62 | 796 | 1 |
| 2001 | 826 | 69 | 2+ | 41 | 785 | |
| 2002 | 847 | 71 | 2+ | 17 | 830 | |
| 2003 | 772 | 63 | 2 | 21 | 751 | |
| 2004 (8 ខែ) | 671 | 84 | 3 | 26 | 645 | |

អត្រាចម្បងនៃគ្រោះថ្នាក់ដោយគ្រាប់មីនពាក់ព័ន្ធទៅនឹងសកម្មភាព ជីវភាពរស់នៅប្រចាំថ្ងៃដូចជា: ការបង្កបង្កើនផល ចិញ្ចឹមសត្វ រានដីថ្មី នេសាទ និង ការប្រមូលម្ហូបអាហារ និង អុស (៥១ ភាគរយ) ឬ ការធ្វើដំណើរ (៣១ ភាគរយ) នៅពេលកើត ឧប្បត្តិហេតុ រីឯ ៦៣ ភាគរយ នៃគ្រោះថ្នាក់ដែលបង្កដោយយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ បង្កឡើងដោយការកេះលេង ។

គ្រោះថ្នាក់ដោយគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ត្រូវបានរាយការណ៍ថាកើតមានឡើងក្នុងខេត្តចំនួន ២០ នៃខេត្ត-ក្រុងទាំង ២៤ នៅឆ្នាំ ២០០៣ ដែល ៧៨ ភាគរយ នៃគ្រោះថ្នាក់សរុបត្រូវបានរាយការណ៍នៅក្នុងខេត្តចំនួន ៧ ដែលច្រើនបំផុតនៅក្នុងខេត្តបាត់ដំបង មានអត្រាគ្រោះថ្នាក់ចំនួន ១៦៩ ករណី (២២ ភាគរយ) បន្ទាប់មកខេត្តបន្ទាយមានជ័យ ចំនួន ១២១ ករណី (១៦ ភាគរយ) និង ខេត្ត ឧត្តរមានជ័យ ៩៧ ករណី (១៣ ភាគរយ) ។

ការពិភាក្សានានាកំពុងដំណើរការក្នុងសហគមន៍សកម្មភាពមីនស្តីអំពី "កង្វះខាតដំណើរការ" ក្នុងការកាត់បន្ថយចំនួនគ្រោះថ្នាក់នៃគ្រាប់មីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ។ សម្មតិកម្មដែលបានដាក់ឡើងរួមមានការិតផ្តល់មូលនិធិដល់ជនក្រីក្រ សំរាប់ការអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីន កំណើនប្រជាពលរដ្ឋ និងការតាំងទីលំនៅជាថ្មីរបស់ជនផ្លាស់ប្តូរទីលំនៅនៅក្នុងប្រទេស និង ជនមាតុភូមិនិវត្តន៍ បំរែបំរួលចំនួនប្រជាពលរដ្ឋ និង ស្ថានភាពសេដ្ឋកិច្ចសង្គមក្នុងតំបន់ដែលរងគ្រោះ និងតំរូវការបញ្ជាក់អោយបានទូលំទូលាយជាងនេះអំពីគ្រោះថ្នាក់នៃយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ជាមូលហេតុចម្បងនៃសកម្មភាពមីន ដែលទាក់ទងរបួសក្នុងប្រទេសកម្ពុជា[109] ។

ការវាយតំលៃពីខាងក្រៅអំពីប្រព័ន្ធពត៌មានជនគ្រោះដោយគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះកម្ពុជា (CMVIS) បានរាយការណ៍ថា ប្រព័ន្ធនេះគឺជាប្រព័ន្ធ "ដែលមានតែមួយក្នុងពិភពលោក ទាក់ទងនឹងការប្រមូលពត៌មាន និងការផ្តល់ពត៌មានលំអិត[110]" ។ ត្រឹមខែ ធ្នូ ឆ្នាំ ២០០៣ ទិន្នន័យពត៌មាននេះ មានផ្ទុកកំណត់ហេតុគ្រោះថ្នាក់ដោយគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ចំនួន ៥៩.១៥៣ ករណី ចាប់ តាំងពីឆ្នាំ ១៩៧៩ មកៈ មនុស្សចំនួន ១៨.៦៧៣ នាក់ត្រូវបានស្លាប់ និង៤០.៤៨០ នាក់ រងរបួស (រួមទាំងជនពិការ ចំនួន ៨.០១៨ ) ដែល ៣៣.៨៤១នាក់ ជាជនស៊ីវិល ។

CMAC បានរាយការណ៍ថាមានការីបោសសំអាតមីនចំនួន ៨ នាក់ បានរងរបួសក្នុងកំឡុងពេល ប្រតិបត្តិការបោសសំអាតមីននៅ ឆ្នាំ២០០៣ ហើយ ៦ នាក់ រងរបួសនៅរយៈពេល ៣ ខែ ដំបូង នៅឆ្នាំ ២០០៤ [111] ។ HALO Trust បានរាយការណ៍ថា មានការីបោស សំអាត មីន ០៣ នាក់ រងរបួសនៅឆ្នាំ ២០០៣[112] ។


Rim Sourng, 41 years old, injured May,2004

[109] UNDP Cambodia, "Support to Mine Action Programs in Cambodia," Project Progress Report for 2002, January 2003.
[110] Steven Mellor, "External Evaluation of the CMVIS Database, Data-entry and reporting systems," Evaluation conducted on behalf of HI and the Cambodian Red Cross, September 2002, p. 1.
[111] CMAC response to Landmine Monitor, 27 February 2004.
[112] HALO, "Annual Report 2003," February 2004, p. 6.

ចំនួនអ្នករងគ្រោះថ្នាក់មីន/គ្រាប់មិនទាន់ផ្ទុះពីឆ្នាំ 1979 ដល់ ខែ ធ្នូ ឆ្នាំ 2003

| ខេត្ត/ក្រុង | មីន | គ្រាប់មិនទាន់ផ្ទុះ | សរុប |
|---|---|---|---|
| បាត់ដំបង | 11,137 | 2,443 | 14,104 |
| បន្ទាយមានជ័យ | 6,655 | 1,623 | 8,278 |
| សៀមរាប | 6,865 | 1,026 | 7,891 |
| ឧត្តរមានជ័យ | 3,889 | 594 | 4,483 |
| ពោធិសាត់ | 3,122 | 614 | 3,736 |
| ព្រះវិហារ | 2,159 | 489 | 2,648 |
| កំពង់ស្ពឺ | 1,987 | 448 | 2,435 |
| កំពង់ចាម | 1,490 | 781 | 2,271 |
| ស្វាយរៀង | 1,586 | 532 | 2,118 |
| កំពត | 1,780 | 310 | 2,090 |
| កំពង់ធំ | 1,190 | 633 | 1,823 |
| តាកែវ | 1,346 | 364 | 1,710 |
| ក្រុងប៉ៃលិន | 893 | 124 | 1,017 |
| កំពង់ឆ្នាំង | 774 | 170 | 944 |
| កណ្ដាល | 753 | 145 | 898 |
| ក្រចេះ | 493 | 224 | 717 |
| កោះកុង | 433 | 208 | 641 |
| ក្រុងព្រះសីហនុ | 305 | 98 | 403 |
| រតនៈគិរី | 96 | 133 | 229 |
| ក្រុង កែប | 203 | 16 | 219 |
| មណ្ឌលគិរី | 122 | 79 | 201 |
| ព្រៃវែង | 79 | 43 | 122 |
| ស្ទឹងត្រែង | 78 | 28 | 106 |
| ក្រុង ភ្នំពេញ | 35 | 34 | 69 |
| សរុប | 47,994 | 11,159 | 59,153 |



Hem Tha, 33 years old, injured April,2004



Toch Sophy, 16 years old, injured February,2004

## ការឧបត្ថម្ភអ្នករងគ្រោះដោយសារមីន

ចំនួនភាគច្រើនអ្នកនៅមានជីវិតពីគ្រាប់មីន រស់នៅដោយភាពពិការក្នុងប្រទេសកម្ពុជា ស្ថិតក្នុងចំណោមអ្នកដែលក្រីក្របំផុតក្នុងប្រទេសក្រីក្រមួយនេះ ។ ប្រហែល ៤៣ ភាគរយ នៃប្រជាពលរដ្ឋនៅជនបទរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ។ នៅក្នុងប្រទេសកម្ពុជា អ្នកនៅមានជីវិតពីគ្រាប់មីន ប្រកបដោយភាពប្រណាំងប្រជែងផ្នែករាងកាយរស់នៅតាមភូមិរាយប៉ាយទូទាំងប្រទេស ឬ រស់នៅតំបន់ទេសចរណ៍ ឬ ទីក្រុងធំៗ ជាទីកន្លែងដែលពួក

គេតស៊ូប្រកបរបរចិញ្ចឹមជីវិត។ ការជួយដល់អ្នកនៅមានជីវិតពីគ្រាប់មីន បន្ទាប់ពីតំរូវការស្តារជាមូលដ្ឋានត្រូវបានបំពេញរួចហើយទាមទារពេលវេលាយូរអង្វែងលើផ្លូវមួយដ៏អាក្រក់ ។ មានសេវាកម្មថែរក្សាសុខភាពជាច្រើន ប៉ុន្តែជារឿយៗមិនអាចទទួលយកបានដោយបញ្ហាហិរញ្ញវត្ថុ។ តំលៃថែរក្សាសុខភាពសំរាប់របួសដោយគ្រាប់មីនអាចបណ្តាលអោយគ្រួសារទាំងមូលត្រូវក្ស័យធនទាំងស្រុង។ ជំនួយភាគច្រើនចំពោះអ្នកនៅមានជីវិតពីគ្រាប់មីនត្រូវបានផ្តល់ដោយគ្រួសាររបស់គេ ទោះបីជាអង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិជាច្រើនបានផ្តល់អោយនូវសេវាសហគមន៍ និង ពិសេសមួយចំនួនក៏ដោយ សេវាកម្មជំនួយអ្នកនៅមានជីវិតពីគ្រាប់មីនក្នុងប្រទេសកម្ពុជា ត្រូវបានអនុវត្តក្នុងក្របខ័ណ្ឌក្រោយសង្គ្រាម [113] ។

យោងតាម CMAA មានអង្គការជាង ៣០ (ជាតិ និង អន្តរជាតិ) ដែលកំពុងប្រតិបត្តិការយ៉ាងសកម្មក្នុងប្រទេសកម្ពុជាភាគច្រើន អស់រយៈពេល ១ ទសវត្ស ឬ វែងជាងនេះ កំពុងធ្វើការដើម្បីស្តារ ជីវភាពរបស់អ្នកនៅមានជីវិតពីគ្រាប់មីនឡើងវិញ។ អង្គការក្រៅរដ្ឋាភិបាលជាច្រើនគឺជាអ្នកអនុវត្តសកម្មភាពដ៏សំខាន់ ដោយផ្តល់នូវសេវាកម្មស្តាររាងកាយនិង ជំនួយឧបត្ថម្ភដទៃទៀតដូចជា : ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការងារនិងការបង្កើតសហគ្រាសខ្នាតតូច[114] ។ អង្គការក្រៅរដ្ឋាភិបាលទាំងឡាយក្នុងប្រទេសកម្ពុជា មិនបានបែងចែកអំពីភាពខុសគ្នារវាងជំនួយដែលមានដល់អ្នកនៅមានជីវិតពីគ្រាប់មីន និង ជំនួយចំពោះជនពិការដោយមូលហេតុដទៃទៀត ។

ជំនួយសង្គ្រោះបន្ទាន់មាននៅក្នុងមជ្ឈមណ្ឌលសុខាភិបាលទៅតាមឃុំ ស្រុក ហើយជួនកាលនៅតាមកំរិតភូមិ ប៉ុន្តែ របួសជាច្រើនទាមទារការព្យាបាលជាពិសេសរាប់ទាំងការវះកាត់ផងដែរ។ សេវាកម្មសុខភាពទាំងនេះគ្រប់គ្រងដោយក្រសួងសុខាភិបាល ហើយមាននៅតាមមន្ទីរពេទ្យរដ្ឋាភិបាល និង មន្ទីរពេទ្យមួយចំនួនដែលគ្រប់គ្រងដោយអង្គការក្រៅរដ្ឋាភិបាល។ ឧប្បត្តិហេតុនានាជារឿយៗ កើតមានឡើងនៅតាមភូមិឬព្រៃដាច់ស្រយាលពីមណ្ឌលសុខភាព ហើយជំនួយសង្គ្រោះបន្ទាន់ត្រូវបានផ្តល់ដោយអ្នកភូមិ ។

អង្គការក្រៅរដ្ឋាភិបាលន័រវេស មូលនិធិ Trauma Care Foundation (TCF) ដោយមានកិច្ចសហការជាមួយសេវាកម្ម សង្គ្រោះបន្ទាន់កាតូលិក (Catholic Relief Service) បានផ្តល់នូវការបណ្តុះបណ្តាលក្នុងការជួយសង្គ្រោះបន្ទាន់ និង បច្ចេកទេសសង្គ្រោះ ជីវិតដល់អ្នកភូមិ និង បុគ្គលិកសុខភាពនៅតាមភូមិ ស្រុក និង ពេទ្យតំបន់។ ការបណ្តុះបណ្តាលរបស់ TCF មានដំណាក់កាលខុសប្លែកគ្នា រួមមានអ្នកជំនួយបន្ទាន់នៅតាមភូមិ (Village First Helper) ដែលត្រូវបានបណ្តុះបណ្តាលអំពីជំនួយសង្គ្រោះបន្ទាន់ជាមូលដ្ឋាន បុគ្គលិក សុខភាពស្ម័គ្រចិត្តនៅតាមភូមិ (VHV) ដែលត្រូវបានបណ្តុះបណ្តាលអំពីការព្យាបាលបន្ទាន់ និង របៀបសង្គ្រោះជីវិត និង ពេទ្យយោធាទំនាក់ទំនងជាសំខាន់របស់បុគ្គលិកសង្គ្រោះជីវិត គឺជាបុគ្គលិកពេទ្យរបស់រដ្ឋាភិបាលនៅតាមគ្លីនិកសុខភាពឬមន្ទីរពេទ្យបង្អែក ដែលត្រូវបានបណ្តុះបណ្តាលអំពីបច្ចេកទេសសង្គ្រោះជីវិត រយៈពេលវែង ។ ពេទ្យយោធា (Mine Medics)

[113] Presentation by Denise Coghlan, CCBL, Standing Committee on Victim Assistance and Socio-Economic Reintegration, Geneva, 10 February 2004.

[114] Statement by Sam Sotha, Secretary-General, CMAA, to meeting on victim assistance, Phnom Penh, 10 March 2004.

ត្រូវបានបំពាក់ដោយសាក់កាដូ ដែលមានឧបករណ៍ចាំបាច់ជាមូលដ្ឋាន ដើម្បីធ្វើអោយមានស្ថេរភាពនូវគ្រោះថ្នាក់ដោយគ្រាប់មីន និង រៀបចំដឹកអ្នករងគ្រោះទៅមន្ទីរពេទ្យបង្អែកប្រសិនបើចាំបាច់។ ដំណាក់កាលចុងក្រោយគឺជាការបណ្តុះបណ្តាលការវះកាត់នៅតាមមន្ទីរពេទ្យបង្អែក ។ នៅឆ្នាំ ២០០៣ TCF ដោយមានកិច្ចសហការជាមួយមជ្ឈមណ្ឌល Tromsoe Mine Victim Resource Center (TMC) ន័រវេស បានបណ្តុះបណ្តាលបុគ្គលិកវះកាត់ចំនួន ១២ នាក់ មកពីពេទ្យបង្អែក ចំនួន ៦ គេបានជួយសង្គ្រោះមនុស្សចំនួន ១៥០ នាក់ ដែលរងរបួសទាក់ទងនឹងការប៉ះទង្គិចខ្លាំង រួមទាំងរបួសដែលបណ្តាលដោយគ្រាប់មីន។ TCF កំពុងធ្វើការយ៉ាងសកម្មក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន សៀមរាប ឧត្តរមានជ័យ និង ព្រះវិហារ[115] ។ នៅឆ្នាំ ២០០២ សៀវភៅអប់រំមានចំណងជើងថា "សង្គ្រោះជីវិត សង្គ្រោះអវៈយវៈ" ត្រូវបានបោះពុម្ពចែកចាយជាភាសាខ្មែរ [116] ។

ជាផ្នែកមួយនៃគំរោង Integrated Demining Development Project របស់ខ្លួន, អង្គការ Care បានបណ្តុះបណ្តាលបុគ្គលិក សុខភាពស្ម័គ្រចិត្តនៅតាមភូមិ ចំនួន ២ នាក់ ដើម្បីឆ្លើយតបនឹងតំរូវការសង្គ្រោះបន្ទាន់ដូចជា ឧប្បត្តិហេតុគ្រាប់មីនជាដើម [117] ។

អង្គការមួយចំនួនរួមមានការសង្គ្រោះបន្ទាន់ (Emergency), CMAC, HALO Trust, MAG, Jesuit Services Cambodia និង សេវាកម្មអភិវឌ្ឍន៍គ្រួសារកម្ពុជា បានផ្តល់នូវរថយន្តសង្គ្រោះបន្ទាន់ ឬ ការដឹកជញ្ជូនទៅមន្ទីរពេទ្យ។ អង្គការកាកបាទ ក្រហមកម្ពុជាបានជូនពតិមានដល់ទីភ្នាក់ងារមួយចំនួនអំពីតំរូវការពិសេសរបស់អ្នករងគ្រោះដោយគ្រាប់មីននៅតាមមន្ទីរពេទ្យ ។ នៅក្នុង ខេត្តបន្ទាយមានជ័យ អង្គការកាកបាទក្រហមកម្ពុជា បានបញ្ជាក់អំពីអ្នកនៅមានជីវិតពីគ្រាប់មីន ដែលត្រូវការជាចាំបាច់នូវចំនួនម្ហូប អាហារក្នុងមន្ទីរពេទ្យដល់ JS ហើយសមាគមកម្ពុជាដើម្បីផ្តល់ជំនួយដល់គ្រួសារ និង ស្ត្រីមេម៉ាយ បានឧបត្ថម្ភជាប្រាក់សំរាប់ការវះកាត់។

ការវះកាត់សំរាប់គ្រោះថ្នាក់ដោយគ្រាប់មីនថ្មីៗនិងសំរាប់អ្នកនៅមានជីវិតពីគ្រាប់មីន ដែលទាមទារការវះកាត់បន្ថែមត្រូវបានផ្តល់អោយដោយឥតគិតថ្លៃលើមជ្ឈមណ្ឌលវះកាត់បន្ទាន់ក្នុងខេត្តបាត់ដំបងនិងដោយមជ្ឈមណ្ឌលក្តីសង្ឃឹមនៃមន្ទីរពេទ្យព្រះសីហនុក្នុងក្រុងភ្នំពេញ។ មន្ទីរពេទ្យអង្គរសំរាប់ក្មេងៗក្នុងខេត្តសៀមរាប, មន្ទីរពេទ្យនៅតាមក្រុងនិងខេត្តរបស់រដ្ឋនិងមន្ទីរពេទ្យព្រះកេតុមាលា អតីតសំរាប់គ្រោះថ្នាក់យោធាក៏បានផ្តល់សេវាកម្មវះកាត់ផងដែរ[118]។ យ៉ាងណាក៏ដោយ គ្រួសារជាច្រើនមិនអាចមានលទ្ធភាពទូទាត់ថ្លៃវះកាត់នៅមន្ទីរពេទ្យរដ្ឋឡើយ។ ក្នុងកំឡុងពេលវគ្គសិក្សាស្រាវជ្រាវសំរាប់ធ្វើរបាយការណ៍នេះ អ្នកត្រួតពិនិត្យគ្រាប់មីនបានរកឃើញនូវគ្រោះថ្នាក់ដោយគ្រាប់មីនថ្មីៗនៅមជ្ឈមណ្ឌលវះកាត់បន្ទាន់ មន្ទីរពេទ្យមង្គលបុរី ខេត្តបន្ទាយមានជ័យ មន្ទីរពេទ្យសំរោង ខេត្តឧត្តរមានជ័យ និង មន្ទីរពេទ្យកាល់ម៉ែត ក្រុងភ្នំពេញ ។

---

[115] Yan Vanheng, Manager, TCF, response to LM Questionnaire, 10 February 2004

[116] Trauma Care Foundation, "Tromsoe Mine Victim Resource Center: Annual Report 2002," pp. 7-8; Catholic Relief Service, response to Landmine Monitor Survivor Assistance questionnaire, 7 February 2002.

[117] Email from John Levinson, Project Coordinator, IDDP3 CARE, Battambang, 2 February 2004.

[118] DAC, "List of Organizations helping landmine survivors in Cambodia," February 2003.

នៅឆ្នាំ ២០០៣ មន្ទីរពេទ្យមង្គលបុរី ខេត្តបន្ទាយមានជ័យ បានជួយករណីរងគ្រោះដោយគ្រាប់មីនចំនួន ៤២ ករណី ហើយករណីរងគ្រោះដោយគ្រាប់មីនចំនួន ៧៨ ករណី និង ដោយយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ចំនួន ៣២ ករណី ត្រូវបានជួយសង្គ្រោះនៅឆ្នាំ ២០០២ ។ នៅខែ មករា និង កុម្ភៈ ឆ្នាំ ២០០៤ គេបានរាយការណ៍អំពីគ្រោះថ្នាក់ដោយគ្រាប់មីនចំនួន ៧ ករណី [119] ។ នៅពេលដែលអ្នកត្រួតពិនិត្យគ្រាប់មីនចុះធ្វើទស្សនកិច្ចនៅតាមមន្ទីរពេទ្យកាលពីថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៤ ករណីគ្រោះថ្នាក់ដោយគ្រាប់មីនចំនួន ១១ ករណី ត្រូវបាន បញ្ជូនទៅមន្ទីរពេទ្យ ។

អង្គការក្រៅរដ្ឋាភិបាលសង្គ្រោះបន្ទាន់អ៊ីតាលី បានបើកមជ្ឈមណ្ឌលវះកាត់ "Ilaria Alpi" នៅក្នុងខេត្តបាត់ដំបង កាលពីខែកក្កដា ឆ្នាំ ១៩៩៨ ដើម្បីផ្តល់ជំនួយវះកាត់ដល់ជនរងគ្រោះដោយសង្គ្រាម ជាពិសេសករណីគ្រោះថ្នាក់ដោយគ្រាប់មីន និង ករណីវះកាត់ជាទូទៅដទៃទៀត ។ អង្គការនេះក៏បានផ្តល់នូវប៉ុស្តិ៍សង្គ្រោះបន្ទាន់ចំនួន ៥ កន្លែង ក្នុងតំបន់សំឡូត និង ប្រតិបត្តិការសេវាកម្មរថយន្ត សង្គ្រោះបន្ទាន់ពីសំឡូតផងដែរ ។ នៅឆ្នាំ ២០០៣ អង្គការនេះបានព្យាបាលមនុស្សចំនួន ២.៣៧៩ នាក់ រាប់ទាំង ១៦០ នាក់ រងរបួស ទាក់ទងនឹងសង្គ្រាម, ១០៤ នាក់ ជាគ្រោះថ្នាក់ដោយគ្រាប់មីននិង ៣៧នាក់ ជាគ្រោះថ្នាក់ដោយយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។ អង្គការនេះក៏បានផ្តល់សេវាកម្មវះកាត់ កែលំអត្រឹមត្រូវដល់អ្នកនៅមានជីវិតពីគ្រាប់មីន ចំនួន ៧៨ នាក់ ។ ករណីគ្រោះថ្នាក់ដោយគ្រាប់មីនដែលបានជួយសង្គ្រោះនៅឆ្នាំ ២០០៣ ដែលបានរាយការណ៍មកនេះ មានរបួសធ្ងន់ធ្ងរជាងក្នុងឆ្នាំមុន ដែលទាមទារនូវអវៈយវៈសិប្បនិម្មិតខ្ពស់ និង រយៈពេលព្យាបាលនៅមន្ទីរពេទ្យវែងជាង ។ គ្រោះថ្នាក់ដោយការប៉ះទង្គិចខ្លាំង ត្រូវបានរាយការណ៍ពីស្រុកចំនួន ១៣ ក្នុងខេត្តបាត់ដំបង និង ពីក្រុងប៉ៃលិន, ពោធិសាត់, បន្ទាយមានជ័យ, តាកែវ, សៀមរាប, ប៉ោយប៉ែត, ឧត្តរមានជ័យ, កំពង់ធំ, និងភ្នំពេញ ។ នៅរយៈពេល ២-៣ ខែដំបូងនៃឆ្នាំ ២០០៤ គេបានរាយការណ៍អំពីករណីគ្រោះថ្នាក់ថ្មីៗដោយគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះចំនួន ៦៩ ករណីផ្សេងទៀត។ ចាប់តាំងពីខែកក្កដា ឆ្នាំ១៩៩៨មក មជ្ឈមណ្ឌលវះកាត់បន្ទាន់ បានជួយនូវករណីគ្រោះថ្នាក់ថ្មីៗដោយគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និង អ្នកនៅមានជីវិតពីគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ចំនួន ៥៥២ នាក់ ដែលទាមទារការវះកាត់បន្ថែម : ៦៩ នាក់ នៅឆ្នាំ ២០០៤, ចំនួន ២១៩ នាក់ នៅឆ្នាំ ២០០៣, ចំនួន ២៥៥ នៅឆ្នាំ ២០០២, ចំនួន ២៣៦ នាក់ នៅឆ្នាំ ២០០១, ចំនួន ២៧១ នាក់ នៅឆ្នាំ ២០០០, ចំនួន ៣១៦ នាក់ នៅឆ្នាំ ១៩៩៩ និង ចំនួន ១៩៣ នាក់ នៅឆ្នាំ ១៩៩៨ [120] ។

អ្នកជំនាញវះកាត់សំរាប់វះកាត់នៃគ្រាប់មីននៅឆ្នាំ ២០០៣ រួមមានបុគ្គលិកវះកាត់អវៈយវៈអេស្ប៉ាញ, បុគ្គលិកវះកាត់ត្រចៀក បារាំង និង អូស្ត្រាលី ដោយមានកិច្ចសហការជាមួយមន្ទីរពេទ្យកុមារជាតិ, ក្រុមប្រឹក្សាសកម្មភាពជនពិការ, JS, Emergency និង អង្គការ Chrisian Blind Mission[121] ។

[119] Sok Eng, Metta Karuna Sisophon, response to Landmine Monitor; Information from a comparative study on landmine casualties at the Mongkol Hospital from January to August 1996-1997, 2002-2003. Email from Krisna Uk, NPA, 23 April 2004.

[120] EMERGENCY Surgical Center for War Victims, "Annual Report for 2003," January 2004, p. 5; Response to LM Questionnaire by Sonia Riccelli, Desk Officer for Cambodia, Emergency, 28 February 2004.

[121] Adelphe Tran and Liz Cross, DAC response to Landmine Monitor, 20 June 2004.

សេវាកម្មស្តាររាងកាយសំរាប់អ្នកនៅមានជីវិតពីគ្រាប់មីន ជាទូទៅត្រូវបានចាត់ថែងយ៉ាងល្អ ហើយមានគុណភាពល្អនៅក្នុងប្រទេសកម្ពុជា ជាពិសេសសំរាប់ជនពិការ ទោះបីជានៅតែមានតំរូវការខ្លាំងក្លាក៏ដោយ ។ ចាប់ពីឆ្នាំ ១៩៩៩មក មជ្ឈមណ្ឌលស្តាររាងកាយ និង រោងជាងសិល្បៈកែច្នៃរាងកាយ ដែលគ្របដណ្តប់ ២៤ខេត្តក្នុងប្រទេសកម្ពុជា ដែលបានកើតឡើងពីចំនួន ១៥ ទៅចំនួន ១៦ បានថយ ចុះមកនៅចំនួន ១៤ នៅដើមឆ្នាំ ២០០៣ និង មកនៅចំនួន ១១ នៅឆ្នាំ ២០០៤ ។ យោងតាមអ្នកផ្តល់សេវាកម្មទាំងឡាយ ហេតុផលចម្បងចំពោះការថយចុះនៃចំនួនមជ្ឈមណ្ឌលនេះ គឺបណ្តាលមកពីការថយចុះនូវមូលនិធិ ប៉ុន្តែការបិទមជ្ឈមណ្ឌលនិមួយៗត្រូវបានវិភាគថាធ្វើឡើងដើម្បីកំរិតនូវចំនួនអតិបរមានូវឥទ្ធិពលលើអ្នកនៅមានជីវិតដែលត្រូវការជំនួយជាចាំបាច់ ។ ហេដ្ឋារចនាសម្ព័ន្ធ ដែលបានធ្វើអោយប្រសើរឡើងនៅទូទាំងប្រទេសកម្ពុជា ត្រូវបានរាយការណ៍ថាបានអនុញ្ញាតអោយជនពិការមកពីតំបន់នៅជិតមជ្ឈមណ្ឌលធ្វើដំណើរទៅមជ្ឈមណ្ឌលដែលនៅសល់ជិតបំផុត ។ ហេតុផលដទៃទៀតសំរាប់ការបិទមជ្ឈមណ្ឌលទាំងនេះ រួមមានតំលៃការគ្រប់គ្រងគុណភាព និង និរន្តរភាព[122] ។ អង្គការអន្តរជាតិ ចំនួន ៥ រួមមាន ICRC, American Red Cross (ARC), Cambodia Trust (CT), Handicap International (HI) និង Veterans International (VI) បានជួយដល់មជ្ឈមណ្ឌលនេះ ដោយមានកិច្ចសហប្រតិបត្តិការជាមួយក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនិតិសម្បទា (MOSALVY) ។ MOSALVY មិនមានថវិកាប្រតិបត្តិសំរាប់ការស្តាររាងកាយឡើងវិញឡើយ ដូច្នេះពឹងផ្អែកទៅលើទីភ្នាក់ងារអន្តរជាតិនានា។ មជ្ឈមណ្ឌលស្តារទាំងនេះ ដែលបច្ចុប្បន្នកំពុងជួយអ្នកនៅមានជីវិតពីគ្រាប់មីន និង ជនពិការផ្សេងៗទៀតស្ថិតនៅក្នុងខេត្តបាត់ដំបង (ICRC), កំពង់ស្ពឺ (ARC), សៀមរាប (HI), កំពង់ចាម (HI), ក្រចេះ (VI), ក្រុងព្រះសីហនុ (CT), ព្រៃវែង (VI), តាកែវ(HI), កំពង់ឆ្នាំង(CT) និង ២ ទៀត នៅក្នុងទីក្រុងភ្នំពេញ (CT និង VI)[123] ។ ចាប់ពីឆ្នាំ ២០០១មក មជ្ឈមណ្ឌលស្តារជាច្រើន បានបិទទ្វារនៅខេត្តបន្ទាយមានជ័យ (HI បិទ នៅខែ វិច្ឆិកា ឆ្នាំ២០០៣), ខេត្តកំពត (HI បិទនៅខែកញ្ញា ឆ្នាំ ២០០១), ខេត្តកំពង់ធំ (HI បិទនៅខែ មិថុនា ឆ្នាំ ២០០៤), ព្រះវិហារ (VI បិទនៅខែ តុលា ឆ្នាំ ២០០៤) និង ខេត្តពោធិសាត់ (HI បិទនៅខែ វិច្ឆិកា ឆ្នាំ ២០០១)[124] ។

កម្មវិធីស្តាររាងកាយឡើងវិញរបស់ ICRC ដោយមានកិច្ចព្រមព្រៀងជាមួយក្រសួងសង្គមកិច្ចការងារ បានចាប់ផ្តើមនៅខែតុលា ឆ្នាំ១៩៩១ ហើយមានសមាសភាពពីរគឺៈ មជ្ឈមណ្ឌលស្តាររាងកាយភូមិភាគបាត់ដំបង និង រោងចក្រផលិតឧបករណ៍កែច្នៃរាងកាយក្នុងទីក្រុងភ្នំពេញ។ នៅខែមេសា ឆ្នាំ២០០១ មជ្ឈមណ្ឌលស្តារនេះត្រូវបានលើកតំកើនដោយរដ្ឋាភិបាល អោយក្លាយជាមជ្ឈមណ្ឌលកំរិតភូមិភាគ ហើយឥឡូវនេះ កំពុងបំរើសេវាកម្មដល់ខេត្ត

---

[122] Email from Larrie Warren, Director, Post Conflict Rehabilitation VVAF, 16 September 2004; Response to LM Questionnaire by Keo Phalla, ARC, Phnom Penh, 22 January 2004; interview with Marc Hermant, Program Director, HI, Phnom Penh, 12 January 2004.

[123] Response to Landmine Monitor by Punya Droz, DAC, Phnom Penh, 7 April 2004; DAC, "Action for Victim Assistance: Cambodia 2003," September 2003, p. 11; *Landmine Monitor Report 1999*, p. 406; *Landmine Monitor Report 2001*, pp. 451-452; Article 7 Report, Form J, 15 April 2003.

[124] Email from Larrie Warren, VVAF, 16 September 2004; Email from Edith van Wijngaarden, Coordinator, Rehabilitation Department, HI Cambodia, 17 September 2004.

បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ ឧត្តរមានជ័យ និង ពោធិសាត់ (ភាគខាងជើង/ពាយ័ព្យកម្ពុជា) ។ ICRC បានផ្តល់ការព្យាបាលដោយការហាត់ប្រាណ ឧបករណ៍ជំនួសរាងកាយសិប្បនិម្មិត ឧបករណ៍ជំនួយក្នុងការដើរ, រទេះកង់បី, ការស្នាក់នៅ និង ហូបចុកដោយឥតគិតថ្លៃ និង ចំណាយទូទាត់រវាង ៨០ ទៅ ១០០ ភាគរយ នៃតំលៃធ្វើដំណើរទៅមជ្ឈមណ្ឌលនេះ ។ ការបណ្តុះបណ្តាលពេលបំពេញការងារត្រូវបានផ្តល់អ្នកបច្ចេកទេសព្យាបាលដោយការហាត់ប្រាណ និងអ្នកបច្ចេកទេសកែច្នៃរាងកាយ ។ អ្នកបច្ចេកទេសព្យាបាលដោយការហាត់ប្រាណ និងអ្នកបច្ចេកទេសកែច្នៃរាងកាយចំនួន ៦នាក់ ត្រូវបានឧបត្ថម្ភអោយចូលសិក្សានៅសាលាព្យាបាលដោយការហាត់ប្រាណ និងអ្នកបច្ចេកទេសកែច្នៃរាងកាយកម្ពុជាក្នុងទីត្រកុងភ្នំពេញដើម្បីទទួលបានការសិក្សាបណ្តុះបណ្តាលរយៈពេល០៣ឆ្នាំ ។ មជ្ឈមណ្ឌលនេះក៏ធ្វើប្រតិបត្តិការជាគ្លីនិកចល័ត ដែលធ្វើដំណើរពីខេត្តបាត់ដំបងទៅខេត្តដទៃទៀត ដើម្បីអនុវត្តការជួសជុលដល់ទីកន្លែង និងតាមដានជនពិការ ។ នៅឆ្នាំ ២០០៣ គេបានចុះទស្សនកិច្ចដល់ទីកន្លែងចំនួន ២១ លើកបានជួយមនុស្សចំនួន១,៧៥០នាក់ និង ដាក់ជំនួសសរីរាង្គដែលកាត់ចោលដល់មនុស្សចំនួន ១.០៥៥នាក់ បានជួសជុលឧបករណ៍ជំនួសរាងកាយចំនួន ១៥ និងរទេះកង់បីចំនួន ៦៤ [125] ។ ចាប់ពីឆ្នាំ ១៩៩៩ មក មជ្ឈមណ្ឌលស្តាររាងកាយភូមិភាគនេះបានផលិតឧបករណ៍ជំនួសសរីរាង្គសិប្បនិម្មិតចំនួន ៦.៥២៩ (៦.០៨៩សំរាប់អ្នកនៅមានជីវិតពីគ្រាប់មីន) ឧបករណ៍ជំនួយរាងកាយចំនួន ៣.១១៥ (យ៉ាងហោចណាស់ចំនួន ១១ សំរាប់អ្នកនៅមានជីវិតពីគ្រាប់មីន) និងបានចែកចាយឈើច្រត់ចំនួន ១៨.៤០៤ សំរាប់ និង រទេះកង់បីចំនួន ៥៦៨ រទេះ រួមទាំឧបករណ៍ជំនួសសរីរាង្គសិប្បនិម្មិតចំនួន ១.២៨៣ សំរាប់ (១.១៨៩ សំរាប់អ្នកនៅមានជីវិតពីគ្រាប់មីន) ឧបករណ៍ជំនួយរាងកាយ ចំនួន ៨០៩ (៤ សំរាប់អ្នកនៅមានជីវិតពីគ្រាប់មីន) ឈើច្រត់ចំនួន ២.៣៦៨ និង រទេះកង់បីរុញ ១៩៦រទេះ នៅឆ្នាំ ២០០៣[126] ។

នៅឆ្នាំ ២០០៣ រោងចក្រផលិតឧបករណ៍ជំនួយរាងកាយរបស់ ICRC ក្នុងទីក្រុងភ្នំពេញបានផ្តល់ឧបករណ៍ជំនួយក្នុងការដើរដោយឥតគិតថ្លៃដល់មជ្ឈមណ្ឌលចំនួន១៤ នៅទូទាំងប្រទេសគឺ ICRC នៅខេត្តបាត់ដំបង និងមជ្ឈមណ្ឌលនានាដែលគ្រប់គ្រងដោយ American Red Cross, Cambodia Trust, Handicap International និង Veterans International ។ សំភារៈនិង ឧបករណ៍ជំនួយក្នុងការដើរទាំងនេះ ដែលផលិតបានរួមមានៈ ជើង, ដៃ, ជង្គង់, ជើងរណប, សន្លាក់សីរីរាង្គ, សន្លាក់កែងដៃ, ទំពក់ និង ឈើច្រត់ ។ នៅឆ្នាំ ២០០៣ រោងចក្រនេះបានផលិតគ្រប់សំភារៈដែលចាំបាច់ដើម្បីផលិតឧបករណ៍ជំនួសសរីរាង្គសិប្បនិម្មិតចំនួន ៥.០០០ សំរាប់, នៅឆ្នាំ ២០០២ សំភារៈជើងរណបដែលត្រូវបានផលិតសំរាប់ជំនួយសរីរាង្គមាន ៥.៥០០ និង ឈើច្រត់ចំនួន ៤.៥០០ គូ ត្រូវបានចែកចាយដោយមជ្ឈមណ្ឌលស្តារនានា [127] ។

---

125 ICRC Physical Rehabilitation Programs, "Annual Report 2003," Geneva, 9 March 2004, p. 11; ICRC, "Physical Rehabilitation Program in Cambodia," May 2003, pp. 1-2.

126 Ibid, p. 26; "Annual Report 2002," June 2003; "Annual Report 2001," 14 April 2002; "Annual Report 2000," 31 March 2001; "Annual Report 1999," 31 March 2000, p. 11.

127 ICRC Physical Rehabilitation Programs, "Annual Report 2003," 9 March 2004, p. 11; ICRC, "Physical Rehabilitation Program in Cambodia," Briefing Paper, May 2003, p. 3.

កាកបាទក្រហមអាមេរិកាំង (ARC) កំពុងធ្វើសកម្មភាពយ៉ាងសកម្មនៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ ១៩៩១ មក ដោយផ្តល់ការព្យាបាលដោយការហាត់ប្រាណ, ឧបករណ៍ជំនួសសរីរាង្គដែលកាត់ចោល, និង ឧបករណ៍ជំនួសរាងកាយ, ឈើច្រត់និងរទេះរុញសំរាប់អ្នកនៅមានជីវិតពីគ្រាប់មីននិងជនពិការដទៃទៀតនៅមជ្ឈមណ្ឌលស្តាររាងកាយខេត្តកំពង់ស្ពឺ ។ ARC ក៏បានផ្តល់ការបណ្តុះបណ្តាលពេលបំពេញការងារដល់បុគ្គលិកកម្ពុជា និង សេវាកម្មដល់ទីកន្លែងដែលប្រជាពលរដ្ឋរស់នៅក្នុងតំបន់ជនបទដាច់ស្រយាល។ មជ្ឈមណ្ឌលនេះគ្របដណ្តប់ចំនួន៣៣ភាគរយនៃតំរូវការក្នុងប្រទេសកម្ពុជា (៨០ ភាគរយនៃអ្នកទទួលផល គឺជាអ្នកនៅមានជីវិតពីគ្រាប់មីន) ហើយ ICRC បច្ចុប្បន្នកំពុងទទួលខុសត្រូវលើមជ្ឈមណ្ឌលនេះ ដើម្បីអោយខ្លួនអាចបន្តប្រតិបត្តិការរបស់ខ្លួនបាន ។ ចាប់ពីឆ្នាំ ១៩៩៩ មក ARC បានចាប់តាំឡើងឧបករណ៍ជំនួសសរីរាង្គសិប្បនិម្មិយចំនួន ៣.១៧៦ សំរាប់ រួមទាំង ៧០៩ សំរាប់នៅឆ្នាំ២០០៣ដល់អ្នកនៅមានជីវិតពីគ្រាប់មីន។ ប្រហែល ៤០ ភាគរយ នៃប្រជាពលរដ្ឋដែលទទួលបានសេវាកម្មស្តារនៅមជ្ឈមណ្ឌលនេះ គឺជាអ្នកនៅមានជីវិតពីគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ។ នៅឆ្នាំ ២០០៣ មជ្ឈមណ្ឌលនេះក៏បានផលិតឧបករណ៍ជំនួសរាងកាយ ចំនួន ៩៣៩ ហើយបានចែកចាយឈើច្រត់ចំនួន ៩៧២ និង រទេះរុញចំនួន ១២២ រទេះ។ ARC ក៏បានសហការជាមួយមជ្ឈមណ្ឌលជនពិការជាតិ (NCDP) លើគំរោងដែលបញ្ចូលការស្តារនៅតាមសហគមន៍, ជំនួយចិត្តសាស្ត្រសង្គម, ការបណ្តុះបណ្តាលការងារ និង បង្វែក[128] ។

Cambodia Trust បានបើកគ្លីនិកដំបូងរបស់ខ្លួននៅឆ្នាំ១៩៩២ ហើយឥឡូវនេះបានផ្តល់សេវាកម្មស្តាររាងកាយនៅមជ្ឈមណ្ឌលនានាក្នុងទីក្រុងភ្នំពេញ, ក្រុងព្រះសីហនុ និង ខេត្តកំពង់ឆ្នាំង ។ មជ្ឈមណ្ឌលទាំងនេះផ្តល់សេវាកម្ម ព្យាបាលដោយការហាត់ប្រាណ ផលិត និង តំឡើងអវៈយវៈសិប្បនិម្មិត និង ឧបករណ៍ជំនួសរាងកាយ និង ចែកចាយរទេះរុញ។ ចាប់ពីឆ្នាំ ១៩៩៩ មក មជ្ឈមណ្ឌលទាំងបីបានតំឡើងឧបករណ៍ជំនួសសរីរាង្គដែលកាត់ចោលចំនួន ៥.២៧៨ រាប់ទាំងចំនួន ៨៨៥ ក្នុងឆ្នាំ ២០០៣ សំរាប់អ្នកដែលមានជីវិត ពីគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ។ នៅឆ្នាំ២០០៣ មជ្ឈមណ្ឌលនេះក៏បានផលិតឧបករណ៍ជំនួសរាងកាយចំនួន១២២៦សំរាប់ និងបានចែកចាយឈើច្រត់ចំនួន៧០៦សំរាប់ និងរទេះរុញចំនួន៨៦រទេះ ។ Cambodia Trust ក៏បានប្រតិបត្តិការជាកម្មវិធីដល់ទីកន្លែងផងដែរ ដើម្បីចូលជួយដល់ជនពិការនៅតំបន់ជនបទដាច់ស្រយាល ដោយផ្តល់សេវាកម្មដល់ពេទ្យបង្វែកសំរាប់សេវាកម្មវះកាត់ និង ព្យាបាលជំងឺ ការស្តារ ដែលមានមូលដ្ឋាននៅតាមសហគមន៍ និង ការលើកតំកើងចំណេះដឹងស្តីពីបញ្ហាជនពិការ។ នៅឆ្នាំ ២០០៣, Cambodia Trust បានទូទាត់ថ្លៃវះកាត់ដល់អ្នកនៅមានជីវិតពីគ្រាប់មីនចំនួន៩៩ នាក់ ហើយក្រុមជួយខ្លួនឯងនៅតាមសហគមន៍ចំនួន២៣ក្រុម ត្រូវបានបង្កើតឡើង។ នៅឆ្នាំ១៩៩៩ Cambodia Trust បានចាប់ផ្តើមគំរោងបណ្តុះបណ្តាលដល់ទីកន្លែង ដើម្បីសំរួលដល់ការទទួលយកការបណ្តុះបណ្តាល ការអប់រំ ឱកាសធ្វើការងារ និង ផ្តល់ជំនួយធុនតូច និង កម្មវិធីកម្ចីឥណទានខ្នាតធំ (Macro-Credit) ដើម្បីបង្កើតពាណិជ្ជកម្មខ្នាតតូច ។ CT ប្រើប្រាស់

[128] Response to LM Questionnaire by ARC; ARC, "Helping Cambodia's Disabled," 30 January 2003; DAC, "Country Profile: Study on Persons with Disabilities (Cambodia)," February 2001, p. 45; see also previous editions of the *Landmine Monitor Report*.

បុគ្គលិក ១០៤ នាក់ ក្នុងប្រទេសកម្ពុជាប្រហែល ២២ ភាគរយ ជាជនពិការ[129] ។

មជ្ឈមណ្ឌលស្តាររាងកាយរបស់ Cambodia Trust នៅក្រុងភ្នំពេញក៏ជាគ្លីនិកបង្រៀនសំរាប់សាលា Prosthetic និង Orthotics កម្ពុជា (CSPO) ដែលបង្កើតឡើងដោយ CT នៅឆ្នាំ ១៩៩៤ ដើម្បីផ្តល់ការបណ្តុះបណ្តាលបច្ចេកទេសក្នុងការជំនួសសរីរាង្គដែលកាត់ចោល/ជំនួសរាងកាយសំរាប់ប្រទេសកម្ពុជានិងក្នុងតំបន់ ។ រៀងរាល់ឆ្នាំសិស្សថ្មីចំនួន ១២ នាក់ បានចាប់ផ្តើមកម្មវិធីបណ្តុះបណ្តាលរយៈពេល ៣ ឆ្នាំ រួមទាំងសិស្សមកពីប្រទេសអាហ្វហ្គានីស្ថាន, ភូមា, ឡាវ, ស្រីលង្កា, និង ទីម័រ (Timor Leste) ។ សិស្សជាង ៨០ នាក់ បានប្រលងចេញចាប់ពីពេលសាលានេះបានបើកមក ។ CSPO លើកទឹកចិត្តដល់សិក្ខាកាមជានារីភេទ ដើម្បីពង្រីកសេវាកម្មសំរាប់ស្ត្រីពិការ ។ នៅឆ្នាំ ១៩៩៩ CSPO ទទួលបានការសរសើរពី ISPO ហើយគឺជាមជ្ឈមណ្ឌលមួយក្នុងចំណោមមជ្ឈមណ្ឌលបណ្តុះបណ្តាល Category II ដែលមានតែ ៤គត់ ក្នុងពិភពលោក[130] ។ ការព្យាបាលដោយការហាត់ប្រាណ ត្រូវបានបណ្តុះបណ្តាលនៅសាលាបច្ចេកទេសថែរក្សាសុខភាព(TSMC)ដោយមានការបណ្តុះបណ្តាលជាពិសេសបានផ្តល់អោយផងដែរនូវមជ្ឈមណ្ឌលស្តាររាងកាយនានា[131] ។

អង្គការ Handicap International (HI) បានចាប់ផ្តើមការងារនៅប្រទេសកម្ពុជាក្នុងឆ្នាំ១៩៨១ ដោយមានកម្មវិធីជាច្រើនក្នុងការស្តាររាងកាយ, សមាហរណកម្មសេដ្ឋកិច្ចសង្គម, ប្រមូលពត៌មានទិន្នន័យ, កសាងសមត្ថភាព និងលើកតំឡើងចំណេះដឹងអំពីសិទ្ធិនិងតំរូវការរបស់ជនពិការ ។ នៅឆ្នាំ២០០៣ អង្គការ HI បានឧបត្ថម្ភដល់មជ្ឈមណ្ឌលស្តាររាងកាយក្នុងខេត្តបន្ទាយមានជ័យ, កំពង់ចាម, កំពង់ធំ, សៀមរាប និង តាកែវ ដោយផ្តល់នូវសេវាកម្មព្យាបាលដោយការហាត់ប្រាណ, ឧបករណ៍ជំនួសសរីរាង្គសិប្បនិម្មិត និង ឧបករណ៍ជំនួយដទៃទៀត កម្មវិធីបណ្តុះបណ្តាលដល់ទីកន្លែង ការបណ្តុះបណ្តាលពេលធ្វើការសំរាប់អ្នកបច្ចេកទេស និង អ្នកព្យាបាលដោយចលនា ។ នៅឆ្នាំ ២០០៣ HI បានជួយប្រជាពលរដ្ឋចំនួន ៦.២៤៨ នាក់ រួមទាំងអ្នកនៅមានជីវិតពីគ្រាប់មីន ចំនួន ៣.០០៧ នាក់ ។ ចាប់ពីឆ្នាំ ១៩៩៩ មក មជ្ឈមណ្ឌលដែលឧបត្ថម្ភដោយ HI បានផលិតឧបករណ៍ជំនួសសរីរាង្គកាត់ចោល ចំនួន ៧.៦៨៦ សំរាប់ រាប់ទាំង ១.២៧១ សំរាប់ នៅឆ្នាំ ២០០៣ ។ មជ្ឈមណ្ឌលនេះក៏បានចែកចាយនូវឈើច្រត់ ចំនួន ១.៣៦៤ សំរាប់ កៅអីរុញចំនួន ២១៤ កៅអី និង ទោចក្រយានកង់ ៣ ចំនួន ១៦០ នៅឆ្នាំ ២០០៣ ។ មជ្ឈមណ្ឌលស្តារនៅខេត្តកំពង់ធំនិង បន្ទាយមានជ័យ ឥឡូវនេះបានបិទទ្វារដោយសារមូលហេតុសនិទានកម្មសេវាកម្ម និងផ្តោតអារម្មណ៍ខ្លាំងលើការគ្រប់គ្រងគុណភាព និង និរន្តរភាព ។ កម្មវិធីស្តារដែលមានមូលដ្ឋាននៅតាមសហគមន៍របស់ អង្គការ HI ផ្តោតការលើកទឹកចិត្តលើការតាមដានសុខភាព ជំនួយចិត្តសាស្ត្រសង្គម សំរាលភាពក្រីក្រ និង សមាហរណកម្មសេដ្ឋកិច្ចសង្គមរបស់ជនពិការ តាមរយៈក្រុមជួយខ្លួនឯងនិងបញ្ជូន ចំពោះកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និង កម្មវិធី

[129] Response to LM Questionnaire by Pith Sokra, CT, Phnom Penh, 27 January 2004; The Cambodia Trust, "Annual Report 1999-2000," p. 7; DAC, "Country Profile: Study on Persons with Disabilities (Cambodia)," February 2001, p. 45; Cambodia Trust website, www.cambodiatrust.com; see also previous editions of the *Landmine Monitor Report*.

[130] DAC, "Cambodia 2003," pp. 10-11; The Cambodia Trust, "Annual Report 2002-2003," p. 9.

[131] DAC, "Cambodia 2003," pp.10-11.

ជំនួយខ្នាតតូច ។ អង្គការ HI ក៏បានឧបត្ថម្ភដល់ក្លិបកីឡា ២ របស់ជនពិការ នៅខេត្តបាត់ដំបង និង សៀមរាប និង គ្រប់គ្រងមណ្ឌលស្តាររាងកាយបារ៉ាតេត្រា (Para-Tetra) ក្រុម ស្តារសរសៃខួរឆ្អឹងខ្នងនៅខេត្តបាត់ដំបង [132] ។

អង្គការ Veterans International (VI) ដែលចូលមកប្រទេសកម្ពុជាពីឆ្នាំ១៩៩១ បានប្រតិបត្តិការមជ្ឈមណ្ឌលស្តាររាងកាយ ៣ រួមមានមជ្ឈមណ្ឌលស្តាររាងកាយជាតិគៀនឃ្លាំងនៅក្រុងភ្នំពេញ និង មជ្ឈមណ្ឌលនៅតាមខេត្តមួយចំនួនដូចជា ខេត្តក្រចេះ (បើកនៅ ឆ្នាំ ២០០០) និង ខេត្តព្រៃវែង មជ្ឈមណ្ឌលតូចមួយនៅខេត្តព្រះវិហារ បានបិទនៅខែ តុលា ឆ្នាំ ២០០៤ ។ មជ្ឈមណ្ឌលទាំងនេះផ្តល់សេវាកម្ម ដោយការហាត់ប្រាណ ផលិតកម្ម និង តំឡើងឧបករណ៍ជំនួសសរីរាង្គសិប្បនិម្មិត និង ឧបករណ៍ជំនួសរាងកាយ និង រទេះរុញ ព្រមទាំងឧបករណ៍ជំនួយដទៃទៀត ។ កម្មវិធីនេះរួមមានកម្មវិធីស្តារ ដែលមានមូលដ្ឋាននៅតាមសហគមន៍ ក្រុមផ្តល់សេវាកម្មដល់ទីកន្លែង និង បញ្ជូនដល់សេវាកម្មដទៃទៀត ។ ចាប់ពីឆ្នាំ ១៩៩៩ VI បានតំឡើងឧបករណ៍ជំនួសសរីរាង្គសិប្បនិម្មិត ចំនួន ៥.៣៣៣ សំរាប់ រួមទាំងចំនួន ៨៧៥ សំរាប់ នៅឆ្នាំ ២០០៣ ។ VI ក៏បានផលិតឧបករណ៍ជំនួសរាងកាយ ចំនួន ១.៩៦៥ សំរាប់ និង ឈើច្រត់ ចំនួន ៤២៥ សំរាប់ នៅឆ្នាំ ២០០៣ ។ ចាប់ពីឆ្នាំ ១៩៩៩ មក VI បានផលិត និង ចែកចាយរទេះរុញ ចំនួន ២.២៦៨រទេះ រួមទាំង ៤៨០រទេះ នៅឆ្នាំ ២០០៣ ។ នៅខែ មិនា ឆ្នាំ ២០០៤ VI បានធ្វើជាដៃគូជាមួយរោងជាងបច្ចេកទេសអភិវឌ្ឍន៍ ដើម្បីជំរុញផលិតកម្មរទេះរុញទៅជា *សួនបណ្តុះពាណិជ្ជកម្ម* (*Business Incubation Park*) ដែលមានគោលបំណងបំលែងផលិតកម្មនេះទៅជាមុខព្រួញសេដ្ឋកិច្ចឯកជនក្នុងរយៈពេល២ឆ្នាំក្រោយ ។ អង្គការ VI នឹងបន្តចាត់គ្រប់គ្រងរោងជាងនេះក្នុងកំឡុងពេលអន្តរកាល ។ អង្គការ VI រាយការណ៍ថា ខ្លួននឹងបង្វែរកម្មវិធីរទេះរុញចូលទៅរោងជាងបច្ចេកទេសអភិវឌ្ឍន៍នៅខែមិនា ឆ្នាំ២០០៤ ។ អង្គការ VI ក៏បានឧបត្ថម្ភដល់កម្មវិធី "កីឡាសំរាប់ជីវិត " សំរាប់ជនពិការផងដែរ [133] ។ គំរោងនេះ កំពុងត្រូវបានធ្វើអោយក្លាយជាគំរោងឯកជននៅចុងឆ្នាំ២០០៤ ដោយសង្ឃឹមថានឹងបន្តជាសហគ្រាសខ្នាតតូចប្រកបដោយភាពជោគជ័យ ។ អង្គការ VI ក៏បានឧបត្ថម្ភផងដែរដល់គំរោងបាល់ទះកីឡាសំរាប់ជីវិត ដែលឥឡូវនេះកំពុងប្រតិបត្តិការជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដោយប្រើប្រាស់មូលនិធិខ្លួនឯងផ្ទាល់ [134] ។

សមាគមជំនួយ និង សង្គ្រោះបន្ទាន់ជប៉ុន (AAR) បានបង្កើតសេវាកម្មផលិតកម្មរទេះរុញក្នុងក្រុងភ្នំពេញ នៅឆ្នាំ ១៩៩៤ ។ ចាប់ពីឆ្នាំ ១៩៩៩ មក, AAR បានផលិត និង ចែកចាយរទេះរុញ ចំនួន ១.៥២៤ រទេះ រួមទាំងចំនួន ២៥៤ រទេះ នៅឆ្នាំ ២០០៣ ដែល ១៨ រទេះ សំរាប់អ្នកនៅមានជីវិតពីគ្រាប់មីន[135] ។ សមាគមជំនួយនិងសង្គ្រោះបន្ទាន់ជប៉ុនបានបើកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈគៀនឃ្លាំងក្នុងក្រុងភ្នំពេញនៅឆ្នាំ១៩៩៣ ។

---

[132] Response to LM Questionnaire by Edith van Wijngaarden, HI Cambodia, 25 March 2004; HI, "Activity Report 2003," Brussels, 15 July 2004, pp. 19-20; HI, "Program Summary: Cambodia 2004," 7 December 2003; interview with Marc Hermant, HI, 12 January 2004; see also previous editions of the *Landmine Monitor Report*.

[133] DAC, "Cambodia 2003," p. 34. Veterans International is also known as Vietnam Veterans of America Foundation.

[134] Email from Larrie Warren, VVAF, 16 September 2004; DAC, "Cambodia 2003," p. 34.

[135] Tith March, AAR Japan, response to LM Questionnaire, 16 February 2004.

មជ្ឈមណ្ឌលនេះផ្តល់កម្មវិធីបណ្តុះបណ្តាលរយៈពេល ១ ឆ្នាំ ដល់ជនពិការក្នុងទីក្រុងភ្នំពេញ និង ខេត្តជុំវិញ ចំនួន៩ ។ ការបណ្តុះបណ្តាលនេះផ្តល់ចំណេះដឹងអក្សរសាស្ត្រជាមូលដ្ឋាន ជួសជុលវិទ្យុ ទូរទស្សន៍ ជួសជុលម៉ូតូនិងកាត់ដេរ ។នៅឆ្នាំ២០០៣ មនុស្សចំនួន៤០នាក់ ទទួលបានការបណ្តុះបណ្តាលរួមមាន១៤នាក់ ជាអ្នកនៅមានជីវិតពីគ្រាប់មីន[136] ។

អង្គការ Jesuit Services Cambodia (JS) បានផលិតរទេះរុញ ចំនួន ៥.០០៩ រទេះ ចាប់ពីឆ្នាំ ១៩៩៩ ដែលរចនាឡើងជាពិសេសសំរាប់លក្ខខ័ណ្ឌក្នុងតំបន់ រួមទាំង ១.០៤៦ រទេះ នៅឆ្នាំ២០០៣ ។ រទេះរុញរបស់ JS ត្រូវបានចែកចាយដោយ ARC, ICRC, HI និង CT នៅឆ្នាំ ២០០៣ JS បានចែករទេះរុញចំនួន ២៤៥ រទេះ។ អង្គការ JS ក៏បានផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈនៅសាសាបន្ទាយព្រាប (មជ្ឈមណ្ឌលព្រាប) ។ មុនពេលចូលរួមវគ្គសិក្សានេះសិស្សជាច្រើនបានចំណាយពេល ៣ខែ ដើម្បីទទួលបានជំនាញអក្សរសាស្ត្រ គ្រូណែនាំមួយចំនួនជាអតីតសិស្សរួមទាំងអ្នកពិការដោយសារគ្រាប់មីន។ នៅឆ្នាំ ២០០៣ សិស្សពិការចំនួន ១៤៥ នាក់ បានទទួលនូវការបណ្តុះបណ្តាលរយៈពេល ១ ឆ្នាំ ក្នុងជំនាញកសិកម្ម ចំលាក់ ជាងឈើ ជួសជុលគ្រឿងអេឡិចត្រូនិច ជួសជុលម៉ាស៊ីនតម្បាញ កាត់ដេរ សំលៀកបំពាក់ និង អក្សរសាស្ត្រ ។ ចាប់ពីឆ្នាំ ១៩៩៩ មក សិស្សជាង ៧០០ នាក់ បានទទួលការបណ្តុះបណ្តាល។ អង្គការ JS ក៏បានធ្វើការជាមួយសហគ្រាសដែលរងគ្រោះដោយសារគ្រាប់មីននៅស្រុករតនៈមណ្ឌល, ស្រុកអូរជ្រៅ និង ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ នៅខេត្តសៀមរាប តំបន់មួយចំនួនក្នុងខេត្តឧត្តរមានជ័យ និង នៅក្នុងតំបន់ខ្មែរអតីតក្រហមខេត្តកណ្តាល។ ក្រុមមេត្តាករុណា (Metta Karuna Teams) ដែលរួមមានបុគ្គលិកជាអ្នកពិការដោយសារគ្រាប់មីនមួយចំនួន បានផ្តល់ការគាំទ្រផ្នែកចិត្តសាស្ត្រសង្គមដល់អ្នកភូមិ និងជួយពួកគេធ្វើគំរោងកម្មវិធីសំរាប់សុខុមាលភាព និង សុភាពរបស់គេ ។ កម្មវិធីនេះរួមមានការសង់ផ្ទះសំបែងការប្រើប្រាស់ទឹក ម្ហូបអាហារបន្ទាន់ ជំនួយសាលារៀនសំរាប់ក្មេងៗ និង សិទ្ធិទទួលបានសេវាកម្មសុខភាពនិងទីផ្សារតាមរយៈស្ពាននិងថ្នល់។ នៅក្នុងសហគមន៍មួយចំនួនដែលអង្គការ JS កំពុងប្រតិបត្តិការ អ្នកពិការដោយសារគ្រាប់មីនគឺជាអ្នកដឹកនាំភូមិ គ្រូបង្រៀន បុគ្គលិកអភិវឌ្ឍន៍ និង បុគ្គលិកសុខភាព ។

មជ្ឈមណ្ឌលជាតិជនពិការ (NCDP) បានប្រតិបត្តិការកម្មវិធីស្តារ ដែលមានមូលដ្ឋាននៅតាមភូមិដោយផ្តល់នូវកម្មវិធីស្តារនៅតាមផ្ទះ ជំនួយចិត្តសាស្ត្រសង្គម តាមរយៈក្រុមមនុស្សដែលមានវ័យស្របាលគ្នា និង សំរួលសិទ្ធិទទួលបានសេវាកម្ម និង ឱកាសសេដ្ឋកិច្ចសង្គម ។ មជ្ឈមណ្ឌលជនពិការជាតិ (NCDP) ក៏បានផ្តល់ការអប់រំ និងការហូបចុក ស្នាក់នៅ សំរាប់ក្មេងៗពិការផងដែរ[137] ។

នៅខែ មករា ឆ្នាំ ២០០៣ សេវាកម្មអភិវឌ្ឍន៍ជនពិការ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ប្រចាំខេត្តពោធិសាត់ (DDSP) ត្រូវបានបង្កើតឡើងនៅខេត្តពោធិសាត់ ដែលមានគោលបំណងពង្រីកគុណភាពជីវភាពរស់នៅរបស់ជនពិការក្នុងតំបន់នោះ។ DDSP បានផ្តល់សេវាកម្មស្តាររាងកាយរួមមានការព្យាបាលដោយហាត់ប្រាណ រទេះ

---

[136] Daisuke Sagiya, Country Representative, AAR, questionnaire submitted for “Portfolio of Socio-Economic Reintegration Projects,” 31 August 2004.

[137] DAC, “Cambodia 2003,” pp. 16, 27-28.

រុញ និង ឧបករណ៏ជំនួយដទៃទៀតនិងបញ្ជូនដល់សេវាកម្មដទៃទៀត ។ DDSP ក៏បានផ្តល់ជំនួយចិត្តសាស្ត្រសង្គម សំរួលដល់ការអប់រំសំរាប់ក្មេងៗ និង ការបណ្តុះបណ្តាលវិជ្ជាជីវៈ និង លើកតំកើងចំណេះដឹងស្តីពីបញ្ហាជនពិការ ។ នៅឆ្នាំ ២០០៣, DDSP បានបង្ហាញអ្នកនៅមានជីវិតពីគ្រាប់មីនចំនួន ៧នាក់ សំរាប់ការព្យាបាលនៅមន្ទីរពេទ្យ ហើយប្រហែល ៧០នាក់ បានទទួលផលប្រយោជន៏ពីកម្មវិធី ដែលមានមូលដ្ឋាននៅតាមសហគមន៏នេះ ប្រហែល ១/៣ ជាអ្នកនៅមានជីវិតពីគ្រាប់មីន [138] ។

កម្មវិធីរបស់អង្គការបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការខ្មែរដោយសារសង្គ្រាម （CWARS） បានផ្តល់អោយអ្នកនៅមានជីវិតពីគ្រាប់មីន និង ជនពិការដទៃទៀតនូវការបណ្តុះបណ្តាលក្នុងការបង្កើតប្រាក់ចំណូល និង សេវាកម្មដទៃទៀត ។ អ្នកដែលបានរៀនចប់កម្មវិធីនេះត្រូវបានជួយបង្កើតពាណិជ្ជកម្មសហគ្រាសម៉ាក្រូផ្ទាល់ខ្លួនដោយសំរួលអោយពួកគេសំរេចបាននូវស្វ័យទំនុកចិត្ត និងឯករាជ្យភាពក្នុងខ្លួន ។ នៅឆ្នាំ ២០០២ ជនពិការចំនួន ៥៤៣ នាក់ បានទទួលការបណ្តុះបណ្តាលនេះ [139] ។

នៅឆ្នាំ២០០០ សមាគមសិប្បកម្មកម្ពុជា សំរាប់ជនពិការដោយគ្រាប់មីន និងជំងឺស្វិតដៃជើង ត្រូវបានបង្កើតឡើងដើម្បីបង្កើតការបណ្តុះបណ្តាលផ្នែកពាណិជ្ជកម្ម និងជំនាញ ដើម្បីផលិតនិងលក់របស់របរដែលផលិតបានរួមមានៈ កាបូបប្រុស, កាបូបស្រី, ក្រម៉ាសូត្រ, ប័ណ្ណបដិសណ្ឋារកិច្ចនិង របស់របរប្រើប្រាស់នៅតាមផ្ទះ ។ ចាប់ពីឆ្នាំ២០០០មក ជនពិការចំនួន ៧៧ នាក់ រួមទាំងអ្នកនៅមានជីវិតពីគ្រាប់មីន ចំនួន ៦៧នាក់ បានទទួលផលប្រយោជន៏ពីកម្មវិធីនេះ មនុស្សចំនួន២៩នាក់ រួមមានអ្នកនៅមានជីវិតពីគ្រាប់មីនចំនួន ១៣នាក់ ត្រូវបានបណ្តុះបណ្តាលនៅឆ្នាំ២០០៣ ។ សមាគមនេះខ្វះខាតមូលនិធិដើម្បីពង្រីកសកម្មភាពរបស់ខ្លួន គឺដើម្បីផ្តល់ជាប្រាក់កម្ចីខ្នាតតូចដល់សិក្ខាកាម ដែលទើបនឹងបញ្ចប់វគ្គបណ្តុះបណ្តាលនេះ [140] ។

នៅឆ្នាំ ២០០១ អង្គការ Clear Path International ក្នុងភាពជាដៃគូជាមួយអង្គការអ្នកស្ម័គ្រចិត្តអភិវឌ្ឍន៏សហគមន៏កម្ពុជា (CVCD) បានចាប់ផ្តើមកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈមួយនៅក្នុងក្រុងភ្នំពេញ និង នៅមជ្ឈមណ្ឌលចែកចាយការបណ្តុះបណ្តាលនៅខេត្តកំពង់ចាមដល់សមាជិកគ្រួសារ ឬ អ្នកនៅមានជីវិតពីគ្រាប់មីនជាច្រើននាក់ ។ ការបណ្តុះបណ្តាលនេះបានផ្តល់ចំណេះដឹងនិងជំនាញមួយចំនួនដូចជាៈអក្សរសាស្ត្រអង់គ្លេស, ការបញ្ចូលពតិមានកុំព្យូទ័រ, ការជួសជុលកុំព្យូទ័រ, ការរចនាម៉ូដសំលៀកបំពាក់ និង កាត់ដេរ ជួសជុលឧបករណ៏អេឡិចត្រូនិច និង ការជួសជុល គ្រឿងម៉ាស៊ីនធុនតូច ។ នៅឆ្នាំ ២០០៣ មនុស្សប្រហែល ៩០ នាក់ បានទទួលការបណ្តុះបណ្តាលនេះរាប់ទាំង ៥០នាក់ ជាអ្នកនៅមានជីវិតពីគ្រាប់មីន ។ ចាប់តាំងពីកម្មវិធីនេះបានចាប់ផ្តើមមនុស្សចំនួន ១៥០ នាក់

[138] Response to LM Questionnaire by Steve Harknett, Consultant, DDSP, 10 July 2004, and email, 6 September 2004.

[139] Response to LM Questionnaire by Sam Oeurn Pok, Cambodian War Amputees Rehabilitation Society, Phnom Penh, 14 February 2003.

[140] Hay Kim Tha, Director, CHA, questionnaire submitted for "Portfolio of Socio-Economic Reintegration Projects," 2 September 2004.

រួមទាំងអ្នកនៅមានជីវិតគ្រាប់មីនចំនួន ១០០ នាក់ បានទទួលផលប្រយោជន៍ពីកម្មវិធីនេះ ហើយឥឡូវនេះប្រហែល ៨០ ភាគរយ បានចូលរួមក្នុងសកម្មភាពបង្កើតប្រាក់ចំណូល ។ នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលស្ទឹងត្រង់ គឺជាអ្នកនៅមានជីវិតពីគ្រាប់មីន[141] ។

រោងជាងបច្ចេកទេសអភិវឌ្ឍន៍ (DTW) បានជួយបង្កើតរោងជាងធ្វើម៉ាស៊ីនដោះមីនកម្ពុជា (Cambodian Demining Workshop) ជាពាណិជ្ជកម្មខ្នាតតូច ដែលគ្រប់គ្រងដោយជនជាតិខ្មែរ ដែលប្រើប្រាស់បុគ្គលិកជាជនពិការប្រហែល ២០នាក់ និង ជួយផលិតឧបករណ៍ដោះមីនជាច្រើន ។ រោងជាងបច្ចេកទេសអភិវឌ្ឍន៍ក៏បានផលិត និងនាំចេញនូវ Tempest ជាឧបករណ៍បញ្ជាពីចម្ងាយធុនតូច ម៉ាស៊ីនបោសសំអាត និង ម៉ាស៊ីនកាត់រុក្ខជាតិ [142] ។

នៅឆ្នាំ ១៩៩៩ World Rehabilitation Fund បានអនុវត្តកម្មវិធីរយៈពេល ៣ ឆ្នាំមួយក្នុងភាពជាដៃគូជាមួយ UNDP ដើម្បីជំរុញសមាហរណកម្មសេដ្ឋកិច្ចសង្គមរបស់អ្នកនៅមានជីវិតពីគ្រាប់មីន ។ កម្មវិធីនេះទទួលបានជោគជ័យក្នុងការបង្កើតសមាគមសិប្បករកម្ពុជា (Artisans Association of Cambodia) ដោយមានកិច្ចសហការជាមួយអង្គការកុមារដែលទទួលរងគ្រោះដោយគ្រាប់មីន (CAM), អង្គការ Marynoll, អង្គការ NCDP, អង្គការ RehabCraf និងអង្គការ VI ។ ក្រុមប្រឹក្សាផ្តល់ដំបូន្មានអំពីពាណិជ្ជកម្ម (BAC) ក៏ត្រូវបានបង្កើតផងដែរ ដើម្បីអនុវត្តកម្មវិធីមួយក្នុងគោលបំណងបង្កើតការងារសំរាប់អ្នកនៅមានជីវិតពីគ្រាប់មីននិងជនពិការដទៃទៀត [143] ។

អង្គការ World Vision បានផ្តល់ការបណ្តុះបណ្តាលផ្នែកពាណិជ្ជកម្ម និង កសិកម្ម ក្នុងខេត្តបាត់ដំបង ហើយបានសន្មត់ទទួលខុសត្រូវលើអតីតកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈរបស់អង្គការ Marynoll ក្នុងវត្តថាន់ ក្រុងភ្នំពេញ ដែលមានសិស្ស ២៣៧ នាក់ បានទទួលផលប្រយោជន៍ពីកម្មវិធីនេះនៅឆ្នាំ ២០០៣ [144] ។

ក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) បានចុះបញ្ជីឈ្មោះអង្គការដទៃទៀតជាច្រើន ដែលជួយដល់អ្នកនៅមានជីវិតពីគ្រាប់មីន និងជនពិការដទៃទៀតតាមរយៈក្រុមជួយខ្លួនឯងជំនួយដែលមានមូលដ្ឋាននៅតាមសហគមន៍ ប្រព័ន្ធបញ្ជូន ការអប់រំ ការប្រឹក្សាយោបល់ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និង ការផ្តល់សេវាកម្មដល់ទីកន្លែង ។ គណៈកម្មាធិការសេវាកម្មមិត្តភាពអាមេរិក (American Friends Service Committee) បានផ្តល់សេវាកម្មបង្អែក និង វិធីព្យាបាលរោគរាងកាយដល់ជនពិការ និងគ្រួសាររបស់គេ ចំនួនភាគរយតិចតួចនៃអ្នកទទួលផលគឺជាអ្នកនៅមានជីវិតពីគ្រាប់មីន [145] ។ អង្គការ Caritas Cambodia (CC) បានសំរួលការវះកាត់ភ្នែកដល់អ្នកនៅមានជីវិតពិការភ្នែកដោយគ្រាប់មីនចំនួន ៤នាក់ និង សេវាកម្មស្តារដល់មនុស្ស ១៨ នាក់ ផ្សេងទៀតនៅខេត្តកណ្តាល, តាកែវ, កំពង់ស្ពឺ និង ខេត្តកំពត ។ Caritas Cambodia ក៏បានជួយដល់គ្រួសារអ្នកនៅមានជីវិតដែលពិការភ្នែកចំនួន ១២

[141] Imbert Matthee, President, Clear Path International, questionnaire submitted for "Portfolio of Socio-Economic Reintegration Projects," 31 August 2004; Response to LM Questionnaire by Sothea Aroun, Cambodian Volunteers for Community Development, Phnom Penh, 28 February 2003.

[142] DTW brochure from Guy Craft, Vol. 1, Issue 2, Phnom Penh, 22 October 2001.

[143] For more details see WRF, "The Socio-Economic Reintegration of Landmine Survivors: Lebanon, Mozambique, Cambodia," New York, 2003, pp. 4-7.

[144] Response to LM Questionnaire by Sarah Bearuph, Mine Program Manager, World Vision, 12 February 2004

[145] Response from Roath Leakhana, Country Representative, AFSC, 11 January 2002.

នាក់ [146]។ អង្គការ Children Affected by Mines ដែលជាអង្គការក្រៅរដ្ឋាភិបាលបានជួយក្មេងនៅមានជីវិតពីគ្រាប់មីន អោយទទួលបានការថែទាំសុខភាព ជំនួយស្ដារ និង ចិត្តសាស្ត្រសង្គម ២៦ នាក់ ត្រូវបានជួយនៅឆ្នាំ ២០០២ និង ១៨៤នាក់ នៅឆ្នាំ ២០០១[147]។ អង្គការផ្សេងៗទៀតរួមមាន Action for Disability and Development(ADD),មជ្ឈមណ្ឌលអារ៉ូបប៉េខេត្តបាត់ដំបង (Arrupe Centre Battambang), សមាគមជនពិការកម្ពុជា (CDPA), អង្គការ Operation Enfants de Battambang, អង្គការ Servants, អង្គការគ្រួសារថ្មី, អង្គការ Marist Mission អូស្ត្រាលី, អង្គការ Help Age International និង សេវាសង្គមកម្ពុជា[148]។

គោលការណ៍មួយទៀតដើម្បីជួយដល់អ្នកនៅមានជីវិតក្នុងប្រទេសកម្ពុជាគឺ "គោលការណ៍អភិវឌ្ឍន៍" ដែលផ្ដោតការយកចិត្តទុកដាក់លើសហគមន៍ ដែលរងគ្រោះដោយគ្រាប់មីនរួមទាំងអ្នកនៅមានជីវិតដោយគ្រាប់មីនផងដែរ ។ ជារឿយៗសហគមន៍ទាំងនេះ គឺជាដែនដីព្រំដែនដែលប្រជាពលរដ្ឋតាំងនៅជាថ្មីដើម្បីចាប់ផ្ដើមជីវិតថ្មី។ គោលបំណងនៃគោលការណ៍អភិវឌ្ឍន៍នេះគឺផ្ដល់ដីធ្លីសំរាប់ការដាំដុះដំណាំ ផ្លូវថ្នល់ ស្ពាន អណ្ដូងទឹក សាលារៀន មណ្ឌលសុខភាព និង ជំនួយបង្កើតប្រាក់ចំណូលមួយចំនួនបន្ទាប់ពីសកម្មភាពបោសសំអាតគ្រាប់មីន ។ អ្នកនៅមានជីវិតពីគ្រាប់មីន ត្រូវបានជួយជាមួយសមាជិកសហគមន៍ដទៃទៀត ក្នុងគោលការណ៍អភិវឌ្ឍន៍ដែលបានបញ្ចូលនេះ ។ ទីភ្នាក់ងារនានាដែលកំពុងធ្វើការក្នុងគោលការណ៍បញ្ចូលនេះរួមមាន : អង្គការ CARE, AUSTCARE, World Vision, Lutheran World Federation និង អង្គការ JS ។

ទិន្នន័យពតិមានដែលប្រមូលបានដោយអង្គការ Jesuit Services Cambodia ជាផ្នែកមួយនៃកម្មវិធីនៅតាមទីកន្លែងរបស់ខ្លួនក្នុងឆ្នាំ ១៩៩៩ និង ២០០០ ក្នុងខេត្តបាត់ដំបង ឧត្តរមានជ័យ បន្ទាយមានជ័យ សៀមរាប និង តំបន់ជុំវិញខេត្តកំពង់ស្ពឺបានបង្ហាញថា អ្នកនៅមានជីវិតចំនួន ១.៦៦៣ នាក់ ដែលបានធ្វើសម្ភាសគឺ : ៧១ ភាគរយ មិនមានផ្ទះសម្បែងគ្រប់គ្រាន់, ៧ ភាគរយ មិនមានផ្ទះទាល់តែសោះ, ៤៥ ភាគរយ ត្រូវធ្វើដំណើរជាង ៥ នាទី ដើម្បី ទទួលបានទឹកផឹកនិងប្រើប្រាស់, ៨៩ភាគរយ បានរាយការណ៍អំពីខ្វះខាតម្ហូបអាហារ, ៣២ភាគរយ មិនមានដីសំរាប់ សង់ផ្ទះឬបង្កបង្កើនផល, ២៨ភាគរយ ទទួលបានប្រាក់សោធននិវត្តន៍របស់រដ្ឋាភិបាល, ៥០ភាគរយ "មានការងារ" ធ្វើ(រួមទាំងការដាំដុះស្រូវ)ហើយក្មេងៗយ៉ាងហោច ៤៦ភាគរយ មិនបានទៅសាលារៀនឡើយ (149)។ ដោយផ្អែក លើការរកឃើញទាំងនេះអ្នកនៅមានជីវិតដោយគ្រាប់មីន បានបង្កើតគំរោងមួយមាន ១២ចំណុច ដែលបង្ហាញអំពី តំរូវការរបស់គេនិងអ្នកនៅក្នុងសហគមន៍របស់គេ។ អាទិភាពរបស់គេរួមមាន: ទីជំរកគ្រប់គ្រាន់ ម្ហូបអាហារគ្រប់គ្រាន់និងទឹកគ្រប់គ្រាន់មានការងារឬលទ្ធភាពបង្កើតប្រាក់ចំណូលសិទ្ធិទទួលបានការថែរក្សាសុខភាព ឧបករណ៍ជំនួយនិងស្ដារ ដែលពួកគេអាចលៃលកបានសាលារៀនសំរាប់កូនចៅគេ និង ឱកាសសំរាប់មនុស្សពេញវ័យ រៀនសូត្រនូវជំនាញថ្មីៗ។ អង្គការ JS បច្ចុប្បន្ននេះ កំពុងទទួលរ៉ាប់រងលើការស្ទាបស្ទង់តាមដាន ដើម្បីកំណត់ថា តើស្ថានភាពរបស់អ្នកនៅមានជីវិតពីគ្រាប់មីនបានពង្រីកដែរឬអត់ក្នុងរយៈពេល ៤ ឆ្នាំមុន ។ លទ្ធផលដំបូងពីការស្ទាបស្ទង់នេះបានបង្ហាញថា ក្នុងតំបន់ដែលគំរោងទាំង ១២ចំណុចនេះត្រូវបានអនុវត្តមានអ្នកនៅមានជីវិតជាច្រើន

146 Response to LM Questionnaire by Mu Socheat, CARITAS, 6 February 2004.

147 Response to LM Questionnaire by Annd de Pasquat, DAC, Phnom Penh, February 2003; Response to LM Questionnaire by Andrea Crossland, International Adviser, Children Affected by Mines, 19 April 2002.

148 See DAC, "Cambodia 2003," pp. 10-11, 16 and 19.

149 Data collected during Jesuit Services Outreach Program as of 31 March 2000.

ដែលបានទទួលជំនួយបានរាយការណ៍អំពីគុណភាពនៃជីវិតប្រកបដោយភាពរីករាយជាងមុន ប៉ុន្តែអ្នកនៅមានជីវិតជាច្រើនថែមទៀតកំពុងរង់ចាំជំនួយ ។

ផ្នែកជំនួយជនរងគ្រោះនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរមីន បានបង្កើតយុទ្ធសាស្ត្រមួយសំរាប់គំរោងរយៈពេលវែងនិងមធ្យម ដើម្បីសំរបសំរួលជំនួយជនរងគ្រោះដោយគ្រាប់មីន ដែលបានផ្តល់ដោយវិទ្យាស្ថានជាតិ អង្គការក្រៅរដ្ឋាភិបាលជាតិ និង អន្តរជាតិ [150] ។ គំរោងជាយុទ្ធសាស្ត្ររបស់អាជ្ញាធរមីន សំរាប់ជំនួយជនរងគ្រោះរួមមានៈ ការប្រមូលពត៌មានពីអ្នកផ្តល់សេវាកម្ម និង ការបង្កើតរបាយការណ៍ ការឆ្លើយតបភ្លាមៗដល់ការព្យាបាល ការប៉ះទង្គិចខ្លាំង និង ប្រព័ន្ធដឹកជញ្ជូនសំរាប់គ្រោះថ្នាក់ដោយគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដែលមានទំនាក់ទំនងជាមួយក្រសួងសុខាភិបាល ដើម្បីធានាការមានសេវាកម្មព្យាបាលនៅតាមមន្ទីរពេទ្យ និង ការតាមដានសំរាប់អ្នកនៅមានជីវិតពីគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ធ្វើការជាមួយគណៈកម្មាធិការស្តាររាងកាយ ក្រុមប្រឹក្សាសកម្មភាពជនពិការដើម្បីចូលរួមចំពោះគំរោងជាតិស្តីអំពីតំរូវការរបស់អ្នកនៅមានជីវិតពីគ្រាប់មីន ជួយអ្នកនៅមានជីវិតពីគ្រាប់មីនដឹកនាំជីវភាពផលិតកម្មធម្មតាដោយបង្កើតយុទ្ធសាស្ត្រផ្សេងៗ និងកម្មវិធីនាំមុខ ដែលលើកទឹកចិត្តដោយសកម្មភាពកាត់បន្ថយភាពក្រីក្រ និង កម្មវិធីបង្កើតប្រាក់ចំណូល និងការបង្កើតទិន្នន័យពាក់ព័ន្ធ ដើម្បីប្រមូលពត៌មាន ដែលនឹងជួយដល់អង្គការក្រៅរដ្ឋាភិបាលនានា, រដ្ឋាភិបាល និង ម្ចាស់ជំនួយក្នុងការអនុវត្តន៍កម្មវិធីជំនួយជនរងគ្រោះដោយសារគ្រាប់មីនបានចំគោលដៅ[151] ។ នៅថ្ងៃទី ១០ ខែ មិនា ឆ្នាំ ២០០៤ កិច្ចប្រជុំមួយរបស់អង្គការក្រៅរដ្ឋាភិបាល និង ក្រសួងនានារបស់រដ្ឋាភិបាលត្រូវបានរៀបចំឡើងនៅក្នុងលេខាធិការដ្ឋានអាជ្ញាធរមីន ដើម្បីពិនិត្យមើលតួនាទីរបស់អាជ្ញាធរមីនក្នុងការសំរបសំរួលជំនួយជនរងគ្រោះ ។ ពង្រាងគំរោងយុទ្ធសាស្ត្រសំរាប់ ឆ្នាំ ២០០៤ ដល់ ២០០៩ ត្រូវបានដាក់ជូនដើម្បីពិភាក្សា ។

យុទ្ធនាការលុបបំបាត់មីនកម្ពុជាបាននិយាយថាៈ ការប្រណាំងប្រជែងសំរាប់រាជរដ្ឋាភិបាលកម្ពុជា គឺត្រូវសំរួលសិទ្ធិនិងតំរូវការរបស់អ្នកនៅមានជីវិតពីគ្រាប់មីននិងសហគមន៍ ដែលរងគ្រោះរបស់ពួកគេតាមរយៈប្រព័ន្ធវិមជ្ឈការ ការបែងចែកថវិកា ប្រកបដោយភាពប្រាកដនិយម ដើម្បីបំពេញតំរូវការជំនួយអន្តរជាតិ មានសារៈសំខាន់ក្នុងការផ្តល់ធនធានដ៏ចាំបាច់សំរាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដែលនឹងសំរួលការបញ្ចូលសេដ្ឋកិច្ចសង្គមរបស់អ្នកនៅមានជីវិតដោយគ្រាប់មីននិងសហគមន៍របស់គេនិងសំរាប់តំរូវការស្តារនិងព្យាបាលសុខភាពរបស់គេ[152] ។

អ្នកនៅមានជីវិតពីគ្រាប់មីនចំនួន ២ នាក់ មកពីប្រទេសកម្ពុជា បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលបញ្ចេញសំលេង (Raising the Voices Training) ដែលរៀបចំធ្វើនៅទីក្រុងហ្សឺណែវប្រទេសស្វីសក្នុងខែឧសភា ឆ្នាំ២០០៣ ហើយបានចូលរួមក្នុងកិច្ចប្រជុំលើកទី៥ របស់ភាគីរដ្ឋសមាជិកសន្ធិសញ្ញាក្នុងទីក្រុងបាងកកកាលពីខែកញ្ញា ឆ្នាំ២០០៣ ។

ចាប់តាំងពីឆ្នាំ ២០០២ មក ប្រទេសកម្ពុជាបានដាក់ជូននូវទំរង់ស្ម័គ្រចិត្ត អក្សរ J ភ្ជាប់ជាមួយរបាយការណ៍មាត្រា៧ ប្រចាំឆ្នាំរបស់ខ្លួនដោយផ្តល់នូវពត៌មានអំពីគ្រោះថ្នាក់ដោយគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះនិងសេវាកម្មស្តារដល់អ្នកនៅមានជីវិតពីគ្រាប់មីន[153] ។

## ការអនុវត្ត និង គោលនយោបាយសំរាប់ជនពិការ

នៅឆ្នាំ ២០០០ ពង្រាង "ច្បាប់ស្តីពីសិទ្ធិរបស់ជនពិការ" ត្រូវបានរៀបចំឡើងក្រោមកិច្ចសំរបសំរួលរបស់

[150] CMAA, "Mine Action: 1992-2003," 29 April 2004, p. 6.
[151] Ibid, pp. 33-34.
[152] Presentation by Denise Coghlan, Standing Committee on Victim Assistance, 10 February 2004.
[153] Article 7 Report, Form J, 30 April 2004; Article 7 Report, Form J, 15 April 2003; Article 7 Report, Form J, 19 April 2002.

ក្រុមប្រឹក្សាសកម្មភាពជនពិការ ។ ពង្រាងចុងក្រោយនៃច្បាប់នេះត្រូវបានបញ្ជូនទៅក្រសួងសង្គមកិច្ចនៅឆ្នាំ ២០០២ ដើម្បីពិនិត្យនិងអនុម័តមុនពេលដាក់ជូនទៅក្រុមប្រឹក្សារដ្ឋមន្ត្រីរួមទាំងឯកសារទស្សនៈ ដែលរៀបរាប់អំពីហេតុផល និងផលប្រយោជន៍នៃច្បាប់ដែលបានស្នើនេះ[154] ។ នៅខែមិថុនា ឆ្នាំ២០០៤ គេបានប្រកាសថាការត្រួតពិនិត្យឡើងវិញត្រូវបានបញ្ចប់ ហើយនីតិកម្មច្បាប់បានធ្វើរួចរាល់ដើម្បីដាក់ជូនទៅក្រុមប្រឹក្សារដ្ឋមន្ត្រីនិងបន្ទាប់មកជូនទៅសភាជាតិ "នៅក្នុងវគ្គសិក្សាដែលគ្រោងឡើង" [155] ។ ទោះជាយ៉ាងណាក៏ដោយវាទំនងជាថា នៅត្រឹមខែ កញ្ញា ឆ្នាំ២០០៤ នីតិកម្មនេះមិនត្រូវបានដាក់ជូនទៅក្រុមប្រឹក្សារដ្ឋមន្ត្រីឡើយ ។

អាជ្ញាធរមីនកម្ពុជា ទទួលខុសត្រូវលើការសំរបសំរួល និង ត្រួតពិនិត្យជំនួយជនរងគ្រោះដោយគ្រាប់មីន។ យ៉ាងណាក៏ដោយ អាជ្ញាធរមីន បាន ផ្តល់ការទទួលខុសត្រូវនេះដល់ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនិតិសម្បទា និង ក្រុមប្រឹក្សាសកម្មភាពជនពិការ [156] ។

ក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) ត្រូវបានផ្តួចផ្តើមបង្កើតឡើងដំបូងនៅឆ្នាំ១៩៩៧ ជាអង្គការសំរបសំរួលជាតិពាក់កណ្តាលស្វ័យប្រវត្តិលើសកម្មភាពស្តារនិងពិការភាព ។ DAC បានក្លាយជាអង្គការប្រតិបត្តិទាំងស្រុងក្នុងខែ កញ្ញា ឆ្នាំ ១៩៩៨ ដោយមានការផ្តល់មូលនិធិពីអង្គការមូលនិធិ Leahy War Victims Fund របស់ USAID ។ រដ្ឋាភិបាលបានទទួលស្គាល់ជាផ្លូវការនូវស្ថានភាពរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រោមប្រកាសរបស់ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនិតិសម្បទា លេខ ៣០៨ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៩[157] ។ ក្រុមប្រឹក្សាសកម្មភាពជនពិការ ក៏បានសំរបសំរួលសកម្មភាពស្រាវជ្រាវផងដែរដើម្បីជំរុញលើកតំកើងបញ្ហាពិការភាព[158] ។ តួនាទីចម្បងរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ គឺសំរបសំរួលនិង ផ្តល់ប្រឹក្សាដល់រដ្ឋាភិបាលអំពីការបង្កើតគោលនយោបាយ ដែលប៉ះពាល់ដល់សិទ្ធិ តំរូវការ និង សុខុមាលភាពរបស់ជនពិការ និងដើម្បីសំរបសំរួលដល់ការបង្កើតគំរោងសកម្មភាពជាតិ។ បន្ទាប់ពីអនុសាសន៍របស់ក្រុមពិគ្រោះយោបល់ ដែលផ្តល់មូលនិធិដោយ USAID ក្នុងខែកុម្ភៈ ឆ្នាំ២០០៣ ដើម្បីរៀបចំរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការឡើងវិញ ក្រុមប្រឹក្សាភិបាលថ្មីមួយត្រូវបានបង្កើតឡើងក្នុងខែកុម្ភៈ ឆ្នាំ២០០៤ ។ ក្រុមប្រឹក្សាភិបាលថ្មីនេះ រួមមានតំណាង ៣នាក់ មកពីក្រសួងសុខាភិបាល ក្រសួងអប់រំយុវជននិងកីឡា និង ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនិតិសម្បទា ម្នាក់មកពីលេខាធិការរដ្ឋានអាជ្ញាធរមីន តំណាងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ២នាក់ (សមាគមជនពិការភ្នែកកម្ពុជា និងសមាគមនការរស់នៅដោយឯករាជ្យរបស់ជនពិការកម្ពុជា), តំណាងអង្គការអន្តរជាតិ ២រូប (Handicap International និង Cambodia Trust) និង តំណាង ១រូប មកពីផ្នែកពាណិជ្ជកម្ម (TOTAL) ។ នាយកប្រតិបត្តិនៅតែកំពុងត្រូវបានជ្រើសរើសនៅឡើយ[159] ។

---

[154] Response to LM Questionnaire by Ouk Sisovann, DAC, 22 January 2003. The full text of the draft legislation is available at www.dac.org.kh/legislation/list-laws/draft-disability-law.htm. (accessed 3 September 2004).

[155] Presentation by Sam Sotha, CMAA, Standing Committee on Victim Assistance and Socio-Economic Reintegration, Geneva, 23 June 2004.

[156] Ibid; Article 7 Report, Form J, 30 April 2004.

[157] CMAA, *2002 Work Plan*, Phnom Penh, December 2001, p. 8.

[158] For details see *Landmine Monitor Report 2001*, pp. 453-454.

[159] Steering Group meeting, National Institute of Public Health, Phnom Penh, 27 February 2004. DAC released a plan of action in February 2001, but it would appear that no real progress was made due to the restructuring of DAC. See *Landmine Monitor Report 2001*, p. 451. For more details see Disability Action Council website at www.dac.org.kh.